01501367 E1/279.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Jun-2017, 10:20
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី២៦០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី
លោក រ៉ូជឺ ហ្វីលីព *(Mr.Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត
លោក សេង លាង
លោក ដេល លីសាក់ *(Mr.Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ
លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៃ ជុនធី

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក វៀល សន (2-TCW-860) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក រឿល សន** (2-TCW-860)

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ....................................................................ទំព័រ ៣
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី..............................................................................ទំព័រ ៣៣
សួរដោយលោក គង់ សំអុន ផ្ដើមពី ...........................................................................ទំព័រ ៦៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី រៀល សន។ ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ លោកមេធាវីប្រចាំការសម្រាប់លោក ខៀវ សំផន គឺលោក ខលវីន សោនដឺស៍ បានជូនដំណឹងមកថា លោកនឹងមាន -- នឹងមកយឺតបន្តិចនៅពេលព្រឹកនេះ។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក រៀល សន។ លោក និងលោកមេធាវីប្រឹក្សាគឺលោក ឌុច ផារី មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៥:២៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកស្រី វុឌ្ឍី ។

បាទ មុននឹងផ្ដល់វេទិកាជូនទៅភាគី អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយមានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន និងមិនអាចផ្ចង់អារម្មណ៍បានយូរ និង

ដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៨ ខែមីនា ២០១៥។

[០៩:០៦:០៨]

មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់នឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។ បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា សុខភាពរបស់ជនជាប់ចោទ នួន ជា មានអការៈឈឺចង្កេះជាប្រចាំ វិលមុខ មិនអាចអង្គុយបានយូរ និងផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះ យល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោទស្សន៍សម្រាប់រយៈពេលសវនាការពេញ១ថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាករនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោទស្សន៍ភ្ជាប់ប្រព័ន្ធសោទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ មុននឹងផ្តល់វេទិកាជូនទៅភាគីការពារក្តី ខ្ញុំសូមសួរទៅអស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីចង់សួរសាក្សីរូបនេះដែរឬទេ? បើសិនមានសូមអញ្ជើញបាទ។

បាទ សូមអញ្ជើញ លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[០៩:០៨:០៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ហ្សង់ម៉ាក ឡាវែន៍។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសុំឲ្យលោកបំភ្លឺចម្លើយរបស់លោកដែលលោកបានឆ្លើយរហូតមកទល់នឹងពេលនេះ។ ជាបឋម ខ្ញុំចង់ឲ្យលោកបញ្ជាក់អំពីការៗសិក្សារបស់លោក។ លោករៀនដល់ថ្នាក់ណាដែរ លោកសាក្សី?

**លោក វៀល សេន៖**

**ឆ៖** បាទ ខ្ញុំបាទរៀនដល់ថ្នាក់ទី៣ ពីសង្គមចាស់។

**ប្រធានអង្គជំនុំ៖**

សាក្សី សូមឆ្លើយម្តងទៀត ចម្លើយអម្បាញ់មិញនេះ ហើយអ្នកបកប្រែ បកប្រែមិនទាន់ទេ។

**លោក វៀល សេន៖**

**ឆ៖** បាទ ខ្ញុំបាទរៀនដល់ថ្នាក់ទី៣ ពីសង្គមចាស់។

[០៩:០៩:២៨]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ដូច្នេះ គឺថ្នាក់ទី៣ចាស់។ អ៊ីចឹង ខ្ញុំចង់ដឹងទៀតថា លោករៀននៅឯណាដែរ?

**ឆ៖** ខ្ញុំបាទរៀននៅអនុវិទ្យាល័យព្រះឧទ័យនៅតាកែវ។

**ស៖** ចុះនៅភ្នំពេញ លោកមានបានមករៀនទេ?

**ឆ៖** បានមករៀននៅភ្នំពេញតាំងពីតូចអាយុ១៣ឆ្នាំ ដល់ទៅប្រឡងចូលជាប់នៅរៀនឯសាលាអនុវិទ្យាល័យព្រះឧទ័យតាកែវហ្នឹង ថ្នាក់ទី៦។

**ស៖** លោករៀននៅ<ឯណា? សាលាណាមួយដែរ>?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ រង់ៗចាំរហូតដល់ក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យសញ្ញាភ្លើងក្រហម សូមឆ្លើយណ៎ា។

**លោក វៀល សេន៖**

**ឆ៖** បាទ ខ្ញុំបាទរៀននៅអនុវិទ្យាល័យព្រះឧទ័យតាកែវ កាលនោះ។

[០៩:១១:១៦]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** នៅក្នុងកំណត់ហេតុ<នៃការស្តាប់ចម្លើយ>របស់លោក លោកថាលោករៀននៅវិទ្យាល័យកម្ពុជាបុត្រ លោកជាសិស្សរបស់ ហ៊ូ យន់។ អ៊ីចឹង តើនេះជាការភាន់ច្រឡំទេ ឬក៏ជាចម្លើយត្រឹមត្រូវ?

**ឆ៖** បាទ មិនភាន់ច្រឡំទេ គឺកាលនោះ ខ្ញុំរៀននៅអនុវិទ្យាល័យតាកែវ ប៉ុន្តែដល់ពេលឈប់សម្រាកវ៉ាកង មករៀនគួរនៅភ្នំពេញ។

**ស៖** អ៊ីចឹងៗ ចាប់ពីពេលដែលលោកចូលរៀនមក លោកមានបានចូលទៅក្នុងក្រុមមួយដែលគេហៅថា មជ្ឈដ្ឋានជនចម្រើនទេ?

**ឆ៖** បាទ កាលនោះ គ្មានទេ ទាល់តែខ្ញុំឈប់រៀន មកនៅជាកសិករនៅផ្ទះ ហ្នឹងបានក្លាយទៅជាជនចម្រើន។

**ស៖** អ៊ីចឹង តើលោកមានការងារអ្វីខ្លះ នៅមុនពេលដែលលោកចូលបដិវត្ត<?> <តើ>លោកបានចូលបដិវត្ត<នៅឆ្នាំណា>?

[០៩:១២:៥៥]

**ឆ៖** តាមពិតទៅ ខ្ញុំបាទចូលបដិវត្តតាំងពី ខ្ញុំភ្លេចឆ្នាំទៅហើយ ប៉ុន្តែតាំងពីមាន តាំងពីរបបលន់នល់ រលំទៅបានប៉ុន្មានខែ ខ្ញុំចូលជាចលនាបដិវត្តហ្នឹង។

**ស៖** ហើយមុនពេលចូលបដិវត្តនោះ ខ្ញុំចង់ដឹងថាលោកធ្វើអ្វីដែរ? <តើ>លោកជាកសិករ<មែនដែរឬទេ>? ខ្ញុំឃើញថា<លោកគឺ ជាជាង>កាំបិត ហើយលោកជាជាង<ម៉ាស៊ីន>ទៀត។ <> តើ<លោកមានរបរអ្វីខ្លះ>?

**ឆ៖** បាទ កាលមុនហ្នឹង គឺធ្វើជាងបន្តិចបន្តួច មានកាំបិត មានដែកឈូស មានរណារអីហ្នឹងតិចតួចទេ ធ្វើនៅភូមិ។

**ស៖** <តើលោកជាជាងម៉ាស៊ីនមែនដែរឬទេ>? ហើយបើ<មែន> តើលោកទទួលការបណ្តុះបណ្តាលផ្នែកនេះនៅកន្លែងណាដែរ?

**ឆ៖** បានធ្វើជាជាងតូចតាច ព្រោះមានមេជាងនៅក្នុងភូមិ។ ខ្ញុំធ្វើជាងធ្វើកូនដៃគេទេ។

[០៩:១៥:០០]

**ស៖** នៅពេលដែលលោកចូលបដិវត្ត តើលោក<ផ្លាស់ប្តូរជំនាញដែរឬទេ>? លោកមានចាប់ផ្តើមធ្វើ<សកម្មភាព>ឃោសនា<ដែរឬទេ? តើលោក>ចុះទៅតាមឃុំ ដើម្បីប្រមូលយុវជនឲ្យចូល

បដិវត្តទេ? តើ<លោកបានធ្វើ>សកម្មភាព<បែបនោះដែរឬ>ទេ?

**ឆ៖** បាទ មាន។ អង្កាល់នោះ ចូលបដិវត្តភ្លាមដើរប្រមូលយុវជននៅតាមភូមិ តាមឃុំហ្នឹងឲ្យធ្វើយោធា។

**ស៖** កាលពីម្សិលមិញ <ខ្ញុំបានឮ> ក៏ដូចជា<អាន>កំណត់ហេតុ<នៃការស្តាប់ចម្លើយ>របស់លោក លោកឆ្លើយថា លោកធ្វើការនៅការដ្ឋានទំនប់<ត្រពាំងបី> ឬក៏ខ្ពបត្របែក។ ខ្ញុំមិនដឹងថា តើជាទំនប់តែមួយ ឬក៏ជាទំនប់ផ្សេងគ្នា។ <តើ>លោកចាប់ផ្តើមធ្វើ<ការនៅការដ្ឋាន>ទំនប់ហ្នឹង<នៅពេលណា>? តើលោក<មាននាទី>ជាអ្វី<?> ជាប្រធានកង ជាអ្នក<គ្រប់គ្រង> ឬក៏លោកគ្រាន់តែជាកម្មករធ្វើទំនប់ធម្មតាទេ?

**ឆ៖** បាទ ខ្ញុំបាទជាកម្មករធ្វើទំនប់ធម្មតាទេ។

[០៩:១៦:៤០]

**ស៖** តើមុន ១៧ មេសា ៧៥ ឬក៏យ៉ាងម៉េច? <តើវានៅពេលដែល> អាមេរិកាំងលែងទម្លាក់គ្រាប់បែកទៀត<មែនដែរឬទេ? តើលោកធ្វើនៅពេលណាដែរ>?

**ឆ៖** បាទ ធ្វើទំនប់ហ្នឹង គឺអាមេរិកកាំងកំពុងតែទម្លាក់គ្រាប់បែក។

**ស៖** តើមានមនុស្សប៉ុន្មាននាក់ដែលធ្វើការនៅការដ្ឋានជាមួយលោកហ្នឹង? <តើ>ការដ្ឋាន<នោះ>ធំ<ដែរឬ>ទេ?

**ឆ៖** បាទ ការដ្ឋានហ្នឹងធំ គឺប្រមូលប្រជាពលរដ្ឋគ្រប់ឃុំមកធ្វើនៅកន្លែងហ្នឹងទាំងអស់គ្នា។ គ្រប់ឃុំទូទាំងស្រុកត្រាំកក់។

**ស៖** អ៊ីចឹងមានមនុស្សប៉ុន្មាននាក់ដែរ រាប់សិប រាប់រយ រាប់ពាន់<នាក់> លោកអាចបញ្ជាក់ចំនួនមនុស្សដែលធ្វើការនៅទីនោះបានទេ?

**ឆ៖** ខ្ញុំមិនបានដឹងចំនួនមនុស្សធ្វើការនៅកន្លែងនោះពិតប្រាកដទេ ប៉ុន្តែក្នុងមួយឃុំបើយ៉ាងហោចណាស់ក៏មាន២០នាក់ដែរ មួយឃុំ២០នាក់។

**ស៖** អ៊ីចឹង<នៅពេល>នោះ គឺមាន១២ឃុំ អ៊ីចឹង<មានកម្មករ>ប្រហែលជា២៥០នាក់។ អ៊ីចឹងមែនទេ លោកគិតមើលទៅមើល ប្រហែលជាប៉ុណ្ណឹងទេ?

**ឆ៖** បាទ ប្រហែលប៉ុណ្ណឹង ២០០នាក់ជាងហ្នឹង ប្រហែល។

[០៩:១៩:០០]

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** តើលោកចាំទេ ថាគណៈប្រតិភូចិននោះ មានមកសម្ពោធទំនប់ហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងផង។ អត់ដែលឃើញចិនមកសម្ពោធទេ ដែលឃើញតែចិនជិះឡាន កាត់ហ្នឹង កាត់ដែលទំនប់កំពុងតែធ្វើហ្នឹង។ ជិះហ្នឹងនៅពេលយប់ទៀត។

**ស៖** <បើមិនច្រឡំទេ>កាលពីម្សិលមិញ <>លោកបានឆ្លើយថា បានឃើញ ខៀវ សំផន នៅ <ការដ្ឋាន>ទំនប់ហ្នឹង។ អ៊ីចឹងខ្ញុំស្តាប់ហ្នឹងត្រូវទេ ឬក៏ខ្ញុំស្តាប់ច្រឡំទេ?

**ឆ៖** បាទ បើតាមខ្ញុំបាទយល់ថា មិនច្រឡំទេ មិនមែនឃើញនៅលើទំនប់ទេ គឺឃើញគាត់នៅ មានមន្ទីរមួយនៅក្នុងព្រៃឫស្សី ព្រៃឫស្សីជិតហ្នឹង។ ឃើញមួយភ្លែតទេ។

**ស៖** ហើយមន្ទីរព្រៃឫស្សីហ្នឹងជាមន្ទីរសម្រាប់អ្នកធ្វើការនៅការដ្ឋានសាងសង់ទំនប់ហ្នឹង ឬក៏ <គេមាន>មន្ទីរ<>ផ្សេងដាច់ដោយឡែក<មួយទៀត>?

**ឆ៖** បាទ ខ្ញុំបាទមិនដឹងទេមន្ទីរហ្នឹង ដោយសារប្រពន្ធ តាម៉ុក យាយខឹម គាត់រកខ្ញុំជួយដឹកនាំ គាត់ទៅ គាត់យកមិនរួច ដឹកជាមួយកង់។ ទៅដល់ហ្នឹង ទៅដល់ត្រង់ឆ្ងាយពីមន្ទីរបន្តិច គាត់ប្រាប់ថា ឲ្យ ខ្ញុំត្រឡប់មកវិញចុះ ដាក់ដំដាក់អីហ្នឹង ហើយគាត់ចង្អុលប្រាប់ថា នោះ តាខៀវ សំផន។

**ស៖** <តើ>លោក<>ឃើញគាត់ផ្ទាល់ភ្នែក ឬក៏<លោកគ្រាន់តែឮគេប្រាប់>ថា លោក ខៀវ សំផន នៅក្នុងមន្ទីរ<នោះ? តើមន្ទីរនោះមានទីតាំងនៅឯណា>?

[០៩:២១:៥៤]

**ឆ៖** នៅក្នុងភូមិចំបក់ពណ្ណរាយហ្នឹង ប៉ុន្តែភូមិចំបក់ពណ្ណរាយហ្នឹងមានព្រៃ ព្រៃឫស្សីធំណាស់ ហើយមន្ទីរហ្នឹងនៅកណ្តាលហ្នឹង។ ហើយខ្ញុំបានឃើញតែមួយភ្លែតហ្នឹង គ្រាន់តែចង្អុលប្រាប់ ខ្ញុំឡប់មក វិញមក ព្រោះ យាយខឹម ហ្នឹងគាត់ប្រាប់ថាឲ្យទៅៗ កុំនៅ។

**ស៖** ដូច្នេះ លោកឃើញគាត់តែមួយភ្លែតទេ។ អ៊ីចឹងពីមុនមកនោះលោកធ្លាប់ជួបលោក ខៀវ សំផន ទេ ដូចជានៅភ្នំពេញ ឬក៏នៅកន្លែងផ្សេង<ដែរឬ>ទេ?

**ឆ៖** នៅភ្នំពេញធ្លាប់តែឃើញ មិនបានជួបទេ ប៉ុន្តែធ្លាប់ឃើញ។

**ស៖** តើលោកមានបាន<ទៅ>ចូលរួមក្នុង<ពិធីរៀបការ>លោក ខៀវ សំផន<ដែរឬ>ទេ?

**ឆ៖** បាទ មិនបានចូលរួមទេ ប៉ុន្តែបានជួយដឹកនំដឹកអីទៅជាមួយប្រពន្ធ តាម៉ុក ហ្នឹង តែមួយ ភ្លែតហ្នឹង។

**ស៖** ខ្ញុំយល់មិនសូវច្បាស់ទេលោក។ នំហ្នឹងដឹកទៅដើម្បីអី សម្រាប់យកទៅឲ្យលោក ខៀវ

សំផន រៀបការ ឬក៏សម្រាប់<កម្មវិធីអ្វី>ផ្សេង?

**ឆ៖** ខ្ញុំមិនដឹងថាមូលហេតុអីទេ គ្រាន់តែ យាយខឹម ហ្នឹងប្រាប់ថា “ការៗលោក ខៀវ សំផន”។

[០៩:២៤:០៧]

**ស៖** យាយ<ខឹម> ជាកូន<ស្រី>តាម៉ុក ដែល<លោកនិយាយថាមានរោគសរសៃប្រសាទ> ឆ្កួតហ្នឹង<មែនដែរឬទេ>?

**ឆ៖** បាទ យាយខឹម ម៉ែ យាយខុម។ យាយខឹម ប្រពន្ធតាម៉ុក, យាយខុម កូនតាម៉ុក។

**ស៖** អ៊ីចឹងខ្ញុំសង្ខេបឡើងវិញ។ លោកបានឃើញ<មនុស្សម្នាក់> មួយភ្លែត<ទេ ហើយក្រោយមក>លោកគិតថាគាត់ហ្នឹងជា ខៀវ សំផន។ អ៊ីចឹងលោកនៅចម្ងាយប៉ុន្មានម៉ែត្រដែរ<បុគ្គលនោះ>? ហើយពេលដែលឃើញហ្នឹង ឃើញពេលថ្ងៃ ឬក៏ពេលយប់? ហើយលោកឃើញហ្នឹងឃើញមុខគាត់ច្បាស់ទេ?

**ឆ៖** ខ្ញុំបានឃើញថ្ងៃ ប៉ុន្តែឆ្ងាយពីគ្នាប្រហែលជា ៥០ម៉ែត្រ មើលមុខមិនឃើញទេ គ្រាន់តែដឹងថាឈ្មោះ ខៀវ សំផន ហ្នឹងដោយសារ យាយខឹម ហ្នឹងគាត់ប្រាប់ថា នោះ! លោក ខៀវ សំផន។ ប៉ុន្តែមើលមុខមិនដឹងទេ មិនស្គាល់។

**ស៖** នៅពេលណាដែរ ដែលលោកឈប់ធ្វើការនៅ<ការដ្ឋានត្រពាំងបី ឬការដ្ឋាន>ទំនប់ខ្ទបត្របែក<>? ហើយបន្ទាប់ពីឈប់ធ្វើទំនប់ហ្នឹងទៅ លោកធ្វើអ្វីទៀត<>?

**ឆ៖** បាទ ខ្ញុំភ្លេចទៅហើយមិនដឹងថា ឈប់នៅពេលឆ្នាំណាទេ ប៉ុន្តែធ្វើទំនប់ហ្នឹងហើយបានឈប់។ ហើយឈប់ពីហ្នឹងមកៗ ខ្ញុំមកធ្វើជាងនៅស្រុក១០៥ហ្នឹង។

**ស៖** <តើគេឱ្យលោកធ្វើអ្វី? តើគេឱ្យ>លោក<ដើរ>មានចាក់ថ្នាំ ចែកថ្នាំទេ<? តើ>នៅពេលដែលលោកធ្វើជាង<ម៉ាស៊ីន លោកមានភារកិច្ចទាំងអស់នេះដែរឬទេ>?

**ឆ៖** បាទ ធ្វើជាងហ្នឹងខ្ញុំធ្វើជាសេដ្ឋកិច្ចទេ សម្រាប់ដើររកស្រូវអង្ករអីមកឱ្យជាងក្នុងអង្គភាពហ្នឹងហូប។ ហើយមិនដែលបានធ្វើអីទេ គឺអត់ដែលបានធ្វើអី ដើររកតែស្រូវអង្ករ។

[០៩:២៧:៤០]

**ស៖** ដូច្នេះ លោកមិនមែនជាជាង<ម៉ាស៊ីន>ទេអ៊ីចឹង។<តើ>លោកជា<ប្រធាន>កង<ហ្នឹង> ឬក៏លោកជាអ្នកទទួលបន្ទុករកស្បៀង? ហើយ<កិច្ចការ>របស់លោក<>មានរួមបញ្ចូល<ទាំងសេវាសុខភាពមែនដែរឬ>ទេ?

**ឆ៖** បាទ កាលនោះ ខ្ញុំធ្វើជាង ប៉ុន្តែនៅក្នុងអង្គភាពជាងហ្នឹង ប៉ុន្តែកាន់ខាងសេដ្ឋកិច្ចដើររកនេះហ្នឹង។ ហើយមិនបានមានថ្នាំអីចែកទេ កាលនោះ អត់មានថ្នាំមានអីចែកឲ្យនេះទេ។ ហើយដែលប្រធានខ្ញុំហ្នឹងដោយឡែក។

**ស៖** នៅក្នុងកំណត់ហេតុ<នៃការស្តាប់ចម្លើយ>របស់លោក លោកបានឆ្លើយថា លោកទទួលខុសត្រូវក្នុងការទិញថ្នាំ ទិញវត្ថុធាតុដើម ដើម្បីផលិតថ្នាំ។ ខ្ញុំចង់ដឹងថា តើ<>លោកចាប់ផ្តើមធ្វើ<ការងារ>បែប<នេះនៅពេលណា>?

**ឆ៖** បាទ នៅពេលដែលមន្ទីរពេទ្យខ្វះខាតថ្នាំព្យាបាល ខ្ញុំបាទស្នើទៅស្រុក ទៅគណៈស្រុកៗឲ្យលុយឲ្យកាក់ខ្លះទៅទិញ។

**ស៖** តើលោក<ទទួលខុសត្រូវផ្នែក>ទិញ<ឱសថសម្រាប់ផ្គត់ផ្គង់មន្ទីរពេទ្យ>មុនពេលដែលលោកគេតែងតាំងឲ្យទៅធ្វើ<ប្រធាន>មន្ទីរពេទ្យ ឬក៏<ពេល>ក្រោយ<ពីលោកបានទទួលការតែងតាំងនោះ>?

**ឆ៖** បាទ ពេលខ្ញុំទៅទិញថ្នាំ គឺធ្វើពេទ្យហើយបានទៅទិញ។ វាខ្វះថ្នាំ។

[០៩:៣០:០៨]

**ស៖** ខ្ញុំមិនសូវយល់ គឺមុន ឬក៏ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥?

**ឆ៖** ក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥។

**ស៖** កាលពីម្សិលមិញ លោកបានពន្យល់ថា លោកបាន<ចូលរួមការបណ្តុះបណ្តាលចំនួនពីរលើក> គឺម្តង<មានរយៈពេល>៣ខែ ម្តងទៀត<មានរយៈពេល>៦ខែ ហើយលោក<ប្រាប់>ថា អ្នកបង្រៀនហ្នឹងឈ្មោះ សី។ តើលោកអាចបញ្ជាក់ចំណុចនេះបានទេ?

**ឆ៖** បាទ ខ្ញុំកាលនោះ សី ហ្នឹងគាត់ជាប្រធានពេទ្យតំបន់។ គាត់កោះហៅទៅរៀនរយៈ៣ខែៗហ្នឹងចប់ ក្រោយមកទៅរៀន៦ខែ។ ប៉ុន្តែទៅរៀន៣ខែហ្នឹង មិនបានរៀន មិនបាន២អាទិត្យផង ចប់ហើយ ត្រឡប់មកកន្លែងវិញហ្នឹង ហៅវគ្គ៣ខែ។ ដល់វគ្គ៦ខែ រៀនបានប្រហែលជាកន្លះខែ ១៥ថ្ងៃហ្នឹងក៏ចប់ទៀតទៅ។

**ស៖** ខ្ញុំមិនសូវយល់ទេ លោកសាក្សី។ វគ្គ៣ខែ និង៦ខែហ្នឹង គឺរៀន ដល់ពេលរៀនមែនទែនទៅតែ២អាទិត្យទេ<ក្នុងមួយវគ្គៗនោះមែនដែរឬទេ>? ឬក៏<មានការផ្លាស់គ្នា>២សប្តាហ៍<ម្តងឬ>យ៉ាង<ដូចម្តេច?> ខ្ញុំអត់យល់<ទេ>លោកសាក្សី<។>

[០៩:៣២:០១]

**ឆ៖** បាទ កាលនោះ យើងទៅរៀន ប៉ុន្តែដល់ពេលមានរវល់ការងារនៅមន្ទីរពេទ្យច្រើន យើងអត់ទៅ អត់ទៅរៀនទាំងវគ្គ៣ខែ ទាំងវគ្គ៦ខែហ្នឹងដូចគ្នា។ តែកាលណានៅមន្ទីរពេទ្យមានការងារច្រើន គឺយើងអត់ទៅ គ្រាន់តែសរសេរសំបុត្រប្រាប់ប្រធាននោះថា រវល់អ៊ីចេះ រវល់អ៊ីចុះទៅ រវល់ធ្វើការនៅក្នុងមន្ទីរពេទ្យហ្នឹង អ្នកជំងឺច្រើន អីច្រើនអ៊ីចឹងទៅ គ្មានអ្នកនៅ យើងក៏ទៅរករហូតទៅដល់តែចប់វគ្គទៅ។

**ស៖** <ដូច្នេះ>ខ្ញុំអាចនិយាយបានទេថា មុនពេលដែល<គេតែងតាំងលោកជាប្រធាន>មន្ទីរពេទ្យហ្នឹង លោក<មិនដែល>ទទួល<បានការ>បណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** ដូច្នេះគេហៅឲ្យលោកចូលរួមរៀនពីរវគ្គ មួយវគ្គ៣ខែ ហើយនិង៦ខែ ក៏ប៉ុន្តែតាមពិតទៅលោកបានចូលរៀនតែប្រហែលជា២សប្តាហ៍ទេ ក្នុងមួយវគ្គៗហ្នឹង។ អ៊ីចឹងសរុបទៅ លោកបានរៀនប្រហែល១ខែ ដើម្បីចូលទៅដឹកនាំមន្ទីរពេទ្យស្រុកនោះ។ អ៊ីចឹងមែនទេ តាមចម្លើយរបស់លោកនោះ?

**ឆ៖** បាទ អង្កាល់រៀននេះ មិនមែនរៀនមុនចូលធ្វើពេទ្យទេ គឺធ្វើពេទ្យទៅហើយ បានគេហៅទៅរៀន។

[០៩:៣៤:០៦]

**ស៖** នៅពេលណាដែលលោកចាប់ផ្តើមចាក់ថ្នាំ<បង្ការ>ឲ្យអ្នកជំងឺលើកទី១ <តើវា>មុនពេលគេតែងតាំងលោក<ជាប្រធាន>ពេទ្យ ឬក៏ក្រោយពេលដែលគេតែងតាំង<>លោក<>?

**ឆ៖** ការចាក់ថ្នាំនេះ គឺខ្ញុំបាទចេះចាក់ថ្នាំតាំងពីខ្ញុំបាទនៅក្មេងម្ល៉េះ នៅកំលោះ គឺចាក់ថ្នាំឲ្យប្រពន្ធខ្ញុំ ឲ្យម៉ែខ្ញុំ ឲ្យឪខ្ញុំអ៊ីចឹងកាលនៅកំលោះ។ ចេះចាក់ថ្នាំនាយអាយបន្តិចបន្តួច ឈឺតិចតួច ឈឺគ្រាន់ក្តៅអី ចាក់ថ្នាំ ឲ្យថ្នាំគ្រាប់ហ្នឹង។

**ស៖** អ្នកបង្រៀនដែលឈ្មោះ ស៊ី ហ្នឹងជាប្រធានមន្ទីរពេទ្យតំបន់។ តើ ស៊ី ហ្នឹងជាមនុស្សដែលលោកហៅថា ឫស្សី ហ្នឹងមែនទេ? ជាពិសេសនៅពេលដែលលោកសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺលេខ D313/1.2.410, ERN 00752106។ លោកបានបញ្ជាក់ថា ឫស្សី ជាអតីតគ្រូពេទ្យនៅមន្ទីរពេទ្យព្រះកេតុមាលានៅភ្នំពេញ។ ហើយគាត់រត់គេចទៅជាមួយលោក ខៀវ សំផន។ អ៊ីចឹងខ្ញុំចង់ដឹងថាតើ ស៊ី ហ្នឹងជាមនុស្សតែមួយនឹង ឫស្សី នេះមែនទេ?

**ឆ៖** បាទ មិនមែនឫស្សីទេ ឫស្សីគឺព្រៃឫស្សី។ ហើយ សី នេះគឺឈ្មោះមនុស្ស ដែលជាប្រធានពេទ្យតំបន់។

**ស៖** អ៊ីចឹងប្រធានមន្ទីរពេទ្យថ្នាក់តំបន់ហ្នឹងធ្លាប់ធ្វើពេទ្យនៅពេទ្យព្រះកេតុមាលា<> ហើយ <តើ>គាត់<>រត់គេច<ទៅ>ជាមួយលោក ខៀវ សំផន ទេ?

**ឆ៖** នេះបើតាមខ្ញុំដឹង ថាគាត់ធ្លាប់ធ្វើពេទ្យនៅមន្ទីរពេទ្យព្រះកេតុមាលាហ្នឹង នេះខ្ញុំមិនដឹងផ្ទាល់ ឃើញផ្ទាល់ទេ គឺគេប្រាប់ថាអ៊ីចឹង ថាគាត់ហ្នឹងជាបុគ្គលិកពេទ្យនៅមន្ទីរពេទ្យព្រះកេតុមាលា ប៉ុន្តែដល់ក្រោយមក ក៏បានមករួមសកម្មភាពជាមួយលោក ខៀវ សំផន។

[០៩:៣៧:១៧]

**ស៖** <តើគាត់ធ្វើអ្វីជាមួយ ខៀវ សំផន?> ខ្ញុំអត់<>យល់<ថាគាត់ធ្វើសកម្មភាពអ្វីជាមួយលោក ខៀវ សំផន នោះ>?

**ឆ៖** បាទ កាលនោះលោក ខៀវ សំផន ឮតែឈ្មោះមិនដឹងនៅឯណា ប៉ុន្តែថារត់ពេទ្យ សី ហ្នឹង រត់មកហ្នឹង គឺរត់ចូលព្រៃជាមួយនឹងលោក ខៀវ សំផន អាហ្នឹងខ្ញុំមិនឃើញ ប៉ុន្តែគេថាអ៊ីចឹង។ គាត់រត់ពីភ្នំពេញហ្នឹងមក រត់មកចូលរួមសកម្មភាពជាមួយលោក ខៀវ សំផន។

**ស៖** លោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ នៅពេលណាដែរ ដែលគាត់រត់ហ្នឹង? <តើវាកើតឡើង>មុន ៧៥ <តើ>នៅឆ្នាំ៧៩ លោកចង់និយាយឆ្នាំ<ណាឲ្យប្រាកដនោះ>?

**ឆ៖** បាទ មុន១ឆ្នាំរត់គេចតាំងមុនឆ្នាំរដ្ឋប្រហារ រត់ចេញពីភ្នំពេញហ្នឹង។

**ស៖** ក្រោយថ្ងៃទី១៧ <ខែមេសា ឆ្នាំ១៩៧៥> នៅពេលដែល សី <ឡើង>ធ្វើជាប្រធានមន្ទីរពេទ្យតំបន់<។ តើលោកដឹងទេ>ក្រោយពីហ្នឹងមក <>គាត់ធ្វើអីទៀត? <តើ>គាត់ត្រឡប់មកភ្នំពេញវិញ<ដែរឬទេ>?

**ឆ៖** ពេល១ សី ទៅបាត់ នៅ១ប្រពន្ធគាត់គ្រប់គ្រងពេទ្យ។ គាត់ទៅរៀនពេទ្យបន្តនៅភ្នំពេញរហូតទៅដល់មិនដឹងថាខ្ញុំមិនដឹងថាទៅរៀនប៉ុន្មានខែទេ ប៉ុន្តែប្រពន្ធនៅគ្រប់គ្រងពេទ្យហ្នឹងមានបញ្ហា ដឹងបញ្ហាអីទៀត ខ្ញុំមិនបានដឹងច្បាស់ទេ ក៏ប្រពន្ធហ្នឹងបាត់ខ្លួនទៅ មិនដឹងទៅណាបាត់ទៅ ខ្ញុំអត់ដឹង។ ហើយដល់ សី ហ្នឹងត្រឡប់ពីរៀនមកវិញ ក៏លែងបាននៅធ្វើប្រធានពេទ្យហ្នឹងហើយ បានទៅនៅភ្នំ អ៎! ទៅនៅឯខេត្តតាកែវ នៅតំបន់ មិនដឹងនៅណា ខ្ញុំអត់ដឹងដែរ។ ប៉ុន្តែទៅនៅហ្នឹង បើតាមព័ត៌មានថាអត់មានធ្វើអីទេ នៅស្ងៀម។ ហើយប្រពន្ធគាត់ហ្នឹងទៅបាត់ហើយ មិនដឹងទៅឯណា ខ្ញុំអត់ដឹង។

[០៩:៤០:២១]

**ស៖** លោកដឹងទេថា នៅពេល សី នៅភ្នំពេញហ្នឹង គាត់<ក្លាយជាប្រធាន>មន្ទីរពេទ្យមួយឈ្មោះ មន្ទីរពេទ្យ១៧មេសា <ដែរឬ>ទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ អត់ដឹងថាគាត់ដឹកនាំអីទេ គ្រាន់តែដឹងថាគាត់ធ្វើពេទ្យនៅកន្លែងពេទ្យព្រះកេតុមាលាហ្នឹង កាលនោះ។

**ស៖** ឥឡូវនេះយើងនិយាយអំពីមន្ទីរពេទ្យនៅស្រុកត្រាំកក់ ខ្ញុំចង់បានការបំភ្លឺពីលោក។ តើនៅស្រុកត្រាំកក់<>មានមន្ទីរពេទ្យ<ទាំងអស់>ប៉ុន្មាន? <ខ្ញុំមិននិយាយពីតែ>មន្ទីរពេទ្យស្រុក១០៥<តែមួយប៉ុណ្ណោះទេ គឺខ្ញុំសំដៅលើមន្ទីរពេទ្យទាំងអស់នៅក្នុងស្រុកទាំងមូល។ ខ្ញុំដឹងថា>មន្ទីរពេទ្យ<ស្រុក១០៥>នេះស្ថិតនៅភូមិជិតភូមិត្រពាំង<ស្វាយ នៅក្នុង>វត្តត្រពាំងគល់ <ក្នុង>ឃុំត្រពាំង<ធំខាងជើង។ តើ<ត្រឹម>ត្រូវទេ?

**ឆ៖** បាទ មន្ទីរពេទ្យនេះស្ថិតនៅក្នុងភូមិត្រពាំងស្វាយ ឃុំត្រពាំងធំខាងជើង។ ត្រឹមត្រូវហើយអំមិញ គ្រាន់មិនសូវច្បាស់។

**ស៖** សូមអភ័យទោសចំពោះការអានមិនត្រូវនេះ។ មន្ទីរពេទ្យ២២ លោកថា ជាមន្ទីរពេទ្យយោធា ជាមន្ទីរពេទ្យដែលស្ថិតនៅក្រោមតំបន់។ អ៊ីចឹងមន្ទីរពេទ្យហ្នឹងនៅក្នុងស្រុកត្រាំកក់ ឬ<ក៏អត់ទេ>?

**ឆ៖** បាទ មន្ទីរពេទ្យហ្នឹងនៅក្នុងស្រុកត្រាំកក់ នៅក្នុងភូមិព្រៃ -- ភូមិពោធិ៍ដុះ ឃុំត្រពាំងធំខាងជើង។

[០៩:៤២:៣៧]

**ស៖** អ៊ីចឹងគឺមន្ទីរហ្នឹងជាមន្ទីរពេទ្យយោធា ហើយស្ថិតនៅ<ចំណុះឲ្យ>តំបន់ អ៊ីចឹងមែនទេ?

**ឆ៖** បាទ កាលណោះ ខ្ញុំមិនដឹងថា តំបន់ ឬក៏ភូមិភាគទេ ប៉ុន្តែប្រជាជនអត់មានចូលទៅទេ គឺពេទ្យហ្នឹងសម្រាប់តែយោធាទាំងអស់តែម្តង។ សូម្បីតែអ្នកភូមិនៅជិតហ្នឹងក៏អត់ហ៊ាន ទៅ ឈឺថ្កាត់អីអត់ហ៊ានទៅជិតពេទ្យហ្នឹង។

**ស៖** នៅពេលមានប្រជុំនៅថ្នាក់ស្រុក តើមានតំណាងមន្ទីរពេទ្យ២២ មកចូលរួមនៅក្នុងកិច្ចប្រជុំហ្នឹងទេ?

**ឆ៖** នៅប្រជុំថ្នាក់ស្រុក អត់មានតំណាងពេទ្យ២២ហ្នឹងមកចូលរួមទេ ព្រោះប្រជុំតែស្រុក។

**ស៖** ខ្ញុំដឹងផងដែរថា មានមន្ទីរពេទ្យតំបន់<មួយផ្សេងទៀត>ស្ថិតក្នុង<ឃុំ>ដើមចំបក់។ អ៊ីចឹង តើ<ឃុំហ្នឹង>ស្ថិតនៅក្នុងស្រុកត្រាំកក់ដែរមែនទេ ឃុំហ្នឹង?

**ឆ៖** បាទ មិនមែនឃុំដើមចំបក់ទេ គឺសាលារៀន សាលាដើមចំបក់ នៅក្នុងស្រុកត្រាំកក់ដែរ។ មន្ទីរពេទ្យហ្នឹងជាមន្ទីរពេទ្យតំបន់១៣ហ្នឹង តំបន់តាកែវ ខេត្តតាកែវ។

**ស៖** ដូច្នេះ តំបន់១៣ហ្នឹង <>មានមន្ទីរពេទ្យនៅ<ស្រុកត្រាំកក់>។ អ៊ីចឹង តើ<នរណាអាចចូលសម្រាក>ព្យាបាលនៅមន្ទីរពេទ្យតំបន់១៣ហ្នឹង<បាន>?

[០៩:៤៥:៥៨]

**ឆ៖** បាទ មន្ទីរៗពេទ្យនៅដើមចំបក់ហ្នឹង គឺសម្រាប់ទទួលអ្នកជំងឺពីមកពីស្រុកផ្សេងៗដែលបញ្ជូនមក ដែលពេទ្យស្រុកមិនអាចព្យាបាលបាន ក៏បញ្ជូនមកពេទ្យហ្នឹង ធ្ងន់ៗ។

**ស៖** ដូច្នេះ<តាមពិតទៅ អ្នកជំងឺអាចបញ្ជូនទៅពេទ្យស្រុកក៏បាន ពេទ្យតំបន់ក៏បានទៅតាមសភាពធ្ងន់ធ្ងរ>របស់អ្នកជំងឺ<>។ <តើខ្ញុំយល់>អ៊ីចឹង<ត្រឹមត្រូវដែរឬ>ទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** តើប្រជាជន១៧មេសា អាច<>គេបញ្ជូនទៅមន្ទីរពេទ្យតំបន់<បាន>ដែរឬទេ ឬក៏បាន<>ទៅត្រឹមតែមន្ទីរពេទ្យស្រុក<>?

**ឆ៖** បាទ កាលនោះ អ្នកជំងឺមិនគិតថា អ្នកថ្មី ឬអ្នកចាស់នៅមូលដ្ឋានទេ គឺឱ្យតែឈឺ បញ្ជូន -- ឈឺខ្លាំងបញ្ជូនទៅពេទ្យតំបន់ទាំងអស់។

**ស៖** តើមន្ទីរពេទ្យតំបន់ <>និងមន្ទីរពេទ្យស្រុកមានបុគ្គលិកដូចគ្នា<> ឬក៏មន្ទីរពេទ្យតំបន់មានវេជ្ជបណ្ឌិត<ឆ្លងកាត់ការបណ្តុះបណ្តាល និងប្រកបដោយគុណវុឌ្ឍិ> ច្រើនជាងពេទ្យនៅស្រុក <មែនដែរឬទេ>?

[០៩:៤៧:១៧]

**ឆ៖** បាទ នៅពេទ្យតំបន់ បច្ចេកទេសព្យាបាលអ្នកជំងឺគឺចេះច្រើនដឹងច្រើនជាងនៅពេទ្យស្រុក។

**ស៖** តើ<មានការវះកាត់>នៅមន្ទីរពេទ្យ<តំបន់>ដែរឬទេ?

**ឆ៖** បាទ នៅពេទ្យស្រុកអត់មានវះកាត់ទេ។ នៅពេទ្យតំបន់មានវះកាត់តិចតួចហ្នឹងមិនច្រើនទេ។

**ស៖** នៅក្នុងចំណោមបុគ្គលិកពេទ្យតំបន់ តើមានអ្នកដែលទទួលការបណ្តុះបណ្តាលវេជ្ជសាស្ត្រ

ក្រៅពីការ<ការ>បណ្តុះបណ្តាលរយៈពេលពីរបីសប្តាហ៍ហ្នឹង<ដែរឬទេ>? ខ្ញុំចង់និយាយពីទទួលការបណ្តុះបណ្តាលរយៈពេលវែងជា ក្នុងឋានៈជាវេជ្ជបណ្ឌិត។ តើមានវេជ្ជបណ្ឌិត<ដែលមានវិជ្ជាជីវៈ>មុនថ្ងៃ១៧ <ខែមេសា> ឆ្នាំ១៩៧៥ ទៅធ្វើការនៅក្នុងមន្ទីរពេទ្យហ្នឹងដែរឬទេ?

**ឆ៖** បាទ គ្មានទេ មានតែពេទ្យ សី មួយហ្នឹង។

**ស៖** តើ សែន ហ្នឹងអ្នកណាគេដែរ?

**ឆ៖** ពេទ្យសីៗ ហ្នឹងជាប្រធានពេទ្យតំបន់មួយទៀតដែរ នៅត្រពាំងរនាបក្នុងឃុំត្រាំកក់បច្ចុប្បន្ន។

**ស៖** បាទ ខ្ញុំសូមអរគុណ។ អម្បាញ់មិញ ខ្ញុំស្តាប់ឮមិនច្បាស់។ ឥឡូវ ខ្ញុំសូមចូលមកនិយាយអំពីមន្ទីរពេទ្យនៅតាមឃុំវិញម្តង។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថានៅតាមឃុំនីមួយៗមានមន្ទីរពេទ្យ ឬក៏ហៅថាមជ្ឈមណ្ឌលសុខភាព <ប្រសិនបើមាន> តើ<នរណា>ជា<អ្នកគ្រប់គ្រង>មន្ទីរពេទ្យ<>ឃុំ<នោះ>?

[០៩:៥០:១២]

**ឆ៖** បាទ នៅតាមឃុំមានបុគ្គលិកពេទ្យហ្នឹង ឃុំខ្លះមានប្រាំនាក់ ឃុំខ្លះមានប្រាំពីរនាក់។ អ៊ីចឹងអ្នកចែកថ្នាំ អ្នកដែលទទួលខុសត្រូវ គឺបុគ្គលិកពេទ្យម្នាក់ណាដែលយើងមើលទៅឃើញថា ចេះដឹងគួរសមក៏យើងចាត់តាំងឲ្យគេធ្វើប្រធាននៅក្នុងឃុំនោះ។

**ស៖** តើមន្ទីរពេទ្យតាមឃុំនេះ នៅក្រោមឱវាទមន្ទីរពេទ្យស្រុកដែរឬទេ? តើលោកក្នុងឋានៈលោកជា<ប្រធាន ឬ>អនុប្រធានមន្ទីរស្រុក <តើ>លោកគ្រប់គ្រង<ឬតាមដាន>មន្ទីរពេទ្យនៅតាមឃុំដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទគ្រប់គ្រងពេទ្យឃុំទាំង១២ឃុំហ្នឹងៗ គឺខ្ញុំបានគ្រប់គ្រង ហើយនិងមេឃុំគេក៏គ្រប់គ្រងពីលើហ្នឹងដែរ។

**ស៖** លោកគ្រប់គ្រងមន្ទីរពេទ្យ<>ឃុំទាំងអស់<ដែលនៅក្នុងស្រុកទាំងមូល> ឬក៏<គ្រាន់>តែ<គ្រប់គ្រង>មន្ទីរពេទ្យដែល<ស្ថិត>នៅក្នុងឃុំ<ជាមួយ>មន្ទីរពេទ្យស្រុក<តែប៉ុណ្ណោះ>ទេ?

[០៩:៥២:០៥]

**ឆ៖** បាទ ខ្ញុំបានគ្រប់គ្រងមន្ទីរពេទ្យឃុំទាំងអស់ទូទាំងស្រុក។

**ស៖** អ៊ីចឹងខ្ញុំសន្មតថា លោកបានទៅពិនិត្យពេទ្យតាមឃុំទាំងអស់ហ្នឹង តើលោកអាចជម្រាប

ជូនតុលាការបានដែរឬទេ តើស្ថានភាពមន្ទីរពេទ្យតាមឃុំនោះយ៉ាងម៉េចដែរ? ពីឃុំមួយទៅឃុំមួយស្ថានភាពហ្នឹងខុសគ្នា<ដែរឬទេ?> តើលោក<ជាអ្នក>ទទួលបន្ទុកខាងចែក<ចាយឱសថ>ទៅតាមមន្ទីរពេទ្យតាមឃុំទាំងអស់ហ្នឹង<ដែរឬទេ>?

**ឆ៖** បាទ ខ្ញុំបានមានតួនាទីចែកថ្នាំទៅពេទ្យឃុំទាំងអស់ហ្នឹង ហើយមានតួនាទីទៅពិនិត្យមើលម្ដងម្កាល អ្នកជំងឺនៅតាមឃុំហ្នឹង ក្រែងមានអ្នកជំងឺស្រាលៗហ្នឹងក៏ជួយចែកថ្នាំអីណាដែលមានត្រូវនឹងជំងឺហ្នឹង ក៏ចែកទៅ ហើយអ្នកណាដែលមានជំងឺខ្លាំងបន្តិចហ្នឹង ឲ្យបញ្ជូនមកពេទ្យស្រុកមក។

**សៈ** តើមានអ្នកជំងឺដែលស្លាប់នៅតាមមន្ទីរពេទ្យឃុំទាំងនេះដែរឬទេ? តើស្ថានភាពនោះ គ្រប់មន្ទីរពេទ្យឃុំទាំងអស់ហ្នឹងដូចគ្នាទេ? <>

**ឆ៖** បាទ ស្ថានភាពអ្នកជំងឺនៅគ្រប់ឃុំដូចគ្នា ព្រោះពេទ្យឃុំមិនមានទុកអ្នកជំងឺធ្ងន់នៅកន្លែងនោះទេ។ ប៉ុន្តែមានស្លាប់នៅពេទ្យឃុំដោយសារនៅការដ្ឋានអ្នកជំងឺមកពីកន្លែងធ្វើការ ពីការដ្ឋានហ្នឹងខ្លាំងពេក មកដល់ពេទ្យមើលមិនទាន់ក៏ស្លាប់ទៅ ហើយបើគេមើលទាន់ ហើយថាធ្ងន់ធ្ងរគេបញ្ជូនមកពេទ្យស្រុក។

[០៩:៥៤:៤៥]

**សៈ** ដើម្បី<ចូល>ទៅ<សម្រាកព្យាបាលនៅ>មន្ទីរពេទ្យឃុំបាន ឬក៏ទៅ<សម្រាកព្យាបាលនៅ>មន្ទីរពេទ្យស្រុកបាន។ តើអ្នកជំងឺត្រូវទទួលបានលិខិតអនុញ្ញាត<ពីអាជ្ញាធរដែរឬទេ? តើគេតម្រូវឲ្យមាន>លិខិតណែនាំណាមួយដើម្បីឲ្យមន្ទីរពេទ្យទទួលពួកគាត់<ដែរ>ឬ<ទេ>?

**ឆ៖** បាទ គឺសិទ្ធិ -- លោកចៅហ្វាយស្រុកលោកឲ្យសិទ្ធិទទួលអ្នកជំងឺមកពីឃុំ។ កាលណាឃុំបញ្ជូនមក គឺឲ្យពេទ្យស្រុកហ្នឹងមានសិទ្ធិទទួលអ្នកជំងឺហ្នឹង។

**សៈ** អ៊ីចឹង គឺថាត្រូវមានលិខិតអនុញ្ញាតរបស់ចៅហ្វាយស្រុក ដើម្បីអាចចូលទៅ<សម្រាកព្យាបាលនៅ>មន្ទីរពេទ្យស្រុកបាន<។ តើខ្ញុំយល់បែបនេះត្រឹមត្រូវដែរឬទេ>?

**ឆ៖** បាទ អ្នកជំងឺគឺគេឲ្យសិទ្ធិពេទ្យឃុំហ្នឹង គឺបើកាលណាខ្លាំងពេក ហើយថាមើលមិនបាន ឲ្យបញ្ជូនមកពេទ្យស្រុក អត់បាច់មានសំបុត្រពីចៅហ្វាយស្រុកទេ។

[០៩:៥៦:១៤]

**សៈ** <>ដើម្បីឲ្យអាចចូល<សម្រាកព្យាបាលនៅ>មន្ទីរពេទ្យឃុំបាននោះ តើ<ចាំបាច់>ត្រូវមានការអនុញ្ញាត<ពីអាជ្ញាធរដែរឬទេ>? ឬក៏អ្នកណាក៏អាចមានសិទ្ធិចូលមកសុំការព្យាបាលនៅមន្ទីរ

ពេទ្យតាមឃុំ<ឈឺអីក៏ដោយ និងនៅពេលណាក៏>បាន<មែនដែរឬទេ>?

**ឆ៖** បាទ អ្នកជំងឺដែលត្រូវចូលមកពេទ្យឃុំបាន លុះត្រាណាដែលមេភូមិ ឬប្រធានកង អនុញ្ញាតឲ្យមកបានបាន។

**ស៖** តើ<>ប្រធានកង <ឬប្រធានភូមិ>វាយតម្លៃលើភាពធ្ងន់ធ្ងរនៃសុខភាព <ឬស្ថានភាពសុខភាព>របស់អ្នកជំងឺយ៉ាង<ដូចម្ដេចដែរ>?<>

**ឆ៖** តាមពិតទៅគាត់អត់ដឹងថា ឈឺស្រាល ឬធ្ងន់ទេ ប៉ុន្តែឃើញអ្នកជំងឺឈឺហើយ ត្រូវតែឲ្យយកមកភ្លាម។ អង្កាល់នោះគ្មានអីដឹកទេ សែងនឹងអង្រឹងបើដើរមិនរួច ប៉ុន្តែអ្នកជំងឺដើររួច ឲ្យដើរមកខ្លួនឯង មកពេទ្យឃុំមក។

**ស៖** បាទ លោកបានឆ្លើយផងដែរនៅក្នុងកិច្ចសម្ភាសន៍របស់លោក<ជាមួយ>មជ្ឈមណ្ឌលឯកសារកម្ពុជាគឺថាឯកសារ <D313/1.2.410>។ លោកនិយាយថា អ្នកជំងឺមួយចំនួនត្រូវបានបញ្ជូនមកទីក្រុងភ្នំពេញ ហើយលោកបាន<>ជូន<>អ្នកជំងឺមួយចំនួនផងដែរ។ តើលោក<អាចបញ្ជាក់ចំណុចនេះបាន>ដែរឬទេ?

[០៩:៥៨:១៨]

**ឆ៖** បាទ ខ្ញុំបាទនៅរក្សាចម្លើយនេះដដែល។ កាលណោះខ្ញុំ -- កាលណោះនៅមន្ទីរពេទ្យមានអ្នកជំងឺប្រហែលជាជិត១០នាក់ រាករូសខ្លាំងពេក ឲ្យថ្នាំមិនបាត់ ខ្ញុំដឹកតាមរថយន្ត ខ្ញុំមានរថយន្តមួយរ៉ុលវ៉ាហ្កែន អារ៉ុលវ៉ាហ្កែនហ្វាមីល្យាំងហ្នឹង ដឹកយកមកពេទ្យដើមចំបក់។

**ស៖** ប៉ុន្តែមន្ទីរពេទ្យនៅដើមចំបក់ហ្នឹងមិនមែនជាមន្ទីរពេទ្យភ្នំពេញទេ។ តើលោកធ្លាប់បានជូន<>អ្នកជំងឺមួយចំនួនមកទីក្រុងភ្នំពេញដែរឬទ?

**ឆ៖** បាទ មានកាលអង្កាល់ដែលខ្ញុំដឹកអ្នកជំងឺហ្នឹងមក រាករូសហ្នឹងមក មកដល់ពេទ្យហ្នឹងពេទ្យដើមចំបក់ហ្នឹង ពេទ្យដើមចំបក់ថាកុំនៅព្យាបាលនៅពេទ្យនេះអី យកទៅភ្នំពេញ។ ហើយក៏គាត់ផ្ញើអ្នកជំងឺ អ្នករាករូសហ្នឹងបីបួនប្រាំនាក់ថែមទៀតឡានហ្នឹងមកភ្នំពេញ។ មកកាលហ្នឹងមកពេទ្យរុស្ស៊ី នៅពេទ្យរុស្ស៊ីសព្វថ្ងៃហ្នឹង មកពេទ្យរុស្ស៊ីហ្នឹង។

[១០:០០:០៣]

**ស៖** អ៊ីចឹងដើម្បីអាចផ្ទេរមកភ្នំពេញបាន ត្រូវតែមានការ<សម្រេចចិត្ត>ពីតំបន់ ឬក៏ពីភូមិភាគ<ដែរឬទេ?> ឬក៏លោកផ្ទាល់នេះ លោកអាចសម្រេចបញ្ជូនអ្នកជំងឺមកភ្នំពេញដោយខ្លួនឯង?

**ឆ៖** បាទ ខ្ញុំបាទ មិនមានសិទ្ធិបញ្ជូនដោយខ្លួនឯងទេ គឺអម្បាញ់មិញ ខ្ញុំឆ្លើយថា ខ្ញុំដឹកអ្នកជំងឺមកៗដល់ប្រធានពេទ្យតំបន់ហ្នឹងប្រាប់ថា ឱ្យយកទៅភ្នំពេញ គាត់សរសេរសំបុត្រមួយឱ្យមក ហើយគាត់ផ្ញើអ្នកជំងឺឈ្មោះ អ្នកជំងឺហ្នឹងក្នុងសំបុត្រហ្នឹង ហើយខ្ញុំទៅយកទៅភ្នំពេញ។

**សៈ** ហើយអ្នកដែលទៅភ្នំពេញនោះ គាត់ជាប្រជាជនចាស់ ឬក៏ប្រជាជន១៧មេសា?

**ឆ៖** បាទ មានប្រជាជនចាស់ខ្លះ ប្រជាជន១៧មេសាខ្លះ មានស្រីខ្លះ មានប្រុសខ្លះ។ ភ្លេច ខ្ញុំភ្លេចអស់ហើយមិនដឹងស្រីប៉ុន្មាន ប្រុសប៉ុន្មានអត់ដឹង ភ្លេច។

**សៈ** តើនៅភ្នំពេញមានវេជ្ជបណ្ឌិតមានបទពិសោធន៍ច្រើនជាងនៅមន្ទីរពេទ្យស្រុក ហើយនិងមន្ទីរពេទ្យតំបន់ដែរឬទេ? តើកម្រិតនៃការព្យាបាលនោះខុសគ្នា ហើយបើខុសនោះ ខុសត្រង់ណា?

**ឆ៖** ខ្ញុំបាទមិនដឹងច្បាស់ទេពីការបច្ចេកទេសព្យាបាល ហើយនិងកម្រិតយល់ដឹងពីមន្ទីរពេទ្យនៅភ្នំពេញគឺខ្ញុំអត់ដឹងទេ។ គ្រាន់តែយកអ្នកជំងឺទៅដល់ ហើយសែងអ្នកជំងឺដាក់ទៅក្នុងពេទ្យអស់ហើយ ក៏ត្រឡប់មកវិញ តែប៉ុណ្ណឹងទេ អត់ដឹងថាមានវេជ្ជបណ្ឌិតអី អត់ដឹងទេ។

[១០:០២:៣០]

**សៈ** <អ៊ីចឹង>នៅភ្នំពេញ<> លោកមិនដែលបានជួបវេជ្ជបណ្ឌិតទេ<មែនដែរឬទេ?> ពេលដែលលោកយកអ្នកជំងឺទៅ ភ្នំពេញ<ហើយ លោកត្រូវទុកអ្នកជំងឺជាមួយនរណាម្នាក់។ តើលោកទុកអ្នកជំងឺនោះជាមួយនរណា?> <តើ>លោកមានសរសេររបាយការណ៍<>ពី<ស្ថានភាព>ជំងឺរបស់<អ្នកជំងឺឱ្យគេបានដឹង>ទេ?

**ឆ៖** បាទ មានលិខិត។ ខ្ញុំបញ្ជូនអ្នកជំងឺពីស្រុកមក មានលិខិតមួយ មកតំបន់ អមជាមួយពេទ្យតំបន់ហ្នឹងគេសរសេរសំបុត្រមួយឱ្យមកភ្នំពេញហ្នឹងមកប្រគល់ឱ្យពេទ្យអ្នកដែលគេរត់មកទទួលអ្នកជំងឺហ្នឹងប្រគល់ឱ្យពេទ្យហ្នឹងទៅ ហើយយើងត្រឡប់មកផ្ទះវិញ។

**សៈ** តើលោក<ប្រគល់អ្នក>ជំងឺ <និងរបាយការណ៍ជំងឺ? តើលោកប្រគល់ពួកគេឱ្យទៅយោធា ឬតើលោកប្រគល់អ្នកជំងឺឱ្យ>ទៅវេជ្ជបណ្ឌិត ឬក៏ទៅ គិលានុបដ្ឋាយិកា<>?

**ឆ៖** បាទ ពេលឡានដឹកអ្នកជំងឺទៅដល់មានបុគ្គលិកពេទ្យរត់ចុះមកទទួលអ្នកជំងឺ។ ភាគច្រើនបុគ្គលិកពេទ្យនោះសុទ្ធតែស្រីៗ ជួយសែងអ្នកជំងឺ។ ហើយខ្ញុំប្រគល់ឱ្យពេទ្យហ្នឹងមិនដឹងពេទ្យមួយណាប្រធានអី អត់ដឹងទេ ព្រោះច្រើនរត់មកទទួលអ្នករាកហ្នឹងវាច្រើនណាស់។ អាខ្លះរត់ចេញ អាខ្លះរត់ចូល។

**សៈ** តើនៅក្នុងមន្ទីរពេទ្យទាំងអស់នោះ មានគិលានុបដ្ឋាយិកាដែលទទួលការបណ្តុះបណ្តាលនៅក្នុងស្រុកត្រាំកក់ដែរឬទេ?

**ផៈ** បាទ គ្មានទេ។

[១០:០៥:០៣]

**សៈ** ប្រហែលជាលោកមិនយល់សំណួរខ្ញុំទេ។ សំណួរខ្ញុំអម្បាញ់មិញនេះ ខ្ញុំចង់ដឹងថា <តើ> គិលានុបដ្ឋាយិកាដែលធ្វើការនៅភ្នំពេញនោះ<មាននរណាមកពីមន្ទីរពេទ្យនៅក្នុងស្រុកត្រាំកក់ដែរឬទេ? សំណួររបស់ខ្ញុំមិនចង់ដឹងថាតើពួកគេទទួលបានការបណ្តុះបណ្តាលបានល្អ ឬអត់នោះទេ ខ្ញុំគ្រាន់តែចង់ដឹងថា តើមាន>គិលានុបដ្ឋាយិកាដែលនៅភ្នំពេញ មានអ្នកដែលមកពីស្រុកត្រាំកក់ដែរឬទេ មកធ្វើការនៅមន្ទីរពេទ្យនៅក្រុងភ្នំពេញនេះ?

**ផៈ** ខ្ញុំបាទមិនដឹងទេ មិនដឹងថាមាន ឬមិនមានទេ ប៉ុន្តែកាលដែលខ្ញុំដឹកអ្នកជំងឺទៅដល់ហ្នឹងពេទ្យហ្នឹងចុះមក រត់មកទទួលហ្នឹង គឺគ្មានទេ គ្មានអ្នកស្រុកត្រាំកក់ទេ បួនប្រាំប្រាំមួយប្រាំពីរនាក់ហ្នឹងគឺមិនដឹង អត់ដឹងទេ។

**សៈ** តើលោក<ជាអ្នក>ទទួលរបាយការណ៍<ពី>មន្ទីរពេទ្យតាមឃុំ <ហើយតើ>លោកខ្លួនឯងផ្ទាល់<ជាអ្នក>សរសេររបាយការណ៍ជូនទៅមន្ទីរពេទ្យតំបន់ដែរឬទេ?

**ផៈ** ខ្ញុំបាទពេទ្យតាមឃុំធ្វើរបាយការណ៍មក ហើយខ្ញុំបាទនឹងទៅរាយការណ៍ឲ្យមន្ទីរពេទ្យតំបន់ពីបញ្ជីអ្នកជំងឺឈឺ ប្រភេទជំងឺដែលប្រជាជនឈឺ គឺខ្ញុំបាទផ្ទាល់ជាអ្នករាយការណ៍ឲ្យពេទ្យតំបន់។

**សៈ** តើធ្វើរបាយការណ៍ហ្នឹង<ញឹកញាប់ដែរឬទេ? តើលោកសរសេររបាយការណ៍រៀងរាល់> សប្តាហ៍ <ឬរៀងរាល់ខែ?> តើ<លោកលើកឡើងពីចំនួនអ្នកជំងឺទទួលឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យ ចំនួន>អ្នកជំងឺដែល<អនុញ្ញាតឲ្យ>ចេញពីមន្ទីរពេទ្យ <ឬ>ចំនួនអ្នក<ជំងឺ>ដែល<បាន>ស្លាប់នៅក្នុងមន្ទីរពេទ្យដែរឬទេ?

**ផៈ** តាមពិតទៅ ខ្ញុំបាទធ្វើពេទ្យ២ឆ្នាំប្លាយ អត់ដែលធ្វើរបាយការណ៍ពីអ្នកជំងឺចេញ និងអ្នកជំងឺចូល អ្នកជំងឺឈឺ និងអ្នកស្លាប់ គឺអត់ដែលធ្វើនឹងក្រដាស់ទេ គឺទៅរាយការណ៍មាត់ទទេ។

[១០:០៧:៤៨]

**សៈ** តើលោករាយការណ៍ដោយផ្ទាល់មាត់ទៅមេរបស់លោក អំពីចំនួនអ្នកជំងឺដែលស្លាប់នៅមន្ទីរពេទ្យដែរឬទេ? <តើលោក>រាយការណ៍<បែបនេះញឹកញាប់ដែរឬទេ>?

**ឆ៖** បាទ ១ខែម្តង។

**ស៖** ដូច្នេះ<រាល់ព័ត៌មានទាំងអស់ត្រូវ>លោករាយការណ៍ទៅថ្នាក់លើ តើលោកដឹងដែរឬទេថាតើថ្នាក់លើ<របស់លោកបាន>រាយការណ៍បន្តទៅថ្នាក់ភូមិភាគ ឬក៏ទៅថ្នាក់ជាតិដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ។ អត់ដឹងថាគេរាយការណ៍ទៅលើទៀតអីយ៉ាងម៉េច គឺអត់ដឹង។

**ស៖** ផ្ទុយទៅវិញ<តើ>លោកធ្លាប់ទទួល<ការណែនាំ>ពីថ្នាក់លើ<របស់លោកដែរឬទេ?> នៅក្នុងកំណត់ហេតុ<នៃការ>ស្តាប់ចម្លើយរបស់លោក<> លោក<និយាយ>ថារាល់ពេលប្រជុំ<ម្តងៗ> លោកត្រូវពិភាក្សាអំពី<>ផែនការសកម្មភាព ហើយលោកទទួលផែនការ<នោះ>។ ខ្ញុំសួរថា តើ<លោក>ទទួល<ផែនការ>សកម្មភាព<នោះ>ពី<នរណា ហើយតើខ្លឹមសារនៃផែនការសកម្មភាពនោះមានអ្វីខ្លះ>? <តើវាគឺជាការណែនាំអំពីផ្នែកសុខាភិបាលស្អាតស្អំ ឬក៏និយាយពី>នយោបាយដែរ?

**ឆ៖** បាទ គឺគេណែនាំមិនមែនផ្នែកនយោបាយទេ គឺគេណែនាំតែផ្នែកការព្យាបាលជំងឺ ឲ្យថ្នាំអ្នកជំងឺ ប្រភេទជំងឺ និងការធ្វើថ្នាំបុរាណ។ តែប៉ុណ្ណឹង អត់មាននិយាយពីរឿងនយោបាយទេ។

[១០:១០:២៦]

**ស៖** ហើយយើងនឹងត្រឡប់មកនិយាយពីចំណុចនេះពេលក្រោយទៀត។ លោកក៏បានឆ្លើយផងដែរនៅក្នុងកំណត់ហេតុ<នៃការ>ស្តាប់ចម្លើយរបស់លោកថាលោក ថាពីដំបូងនោះ លោកជាអនុប្រធានមន្ទីរស្រុក ហើយ<តែងតែ>មានមនុស្សម្នាក់ដែលជាប្រធានពេទ្យស្រុកហ្នឹង គឺជាមនុស្ស<នារី>។ <លោកនិយាយពី>ឈ្មោះ ម៉េត, ឈ្មោះ យ៉ា និង នារីនាង។ តើលោកអាចជម្រាបជូន<អង្គជំនុំជម្រះ>បានទេថាតើ<ការបែងចែកភារកិច្ច>រវាងលោក <>និងនារីទាំងអស់<នោះ>ដែល<ទទួលបានការចាត់តាំងជាប្រធានមន្ទីរពេទ្យ>ជា<>ផ្លូវការនោះ<យ៉ាងដូចម្តេចដែរ>?

**ឆ៖** បាទ ធាតុពិតទៅ កាលនុ៎ងខ្ញុំបើតាមខ្ញុំយោបល់មើលគឺនារីពេទ្យជាប្រធានហ្នឹង គឺគេចាំក្តាប់រួមពីលើខ្ញុំបាទមក ជាពិសេសសង្កត់លើខ្ញុំបាទផ្ទាល់ហ្នឹងខ្លាំងជាងគេតែម្តង។

[១០:១១:៤៤]

**ស៖** លោកបានឆ្លើយថា គឺស្ត្រីទាំងអស់នុ៎ងដែលជាប្រធានពេទ្យហ្នឹង មិនដឹងថាវេជ្ជសាស្ត្រហ្នឹងជាអ្វីផងទេ ហើយលោកបានបន្ថែមផងដែរ ថាទាក់ទងនឹង ម៉េត នោះ លោកថា ម៉េត មិនចេះទាំងអានផង។ តើលោក<អាចបញ្ជាក់ចម្លើយនោះបានដែរឬទេ>?

**ឆ៖** បាទ នៅរក្សាចម្លើយនេះដដែល។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ សាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនូវបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១២នាទី ដល់ ម៉ោង ១០:៣១ នាទី)*

[១០:៣១:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅចៅក្រមហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី តើ<ត្រឹមត្រូវ>ទេថាមន្ទីរពេទ្យ<>មាន<>ប្រាំ<ផ្នែក> គឺផ្នែកវេជ្ជសាស្ត្រទូទៅ <>ផ្នែកសម្ភព <>ផ្នែកផលិតថ្នាំ <>ចែកជាផ្នែកផលិតថ្នាំបុរាណ <>និងផលិតថ្នាំទំនើប <> ផ្នែកចង្ក្រានបាយ <>និងផ្នែកបណ្តុះបណ្តាល។ តើ<មន្ទីរពេទ្យស្រុកត្រាំកក់រៀបចំបែងចែកដូច្នេះដែរឬទេ>?

**លោក រៀល សន៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើយើងអាចនិយាយបានដែរឬទេថា លោកជាអ្នកគ្រប់គ្រងនៅផ្នែកទាំងអស់នេះ ឬក៏មានផ្នែកណាមួយដែលលោកមិនទទួល<ខុសត្រូវនោះ>ទេ?

**ផ៖** គឺទាំងប្រាំផ្នែកនេះគឺ ខ្ញុំបានចូលរួមគ្រប់គ្រងទាំងប្រធានធំ និងខ្ញុំបាទហ្នឹងជួយចូលរួមដែរ។

[១០:៣៣:២៧]

**ស៖** លោកបាននិយាយកាលពីម្សិលមិញថា គេវះ<កាត់ដើម្បីបង្កើតកូននៅក្នុងមន្ទីរពេទ្យរបស់លោក>។ តើខ្ញុំសួរថា តើ<នរណា>ជាអ្នកវះ<កាត់ដើម្បីបង្កើតកូននៅពេលនោះ>?

**ផ៖** បាទ គឺធ្វើការវះកាត់នេះដែលខ្ញុំនិយាយពីម្សិលមិញនេះ គឺមិនមែននៅក្នុងពេទ្យស្រុកទេ គឺនៅពេទ្យតំបន់ គេធ្វើការវះកាត់។ មានអ្នកជំនាញខាងវះកាត់។

**ស៖** តើលោកផ្ទាល់<>ធ្លាប់បង្កើតកូនឲ្យគេទេ? តើមានរឿងអ្វីកើតឡើង<ចំពោះករណីសង្គ្រោះបន្ទាន់>?

**ផ៖** បាទ បើសិនណាជាអ្នកជំងឺត្រូវមកកូនង៉ែតអី ហើយបុគ្គលិកពេទ្យខ្ញុំបាទគាត់ជួយមិនបានហ្នឹង គាត់ហៅខ្ញុំជួយហ្នឹង ខ្ញុំអាចជួយបាន។ ជួយគាត់បានខ្លះៗ។

[១០:៣៤:៥៦]

**ស៖** លោកជាអ្នកទទួលខុសត្រូវក្នុងការបណ្ដុះបណ្ដាលបុគ្គលិក<។> តើលោក<បណ្ដុះបណ្ដាលគេ>ទាំងផ្នែកវេជ្ជសាស្ត្រ <>និងទាំងផ្នែកនយោបាយ<មែនដែរឬទេ>?

**ផ៖** បានទទួលតែផ្នែកវេជ្ជសាស្ត្រទេ ផ្នែកនយោបាយ គឺប្រធាននារី គេអ្នកទទួលខុសត្រូវ។

**ស៖** តើ<នរណា>ជាអ្នកទទួលខុសត្រូវក្នុងការជ្រើសរើសបុគ្គលិក? តើ<ការជ្រើសរើសនេះធ្វើឡើងត្រឹមថ្នាក់>មន្ទីរពេទ្យ<> ថ្នាក់ស្រុក <>ថ្នាក់តំបន់ <ឬក៏នៅ>ថ្នាក់ភូមិភាគ<? តើនរណា>ជាអ្នកទទួល<ខុសត្រូវក្នុងការជ្រើស>រើសបុគ្គលិកហ្នឹង?

**ផ៖** បាទ ករណីរើសបុគ្គលិក គឺខ្ញុំមិនមានសិទ្ធិទេ កាលនោះពេទ្យស្រុកមិនមានសិទ្ធិទេ គឺថៅហ្វាយស្រុកបញ្ជូនមកៗឲ្យពេទ្យ បញ្ជូន បើនារីប្រាប់ សរសេរសំបុត្រមួយប្រាប់មកថានារីនេះឲ្យមកនៅក្នុងពេទ្យហ្នឹង រៀនធ្វើពេទ្យ បើយុវជនក៏អ៊ីចឹងដែរ។

**ស៖** ម្សិលមិញលោកបាននិយាយថា បុគ្គលិកភាគច្រើនជាស្ត្រី។ ហើយខ្ញុំក៏បានអានផងដែរថា អង្គការមិនទុកចិត្តលើអ្នកដែល<រៀនបានខ្ពស់នោះ>ទេ<។> គឺអង្គការ<ពេញចិត្ត>នារីៗកសិករព្រោះថាគាត់មិនបានទៅរៀននៅសាលាដូច<អ្នកដទៃឡើយ> ដោយសារតែខ្លួន<>ជាប់រវល់ធ្វើ<ការងារ

ដើម្បី>បដិវត្តន៍។ តើមាគ៌ា<នេះ>ត្រូវ<គេអនុវត្ត>ក្នុងការ<ជ្រើស>រើសបុគ្គលិក<នៅមន្ទីរពេទ្យដែរឬទេ? តើគេពេញចិត្តជ្រើសរើសនារីមែនទេ? តើគេពេញចិត្តនារីដែលមកពីវណ្ណៈកសិករ ជាពិសេសកសិករក្រីក្របំផុតមែនដែរឬទេ>?

[១០:៣៧:៣១]

**ឆ៖** បាទអ៊ីចឹងមែន គឺបើចង់បានបុគ្គលិកពេទ្យណាម្នាក់ ហើយគេបញ្ជូនមកនោះ គឺពិតជាក្រ។

**ស៖** លោកខ្លួនឯងផ្ទាល់ លោកបាននិយាយដូចតទៅនេះ៖ “អង្គការមិនចង់ជ្រើសរើសមនុស្សដែលមានបានការរៀនសូត្រជ្រៅជ្រះទេ ព្រោះថាអាចក្បត់<>។ បញ្ញាជនអាចក្បត់ពីព្រោះពួក គេចេះពិចារណា<។> ហើយខ្ញុំៗយល់អំពី<ការអនុវត្តរបស់របបនោះ>អ៊ីចឹងខ្ញុំប្រយ័ត្នធ្វើយ៉ាងណាកុំឲ្យខុស”។ នៅក្នុង ឯកសារ <D313/1.2.409> ERNជាភាសាបារាំងគឺ <00808636> ដល់ 37។ តើលោកបញ្ជាក់<ពីអ្វីដែលខ្ញុំទើបតែអានអម្បាញ់មិញបានដែរឬទេ>?

**ឆ៖** បាទ លើកៗឡើងអ៊ីចឹងមែន។

**ស៖** តើ<>យុវនារី <ឬក៏ក្មេងស្រីៗនោះ>ដែលៗលោកបញ្ជូនទៅធ្វើការនៅមន្ទីរពេទ្យហ្នឹងគាត់មានអាយុប៉ុន្មានដែរ<>?

**ឆ៖** បាទ ក្មេងស្រីៗទាំងនោះមានអាយុតាំងពី១៣ឆ្នាំឡើង ១៣, ១៥ ទៅ ១៧-១៨ ទៅ២០ឆ្នាំមាន។ មានអ្នកខ្លះរហូតដល់ទៅមេម៉ាយមានកូនពីរបីហើយ ក៏គេបញ្ជូនឲ្យមកធ្វើពេទ្យដែរ ប៉ុន្តែអ្នកមេម៉ាយហ្នឹងស្លាប់បាត់អស់ហើយ ដែលធ្វើពេទ្យជាមួយខ្ញុំហ្នឹងស្លាប់បាត់អស់ហើយ។

**ស៖** តើ<កុមារ>ទាំងអស់ហ្នឹង -- <ដោយសារគេមានអាយុទើបតែ>១៣ឆ្នាំនោះ -- <តើពួកគេ>ចេះអាន<អក្សរ>ដែរឬទេ?

[១០:៤០:១៩]

**ឆ៖** បាទ អត់ចេះអានទេ គឺខ្ញុំបាទជួយបង្ហាត់បង្រៀនវា មានបើកវគ្គបង្ហាត់បង្រៀនមួយម៉ោងពីរម៉ោងអ៊ីចឹង នៅក្នុងមន្ទីរពេទ្យដែរ។ ប៉ុន្តែក្មេងៗកាលនោះ វាអត់សូវចង់រៀនសូត្រអីប៉ុន្មានទេ វារៀនបាន១ថ្ងៃអ៊ីចឹងទៅវាលែងរៀនទៅ អ៊ីចឹងទៅ ខ្ញុំក៏ឈប់បង្ហាត់ដែរទៅ។ អត់ចេះៗទេ មិនចេះតែម្តងពីតូចហ្នឹង អត់ចេះ អាធំ មនុស្សចាស់ហ្នឹងក៏អត់មាន អត់ចេះច្រើនដែរ អត់ចេះអក្សរ។

**ស៖** តើពួកគាត់ហ្នឹង មានមុខងារជាអីដែរ? <>តើ<ពួកគេដើរ>ចាក់ថ្នាំ<ដែរឬទេ? តើគេអាចប្រើថ្នាំប្រភេទអ្វី>ខ្លះ?

**ឆ៖** បាទ បើបុគ្គលិកពេទ្យស្រីតូចៗ គឺមិនចាក់ថ្នាំទេ មានតួនាទីត្រឹមលាងសីរ៉ាំង លាងម្ជុល ស្ងោរសីរ៉ាំង ស្ងោរម្ជុល តែប៉ុណ្ណឹងទេ។ ហើយបើពេទ្យនារីធំៗដែលត្រូវៗការចាក់ថ្នាំ ឈឺជំងឺ ឈឺអីត្រូវចាក់ថ្នាំអីនោះ គឺគេពេទ្យបុគ្គលិកពេទ្យទាំងអស់នោះរត់មកសួរខ្ញុំ ពិភាក្សាគ្នាជាមួយខ្ញុំ ហើយបានខ្ញុំទៅមើលជំងឺហើយ បានឲ្យចាក់ថ្នាំ។

**ស៖** <ឧបមា>ថាលោកមិន<នៅ>ពេលគេចាក់ថ្នាំនោះទេ។ អ៊ីចឹងគឺថាប្រហែល<ពួកគេ>ត្រូវតែមានស្វ័យភាព<ក្នុងការងាររបស់គេ>ដែរ។ តើ<>ធ្លាប់មានគ្រោះថ្នាក់<អ្វីដែរឬទេ>?

**ឆ៖** បាទ នៅពេលចាក់ថ្នាំបុគ្គលិកពេទ្យ គ្នាដូចថាមិនសូវយល់ដឹងអីច្រើន ជួនកាលចាក់ថ្នាំទៅបាញ់ថ្នាំខ្លាំងពេក ប្រតិកម្មអីក៏មានអ៊ីចឹងម្តងម្កាលដែរ។

[១០:៤៣:១១]

**ស៖** <>តើ<នេះបណ្តាលឲ្យមាន>គ្រោះថ្នាក់<យ៉ាងដូចម្តេច>?

**ឆ៖** បាទគ្រោះថ្នាក់ក្នុងការព្យាបាល -- ក្នុងការចាក់ថ្នាំ ឬក៏ក្នុងការព្យាបាលហ្នឹង។

**ស៖** ខ្ញុំព្យាយាមនិយាយឲ្យច្បាស់ជាហ្នឹង។ លោកបានរៀបរាប់បញ្ហាមួយចំនួនទាក់ទងទៅនឹងការ<ចាក់>សេរ៉ូម<។> នៅក្នុងឯកសារ <D313/1.2.409> នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ERN ជាភាសាបារាំងគឺ <00808662> ដល់ 63។ លោកបាននិយាយដូចតទៅនេះ៖ "<យើង>ខ្លាច<អ្នកជំងឺស្លាប់ក្រោយពេលគេចាក់ថ្នាំ-->

**លោក គង់ សំអុន៖**

លោកប្រធាន សូមអរគុណ។ សូមឲ្យលោក ឡាវ៉ែន៍ មេត្តាជួយផ្តល់ *វីហ្វឺរិនស៍* ជាភាសាខ្មែរ ឬជាភាសាអង់គ្លេសផងទៅ ដោយសារខ្ញុំមិនអាចតាមជាភាសាខ្មែរបានបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម អាចផ្តល់លេខ ERN ជាភាសា ពីរភាសាទៀតបានដែរឬទេ? ជាភាសាខ្មែរ និងជាភាសាអង់គ្លេស នេះជាតម្រូវការនៃកិច្ចដំណើរការពិភាក្សាកន្លងមក។ ជាពិសេសអង្គជំនុំជម្រះបានកំណត់ភាគីច្បាស់លាស់ណាស់លើបញ្ហាក្នុងការបង្ហាញឯកសារដោយបង្ហាញលេខឯកសារ ហើយនិងលេខ ERN នេះ ហើយដល់វេនចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង បើមិនធ្វើដូច្នេះទេ មិនទំនងទេព្រោះយើងជាអ្នកណែនាំគេឲ្យធ្វើដូច្នេះ។

[១០:៤៥:១៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ឥឡូវខ្ញុំបន្តទៅសំណួរផ្សេងទៀត ព្រោះថាខ្ញុំអត់មានលេខ ERN ជាភាសាខ្មែរ និងអង់គ្លេសទេ។ ERN ជាភាសាខ្មែរពិបាកដែរ<> ព្រោះខ្ញុំមិនចេះអានខ្មែរ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** តើលោកមានចាំអំពី<ព្រឹត្តិការណ៍>មួយដែលអ្នកជំងឺ<ម្នាក់ស្លាប់ក្រោយពេលដែលគេចាក់>សេរ៉ូម<ឲ្យគាត់>ដែរឬទេ<>?

**លោក វៀល សន៖**

**ឆ៖** បាទ ខ្ញុំបាទដូចជាអត់ចាំ។ អត់ ខ្ញុំអត់ដែលមានអ្នកជំងឺស្លាប់ដោយសារបន្ទោកសេរ៉ូមអី គឺអង្កាល់ហ្នឹងដូចអត់មាន។ អីក៏ខ្ញុំបាទភ្លេចម៉េចក៏មិនដឹង ខ្ញុំបាទអត់ដែលមាន។

[១០:៤៦:១៦]

**ស៖** តើលោកមានចាំថាបានទទួលបទបញ្ជាទាក់ទងនឹងការផលិតថ្នាំបុរាណដែរឬទេ?

**ឆ៖** បាទ បញ្ជាថ្នាំបុរាណ គឺលេខាស្រុក ជាពិសេសចៅហ្វាយស្រុកហ្នឹង គាត់ឲ្យសិទ្ធិខ្ញុំដើរប្រមូល តាសង្គមកិច្ចតាមភូមិហ្នឹងមកជួយធ្វើថ្នាំបុរាណ។ តាៗសង្គមកិច្ចហ្នឹង អ្នកខ្លះចេះថ្នាំការពាររោគនេះ ចេះថ្នាំការពាររោគនោះអីចឹងទៅ ខ្ញុំបាទដើរប្រមូលមកបាន ជាពិសេសមកនៅជិតខ្ញុំហ្នឹងបានបីនាក់។ ប៉ុន្តែស្លាប់បាត់អស់ហើយ ឥឡូវស្លាប់បាត់អស់ហើយ ធ្វើថ្នាំបុរាណ ថ្នាំគ្រាប់ ថ្នាំឫសឈើ ឫសព្រៃហ្នឹង តែខ្ញុំបាទវិញ គឺអត់ចេះទេ។ មិនចេះធ្វើថ្នាំបុរាណហ្នឹងសោះ។

**ស៖** តើឈ្មោះ តាពូន ដែលនៅក្នុងមន្ទីរសង្គមកិច្ចស្រុកនោះ តើគាត់ហ្នឹងជាអ្នកមានជំនាញខាងថ្នាំបុរាណមែនទេ?

**ឆ៖** បាទ តាពូន ជាគ្រូសង្គមកិច្ចល្អច្បាស់លាស់។ គាត់ចេះព្យាបាលជំងឺមួយចំនួនធំដែរ ប៉ុន្តែគាត់ស្លាប់បាត់ហើយ តាពូន ជាមនុស្សល្អ។

**ស៖** <តើពេទ្យ>ម្នាក់ឈ្មោះ<ថាន ក៏>ទទួលបន្ទុក<ផ្នែក>ផលិតថ្នាំបុរាណដែរ <មែនទេ>?

**ឆ៖** ស្តាប់ៗអត់បានអំមិញ។ ខ្ញុំស្តាប់អត់បានផង។

[១០:៤៨:៤៦]

**ស៖** តើលោកស្គាល់មនុស្សម្នាក់ដែលឈ្មោះ <ថាន> ទទួលបន្ទុក<>ផលិតថ្នាំបុរាណដែរឬទេ? <>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ឈ្មោះ តាន ហ្នឹងផង។

**ស៖** នៅក្នុងសំណុំរឿង យើងមានអត្ថបទមួយដែលសរសេរនៅក្នុងទស្សនាវដ្ដីស្វែងរកការពិត ដែលបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយអត្ថបទនេះ សរសេរដោយឈ្មោះ អែម សុខឃីម គាត់ហ្នឹងជាអ្នកសម្ភាសលោក ដែលគាត់ក៏បានសម្ភាសអ្នកផ្សេងទៀតផងដែរ។ អ៊ីចឹងនៅក្នុងឯកសារហ្នឹងគឺឯកសារ E3/1919, ERN ជាភាសាបារាំងគឺ <00780396>, ERN ជាភាសាអង់គ្លេសគឺ 00080505, ERN ជាភាសាខ្មែរគឺ 00185398 ដល់ <405>។ ខ្ញុំមិនច្បាស់ថា ERN លេខ ERN ប្រាកដនោះមួយណាទេ ប្រហែលជាទំព័រ៤០២។ មានលើកឡើងដូចតទៅនេះនៅក្នុងឯក-សារហ្នឹង៖ “<ថាន> ជាអ្នកជំនាញខាងថ្នាំបុរាណនៅក្នុងមន្ទីរត្រាំកក់បានឆ្លើយថា តាពូន ដែលជាអ្នកទទួលក្នុងការផលិតថ្នាំបុរាណបានបញ្ជាឲ្យលាយប្រមាត់មនុស្សជាមួយនឹងម្សៅ និងដើមឈើច្រើនមុខទៀត ដើម្បីស្ងួនជាថ្នាំគ្រាប់ ហៅថាថ្នាំអាចម៍ទន្សាយ”។ <>តើលោកមានធ្លាប់ឮគេនិយាយយ៉ាងដូច្នេះទេ? <ឬតើលោកចាំពីព្រឹត្តិការណ៍នោះដែរឬទេ>?

**ឆ៖** បើតាមខ្ញុំដឹង តាៗគាត់ធ្វើថ្នាំបុរាណមក ប្រមាត់មនុស្ស ប្រមាត់នេះមិនមែនប្រមាត់មនុស្សយើងទេ គឺដើមប្រមាត់មនុស្សលាយជាមួយអីផ្សេងៗទៀតទៅធ្វើថ្នាំ។ ដើមប្រមាត់មនុស្ស មានតើ! អាហ្នឹងថ្នាំ ដើមប្រមាត់មនុស្សហ្នឹងឥឡូវក្រ រកមិនសូវបាន។

[១០:៥២:១៨]

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងថ្នាំទំនើបវិញម្ដង តើលោកធ្លាប់ទទួលថ្នាំហ្នឹងគ្រប់គ្រាន់ដែរឬទេ? ឬក៏លោកបានស្នើទៅថ្នាក់លើ<ដើម្បីទទួលបានថ្នាំប្រភេទនេះដែរឬទេ>? តើ<ថ្នាក់លើតប>មកលោក<វិញ>យ៉ាង<ដូចម្ដេច>ដែរ?

**ឆ៖** បាទ ថ្នាំសម័យ បើកាលណាខ្វះ ហើយជាពិសេសគឺខ្វះជាប្រចាំអ៊ីចឹងតែម្ដង ថ្ងៃណាក៏គ្មានមានតិចតួច ស្នើទៅក៏អត់បានដែរ ប៉ុន្តែកាលណាមានគឺមានតែម្ដង មិនដឹងថ្ងៃណាមិនដឹងខែណា ស្រាប់តែថ្ងៃណាមាន មានតែម្ដង។ មកដល់ហ្នឹងក៏មិនច្រើនដែរ សម្រាប់ព្យាបាលអ្នកជំងឺតែពីរបីថ្ងៃហ្នឹងអស់ហើយក៏មិនមែនគ្រប់មុខដែរ មានតិចតួច។

**ស៖** តើលោកខ្វះថ្នាំអីខ្លាំងជាងគេ?

**ឆ៖** បណ្ដាថ្នាំដែលខ្វះជាងគេ ធាតុពិតគឺខ្ញុំមិនដឹងថាអាថ្នាំណានេះទេ ប៉ុន្តែបើអ្នកជំងឺខ្លាំងដែលខ្ញុំមិនដឹងថាឈឺអីនុ៎ង អាហ្នឹងគឺខ្ញុំបញ្ជូនទៅពេទ្យតំបន់ទៅ គឺអត់ដឹងថាត្រូវចាក់ថ្នាំអីជាទេអាហ្នឹង គឺខ្ញុំអត់

ដឹងដែរ។

**ស៖** មន្ទីរពេទ្យតំបន់នុ៎ងមានថ្នាំច្រើនជាងលោក ឬក៏យ៉ាងណា?

**ឆ៖** បាទ មន្ទីរថ្នាំនុ៎ងមាននៅពេទ្យតំបន់មានច្រើនជាងខ្ញុំនៅពេទ្យស្រុក។

**ស៖** នៅពេលដែលខ្វះថ្នាំ តើលោក<ទទួលបញ្ហា>ថា<ថ្នាំដែលលោកមានបន្តិចបន្តួចនោះ>ឲ្យ<ដល់តែ>បុគ្គលរូបណាមួយ មិនត្រូវប្រគល់ថ្នាំហ្នឹងទៅជំងឺផ្សេងទៀត<ដែរឬ>ទេ<?> តើមានការរើសអើង<ក្នុងការព្យាបាល>អ្នកជំងឺ<នៅក្នុងមន្ទីរពេទ្យ>ដែរឬទេ?

[១០:៥៥:១៣]

**ឆ៖** បាទ ចំពោះអ្នកជំងឺអត់មានរើសអើងអីទេ គឺបើអ្នកណាឈឺឲ្យចែកគ្នាអ៊ីចឹងទៅ បើមានអ្នកសល់ បើមានអ្នកជំងឺមួយសល់ ហើយនៅឆ្ងាយមកពេទ្យមិនទាន់អីហ្នឹងយើងចែកទៅឲ្យហើយហ្នឹងឲ្យគាត់ចែកគ្នាទៅ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាថ្នាំសម័យដែលមន្ទីរពេទ្យលោកផលិតនោះ មានថ្នាំអីខ្លះ?

**ឆ៖** បាទ ធាតុពិតខ្ញុំបាទ ផលិតថ្នាំហ្នឹងមិនមែនផលិតខ្លាំងជាងគេទេ ចេះខ្លាំងជាងគេតែបិតសេរ៉ូម បិតទឹកធ្វើសេរ៉ូមសម្រាប់លាយថ្នាំ។ ដូចជាខ្ញុំបានទៅទិញថ្នាំ មេថ្នាំបានមកដូចជា បេខ្ទូ បេអរងកុងហ្វូ កាល់ស្យូម អីហ្នឹងបានបិតទឹកបានហើយលាយយកទៅព្យាបាលជំងឺ។ ក្រៅពីហ្នឹងមានថ្នាំតែប៉ុន្មានមុខហ្នឹងទេអត់មានច្រើនទេ ដូចថាមានមេ។

[១០:៥៦:៥០]

**ស៖** បាទ ឥឡូវខ្ញុំសូមចូលទៅនិយាយអំពីប្រធានបទថ្មីមួយទៀត។ ខ្ញុំសូមឲ្យលោកនិយាយអំពីក្រាំងតាចាន់វិញម្តង។ កាលពីម្សិលមិញ លោកបាននិយាយថា លោកៗបានទទួលសំបុត្រមួយពីថៅហ្វាយស្រុកដែលសុំឲ្យលោកទៅមន្ទីរក្រាំងតាចាន់ដើម្បីឲ្យបាញ់ ដេ.ដេ.តេ ពីព្រោះថាកាលនោះមានមូសច្រើនណាស់ ហើយមានជំងឺគ្រុនចាញ់។ អ៊ីចឹងម្សិលមិញហ្នឹង លោកបាននិយាយអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** លោកបាននិយាយថា លោកបានជួបប្រធានមន្ទីរក្រាំងតាចាន់ ហើយលោកបានប្រាប់ថាគាត់ហ្នឹងឈ្មោះ តាអាន់។ តើលោកនៅរក្សាចម្លើយលោកនេះទេ?

**ឆ៖** បាទ ចម្លើយខ្ញុំពិតមែន។

**ស៖** តើលោកដឹងដែរឬទេថា តាអាន់ នេះជាបងប្អូនកម្មាភិបាលផ្សេងទៀតនៅស្រុកហ្នឹង។ ហើយពិសេសតើលោកធ្លាប់ឮនិយាយទេថា គាត់ហ្នឹងជា<ប្អូន>ប្រុសរបស់ យាយពឿន?

**ឆ៖** បាទ ខ្ញុំមិនដឹងថាបងប្រុស -- មិនមែនយាយ -- នេះយាយបឿន។ បងប្រុសយាយបឿន។

**ស៖** ខ្ញុំមិនមែននិយាយ យាយបឿន ទេ ខ្ញុំចង់និយាយ យាយពឿន។ បាទបើលោកមិនដឹងទេ មិនបញ្ហាអ្វីទេ។ លោកក៏បានឆ្លើយផងដែរ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺឯកសារ <E319.1.22> គឺចម្លើយ១២៥ ទៅដល់ចម្លើយ១២៨ លោកបាននិយាយថា លោកធ្លាប់ឮសំឡេងថ្ងូរ អ្នកទោសថ្ងូរ។ តើលោកអាចបញ្ជាក់បានទេ<>?

**ឆ៖** បាទ មានថ្ងូរអ៊ឺចឹងមែន។ កាលដែលខ្ញុំទៅបាញ់ថ្នាំ ដេ.ដេ.តេ ហ្នឹង បាញ់ជិតៗអគារអ្នកទោសហ្នឹង ឮស្រូវមាត់ថ្ងូរ។

[១០:៥៩:៥៧]

**ស៖** បើតាមលោកមើលឃើញនោះ តើមាន<>អ្នកទោស<ប៉ុន្មាននាក់ជាប់>ឃុំ<>នៅមន្ទីរក្រាំងតាចាន់?

**ឆ៖** បាទខ្ញុំមិនបានឃើញ មិនដឹងច្បាស់ថាមានប៉ុន្មានទេ ប៉ុន្តែគ្រាន់តែថា អើតមើលមួយភ្លែត ហ្នឹងខ្លាច អើតមកវិញទៅឃើញអ្នកទោសហ្នឹងដេកទាំងអស់គ្នា។

**ស៖** តើលោកមានចូលទៅក្នុងអគារដែលមានអ្នកទោសទេ<? តើមាន>គេមានប្រាប់លោកទេថា នៅក្នុងអគារហ្នឹងមានសត្វល្អិត<ដែរ>?

**ឆ៖** បាទ ខ្ញុំអត់បានចូលទេ ហើយគេអត់បានប្រាប់ថាក្នុងហ្នឹងមានសត្វល្អិតអី គឺអត់មានប្រាប់ទេ។ ធាតុពិតគ្រាន់តែខ្ញុំអើតមើលប៉ុណ្ណឹងហ្នឹង ខ្លាចផង ភ័យ ប៉ុន្តែគ្រាន់តែថាឮមាត់ថ្ងូរហើយ អើតមើលមួយភ្លែតទៅតែប៉ុណ្ណឹង។ គេអត់មានប្រាប់ថាឲ្យបាញ់ក្នុងហ្នឹង អត់ទេ បាញ់តែក្រៅៗនៅក្នុងព្រៃ។

[១១:០១:៣៥]

**ស៖** តើគេមានប្រាប់លោកឲ្យយកផលិតផលផ្សេង ក្រៅពី ដេ.ដេ.តេ ហ្នឹងទេ ឬក៏លោកយកតែ ដេ.ដេ.តេ ហ្នឹងទេចូលទៅក្រាំងតាចាន់ហ្នឹង?

**ឆ៖** បាទចូលទៅក្រាំងតាចាន់ហ្នឹង ខ្ញុំបាទប្រយ័ត្នប្រយែង គេស្នើឲ្យទៅបាញ់ ទៅគ្នាប្រាំនាក់ មានធុងបាញ់ថ្នាំប្រាំ។ អ៊ឺចឹងលាយ ដេ.ដេ.តេ ហ្នឹងហើយពីកន្លែងទៅៗដល់បាញ់ ប្រហែលកន្លះម៉ោង ហើយត្រឡប់មកវិញមក។

**ស៖** លោកមានយកថ្នាំទៅឱ្យអ្នកទោសទេ <ឬក៏យក>អាល់កុល <សម្រាប់លាងរបួស ឬសម្រាប់>សម្លាប់មេរោគ<ដែរឬទេ? តើលោកមានយកផលិតផលអ្វីផ្សេងទេ? តើ>គេមានស្នើឱ្យលោកយកផលិតផលផ្សេងពី ដេ.ដេ.តេ ហ្នឹងទេ?

**ឆ៖** បាទ គ្មានទេ។

**ស៖** ដូច្នេះលោកមិនដែលទទួលបានសំណើ<ថ្នាំសង្កូវ ឬផលិតផលផ្សេងៗ>ពី<មន្ទីរសន្តិសុខ>ក្រាំងតាចាន់<>ទេ មែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។ មិនដែលបានទទួលការសុំទេ អត់។

**ស៖** តើលោកចាំទេថានៅក្នុងអគារ ឬក៏នៅក្បែរអគារ ឬខាងលើអគារហ្នឹងមាន<ឧបករណ៍បំពងសំឡេងដែរឬទេ? តើលោកមានឮគេចាក់ភ្លេង ឬចម្រៀងតាមឧបករណ៍នោះដែរឬទេ>?

**ឆ៖** បាទ អត់មានចាក់ចម្រៀងទេ គ្រាន់តែឃើញអ៊ុបប៉ាល័រហ្នឹងចងព្យួរនៅដើមឈើ។ អត់មានឃើញចាក់អីផង។

[១១:០៤:០៥]

**ស៖** លោកក៏បាននិយាយអំពីមនុស្សម្នាក់ឈ្មោះ ដន <>ធ្វើការនៅមន្ទីរស្រុក តើលោកចាំទេឈ្មោះ ដន ហ្នឹង?

**ឆ៖** បាទ ចាំ។ ដន បច្ចុប្បន្ននេះជាអនុប្រធានរាជអារុធហត្ថនៅខេត្តបាត់ដំបង។

**ស៖** លោកអាចឆ្លើយម្តងបានទៀតទេ ព្រោះអម្បាញ់មិញនេះ យើងអត់បានស្តាប់ឮចម្លើយរបស់លោក<ព្រោះមានបញ្ហានៃ>ការបកប្រែទេ។ <ខ្ញុំមិនឮចម្លើយរបស់លោកទេ។>

**ឆ៖** បាទ ខ្ញុំស្គាល់ឈ្មោះ ដន។ បច្ចុប្បន្ននៅធ្វើទាហាន ធ្វើអនុប្រធានប៉េអឹមខេត្តបាត់ដំបង។

**ស៖** តើ ដន <សមាជិកមន្ទីរស្រុកនោះ>ធ្លាប់ត្រូវបានគេបញ្ជូនទៅក្រាំងតាចាន់<នៅពេលណាមួយ>ទេ?

**ឆ៖** បាទ អត់មានដែលទេ ខ្ញុំអត់ដឹង។

**ស៖** ចំពោះបុគ្គលិកមន្ទីរពេទ្យវិញ តើអ្នកណាជាអ្នកទទួលខុសត្រូវលើវិន័យបុគ្គលិក?

**ឆ៖** បាទវិន័យបុគ្គលិកក្នុងមន្ទីរពេទ្យស្រុកគឺនារីឈ្មោះ ម៉េត ហើយដូចខ្ញុំប្រាប់អ៊ីចឹង មិនមែនមាននារីតែមួយទេ ពីរបីឯណោះ។ មួយទៅបាត់ មួយមកទៀតៗ។ មាននារីម៉េត, នារីនាង, នារីអីច្រើនភ្លេច ខ្ញុំភ្លេចឈ្មោះបាត់អត់ទៀតហើយ មកឆាប់ៗពេក ភ្លេចឈ្មោះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើមានបញ្ហាវិន័យបុគ្គលិកនៅក្នុងមន្ទីរពេទ្យហ្នឹងទេ? ហើយបើមាន តើមានបញ្ហាអ្វីខ្លះ?

**ឆ៖** បុគ្គលិកនៅក្នុងមន្ទីរពេទ្យអត់មាន ដែលមានបញ្ហាអីធំដុំទេ គឺប្រធានគេដាក់វិន័យខ្លាចឲ្យមានវិន័យថ្លៃថ្នូនៅក្នុងមន្ទីរពេទ្យហ្នឹង គឺនារីទាំងអស់ហ្នឹងគោរពទាំងអស់គ្នា។ ទាំងនារី ទាំងបុរស បុរសក៏ នារីប្រធាននារីហ្នឹង គេនេះដែរ ក៏ជួយដូចគ្នា។

[១១:០៧:៤០]

**ស៖** អ៊ីចឹងមិនធ្លាប់មានការដាក់ទណ្ឌកម្មលើបុគ្គលិកនៅក្រាំងតាចាន់ទេ<មែនទេ?> គឺថាបុគ្គលិកហ្នឹងគឺតែងតែ<មានទំនាក់ទំនងល្អជាមួយអ្នកជំងឺជាដរាបមែនដែរឬទេ? ឬក៏តើមានពេលខ្លះគេ>ប្រព្រឹត្ត<មិនគប្បី>ជាមួយអ្នកជំងឺ<ដែរឬ>ទេ?

**ឆ៖** បាទ គ្មានទេ។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកអាចជម្រាបបានទេថា<ពាក់ព័ន្ធនឹងស្នើរៀបការរវាងបុគ្គលិកមន្ទីរពេទ្យ តើ>ការសម្រេចទាំងឡាយ<អាចធ្វើឡើង>នៅថ្នាក់<មន្ទីរ>ពេទ្យ ឬក៏<ការសម្រេចត្រូវធ្វើឡើងនៅ>ថ្នាក់ស្រុក<>?

**ឆ៖** ពាក់ព័ន្ធនឹងការរៀបការរបស់បុគ្គលិកគឺសម្រេចពីចៅហ្វាយស្រុក ឬលេខាស្រុក គឺខ្ញុំនៅមន្ទីរពេទ្យហ្នឹងគឺអត់ដឹងទេ មិនដឹងរឿងអីទេ ស្រាប់តែគេការអ៊ីចឹង។ គណៈស្រុកថាឲ្យការយកទៅការនៅមន្ទីរស្រុក។

**ស៖** អ៊ីចឹងការរៀបការហ្នឹង តើសាមីខ្លួនដឹងទេ ដឹងមុនទេ<? តើ>ពួកគេព្រម<>ទេ ចំពោះការរៀបការហ្នឹង?

**ឆ៖** បាទ ចំពោះបុគ្គលិកពេទ្យនៅពេទ្យខ្ញុំគឺដឹងខ្លួនៗពីមុន ស្រុះស្រួលគ្នាបានទៅការ។

**ស៖** អ៊ីចឹងមានន័យថា មិនមានបុគ្គលិកណា<ម្នាក់>ត្រូវ<គេ>បង្ខំឲ្យរៀបការជាមួយអ្នកដែលខ្លួនមិន<ពេញចិត្ត>ទេ មែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** លោកស្គាល់ឈ្មោះ អៀង វុធ ទេ?

**ឆ៖** បាទ មិនស្គាល់ទេ អត់ស្គាល់ឈ្មោះ អៀង វុធ ទេ។

**ស៖** <តាមពិតទៅ>លោកបាននិយាយ<យ៉ាងច្រើន>ពាក់ព័ន្ធនឹងឈ្មោះគាត់នេះ ប៉ុន្តែឥឡូវមិនអីទេ។ ឥឡូវនេះ ខ្ញុំចង់ឲ្យលោកផ្តល់ព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងក្រុមគ្រួសាររបស់លោក។ លោកមាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កូនប៉ុន្មាននាក់លោកសាក្សី?

**ឆ៖** ខ្ញុំបាទមានកូនប្រាំនាក់។

**ស៖** តើកូនរបស់លោកនោះមាន<នាទីអ្វី>នៅស្រុកត្រាំកក់ ឬក៏នៅស្រុកណាផ្សេងទៀតទេនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ<ដែរឬទេ>?

[១១:១១:៣៨]

**ឆ៖** កាលនោះ កាលពេលនោះ គឺកូនខ្ញុំនៅក្នុងស្រុកត្រាំកក់ទាំងអស់គ្នា។ កូននៅតូចៗទាំងប្រាំនាក់ហ្នឹងនៅស្រុកត្រាំកក់។

**ស៖** តើមានកូនប្រុសណាមួយរបស់លោក<ធ្វើប្រធាន>យុវជនស្រុកត្រាំកក់<ដែរឬ>ទេ?

**ឆ៖** បាទ គ្មានទេ។

**ស៖** តើមានកូនស្រីណាមួយទៅរស់នៅជាមួយ តាម៉ុក ទេ?

**ឆ៖** បាទ មាន។ ខ្ញុំបាទមានកូនប្រាំនាក់ហ្នឹង មានស្រីមួយ។ ស្រីមួយហ្នឹងទៅនៅជាមួយ តាម៉ុក – តាមុត ហ្នឹងតាំងពីនៅតូចរហូតទាល់តែថ្ងៃអន្លង់វែងបែកហ្នឹង វាមកដល់ផ្ទះវិញ មានប្តីមានប្រពន្ធមានកូនបីហើយ។

**ស៖** នៅពេលដែលកូនហ្នឹងទៅនៅជាមួយ តាម៉ុក ហ្នឹង នាងមានអាយុប៉ុន្មានដែរ?

**ឆ៖** វាទៅតាំងតែពីអាយុ ១៣ឆ្នាំ។

[១១:១៣:៣១]

**ស៖** ហើយទៅនៅរហូតដល់អាយុប៉ុន្មាន?

**ឆ៖** រហូតដល់អាយុ៣០ជាង បានមកហ្នឹង មកដល់អត់មានចេះអក្សរ ចេះអីផង។

**ស៖** តើលោកមានក្មួយប្រុស<ម្នាក់>ជាមេ<បញ្ជាការ>វរសេនាធំដែលទៅនៅជាមួយ តាម៉ុក ទេ គឺវរសេនាធំដែលនៅក្រោមបញ្ជា តាម៉ុក<ដែរឬទេ>?

**ឆ៖** បាទ មាន។ មានក្មួយប្រុសម្នាក់ឈ្មោះ ស៊ឹង ហ៊ន ទៅនៅក្នុងអង្គភាពកងពលប៉ុន្មានទេ ខ្ញុំភ្លេចហើយ ប៉ុន្តែនៅក្នុងអង្គភាពយោធា។

**ស៖** <តើលោកចាំឈ្មោះ> អៀប ឌុច ទេ?

**ឆ៖** បាទ អត់ស្គាល់ទេ។ មិនស្គាល់ឈ្មោះ អៀប ឌុច ទេ។

**ស៖** ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកធ្លាប់ទៅលាយបូរទេ? គឺខ្ញុំសំដៅទៅលើ

សហករណ៍លាយបូរ។

**ឆ៖** បាទ ផ្ដាប់ទៅ។ ខ្ញុំទៅសហករណ៍លាយបូរហ្នឹង ទៅរៀបចំកន្លែងពេទ្យ គណៈស្រុកប្រាប់ថា មានភ្ញៀវចិនមកទស្សនកិច្ចនៅហ្នឹង ខ្ញុំទៅរៀបចំមន្ទីរពេទ្យឃុំហ្នឹងឲ្យល្អ។

**ស៖** លោកទទួល<>ថ្នាំ<ឬជំនួយ>ពី<ប្រទេស>ចិន<ដែរឬ>ទេ?

**ឆ៖** បាទ ខ្ញុំបាទទទួលជំនួយ មិនទទួលពីចិនទេ ទទួលពីខ្មែរ ប៉ុន្តែថ្នាំចិន។

**ស៖** តើបុគ្គលិកមន្ទីរពេទ្យចេះអានឈ្មោះថ្នាំ ឬក៏សេចក្ដីណែនាំដែលគេមានបិទលើថ្នាំជាភាសាចិនទេ?

**ឆ៖** បាទ បុគ្គលិកពេទ្យមិនចេះអានភាសាចិន និយាយរួមឲ្យតែភាសាបរទេស បុគ្គលិកពេទ្យខ្ញុំគឺអត់ចេះមើលតែម្ដង អត់អានមិនរួច អានមិនដឹង គឺអត់ចេះអាន។

[១១:១៧:១៣]

**ស៖** <ប៉ុន្តែចំពោះ>លោកៗអាចអាន<>ភាសាបារាំងបាន<មែន>ទេ?

**ឆ៖** បាទ បានៗខ្លះទេ មិនបានច្រើនទេ បានខ្លះភាសាបារាំង ហ្នឹងនៅលើដបថ្នាំ នៅលើអំពូលថ្នាំ ផ្សេងទៀតគឺមិនបានទេ មិនបានច្រើនទេ។

**ស៖** ឥឡូវនេះ យើងនិយាយអំពីលាយបូរម្ដង។ តើអ្នកណាជាប្រធានសហករណ៍លាយបូរ?

**ឆ៖** ប្រធានសហករណ៍ កាលដែលៗខ្ញុំទៅរៀបចំទទួលភ្ញៀវនោះ គឺឈ្មោះ កិៗ។ តាកិ ហ្នឹងអក្សរមួយតួ ក៏គាត់អត់ចេះផង អក្សរខ្មែរមួយតួ ក៏អត់ចេះដែរ។

**ស៖** <តើនរណានៅក្រោម>តា<គិត? តើ>ជាលេខាស្រុក<មែនដែរឬទេ>?

**ឆ៖** មេៗរបស់តាកិ គឺលេខាស្រុក។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកប្រធាន ខ្ញុំស្នើសុំបង្ហាញរូបថតជូនទៅសាក្សី។ រូបថតនេះ គឺដកចេញមកពីឯកសារ ខ្សែភាពយន្តឯកសារវីដេអូមួយ ដែលមានលេខ E3/3091R។ ដូច្នេះ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំសូមបញ្ជាក់ថា រូបថតនេះលេចឡើងនៅម៉ោងដូចតទៅ គឺ៤៣នាទី ៣៥វិនាទី នៅលើ

វីដេអូនោះ។ លោកសាក្សី លោកស្គាល់មនុស្សនៅក្នុងរូបថតហ្នឹងទេ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន សូមដាក់បញ្ចាំងនៅក្នុងអេក្រង់កុំព្យូទ័រដើម្បីឲ្យបានភាគីបានមើលផង លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ផ្នែកខាង អាយ.ធី ដាក់បង្ហាញរូបថតអម្បាញ់មិញនេះ នៅលើអេក្រង់កុំព្យូទ័រ។

[១១:២០:៤៦]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** គឺខ្ញុំនិយាយម្តងទៀតគឺថា រូបនេះគឺបញ្ចាំង គឺម៉ោង ៤៣នាទី ៣៥វិនាទី។ លោកសាក្សី លោកស្គាល់មនុស្សនៅក្នុងរូបថតហ្នឹងទេ?

**លោក រៀល សន៖**

**ឆ៖** បាទ មិនស្គាល់ទេ។

**ស៖** យើងនឹងត្រឡប់មកនិយាយអំពីឯកសារមួយដែលខ្ញុំបានធ្វើ ព្រោះថាឥឡូវនេះខ្ញុំមាន ERN ជាបីភាសាហើយ ខ្ញុំនឹងអានឯកសារ D313/1.2.409, ERN ជាភាសាបារាំង 00808663, ជាភាសាអង់គ្លេស 00729078, ជាភាសាខ្មែរ <004118863> ជាភាសាខ្មែរខ្ញុំដូចជាមិនសូវច្បាស់សោះ<>។ គេនិយាយអំពីសេរ៉ូម៖ "យើងខ្លាចថាមានការសម្លាប់អ្នកជំងឺក្រោយពីចាក់<ថ្នាំ>ហើយ បើសិនជាអ៊ីចឹងមែននោះអ្នកផលិតក៏អាចមានគ្រោះថ្នាក់ដល់ជីវិតដែរ។ ចំពោះខ្ញុំៗធ្វើតេស្តលើកណ្តុរសិនមុនពេលទៅចាក់លើមនុស្សនោះ។ អ្នកភូមិម្នាក់ដែលជាអ្នក១៧មេសា បានមករកថ្នាំនៅក្នុងឃុំខ្ញុំ។ គាត់ស្លាប់ភ្លាមនៅពេលដែលអ្នកចាក់នោះមិនទាន់ដកសឺរ៉ាំងចេញផង ហើយនៅសល់ថ្នាំបីអំពូលខ្ញុំយកទៅធ្វើតេស្តលើកណ្តុរ ហើយពេលចាក់ភ្លាមកណ្តុរហ្នឹងងាប់ភ្លាម។ ខ្ញុំហៅអ្នកចាក់ ហើយនិងហៅមេឃុំ មកមើលការធ្វើតេស្តទៅលើឆ្កែ ក្រោយពីចាក់ភ្លាមឆ្កែហ្នឹងងាប់ភ្លាម។ សំណួរ៖"តើមានអ្វីកើតឡើងនៅពេលដែលមានមនុស្សងាប់? មានម៉េច ពីព្រោះថាពួកគេមកសុំសេរ៉ូមខ្លួនឯង ហើយអ្នកចាក់ហ្នឹង គេក៏ចាក់ថ្នាំហ្នឹងឲ្យទៅ ហើយពេទ្យហ្នឹងវាល្ងើ ពេទ្យហ្នឹងអត់ចេះអក្សរទៀត។ មេហ្នឹងនៅពេលនៅពេទ្យឃុំ ប៉ុនចេះចាក់ថ្នាំឲ្យគេចាក់សរសៃទៀត វាឆាប់ងាប់។ ប្រហែលជាគាត់ចង់ងាប់ក៏មិនដឹង ព្រោះវាពិបាកពេករស់នៅក្នុងសង្គមបែបនេះ។ ចង់រស់ដូចខ្ញុំអីហ្នឹង នៅស្រួលៗចេះតែចង់រស់ហើយ"។ អ្វីដែលខ្ញុំអានអម្បាញ់មិញ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នេះតើធ្វើឲ្យលោកមានការចងចាំឡើងវិញទេ?

[១១:២៤:៥៣]

**ឆៈ** បាទ ខ្ញុំបាទចងចាំឡើងវិញ ប៉ុន្តែមិនមែនពេទ្យហ្នឹង គាត់មានថ្នាំយកទៅចាក់អ្នកជំងឺហ្នឹងទេ គឺអ្នកជំងឺហ្នឹង កាន់ថ្នាំមកឲ្យពេទ្យហ្នឹងចាក់។ ពេទ្យហ្នឹងមិនព្រមចាក់ គាត់ថាអ្នកជំងឺហ្នឹងប្រាប់ថា "ខ្ញុំនៅភ្នំពេញនោះ ចាក់តែថ្នាំហ្នឹង" អ៊ីចឹង។ ហើយបានពេទ្យហ្នឹង គាត់ចាក់ទៅ។ ចាក់ទៅ គ្រាន់តែមិនទាន់ដកម្ជុលផង ក៏ស្លាប់បាត់។ ហ្នឹងពេទ្យឃុំណា មិនមែនពេទ្យស្រុកទេ ពេទ្យឃុំ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី ដែលបានឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ ដោយភាពអត់ធ្មត់។ ខ្ញុំអស់សំណួរហើយលោកប្រធាន។

[១១:២៥:៥៥]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សារបស់គាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយ និងសាមសិបនាទីរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:២៦ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយបន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី។ ជាដំបូងនេះគឺមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី រៀល សន។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក សាក្សី។ ខ្ញុំសូមសួរសំណួរមួយចំនួននៅវសៀលនេះពាក់ព័ន្ធទៅនឹងប្រធានបទផ្សេងៗ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ដំបូងខ្ញុំសូមសួរសំណួរជាទូទៅមួយអំពីស្រុក១០៥។ លោកដឹងទេថា មានប្រជាជនប្រហែលប៉ុន្មាននាក់រស់នៅក្នុងស្រុក១០៥ នៅក្នុងឆ្នាំ១៩៧៩?

**លោក រៀល សន៖**

**ឆ៖** បាទ ខ្ញុំបាទមិនដឹងចំនួនមនុស្សនៅក្នុងស្រុក១០៥ទេ ក្រោយឆ្នាំ៧៩ គឺខ្ញុំបាទអត់ដឹងទេ។

**ស៖** លោកដឹងថាមានប្រជាជនប្រហែលជាប៉ុន្មាននាក់រស់នៅក្នុងស្រុក១០៥នៅក្នុងឆ្នាំ១៩៧៥?

**ឆ៖** ហ្នឹងក៏ខ្ញុំបាទអត់ដឹង។

[១៣:៣៥:០០]

**ស៖** ខ្ញុំដឹងថា វាពិបាកនឹងធ្វើការប៉ាន់ប្រមាណណាស់ ប៉ុន្តែតើអាចទេ នៅក្នុងឆ្នាំ១៩៧៩ មានមនុស្ស ៨០.០០០នាក់រស់នៅក្នុងស្រុកត្រាំកក់ គឺស្រុក១០៥?

**ឆ៖** បាទ មិនច្បាស់ ប៉ុន្តែប្រហែល ប្រហាក់ប្រហែល។

**ស៖** លោកសាក្សី លោកដឹងថា អត្រាមរណៈមានន័យថាម៉េចទេ? លោក<ធ្លាប់>ប្រើពាក្យហ្នឹងទេ នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ<ដែរឬទេ>? តើមានន័យថាម៉េចដែរ ពាក្យថា “អត្រាមរណៈ” នេះ?

**ឆ៖** បាទ អត្រាមរណៈនេះ ប្រែថាចំនួនអ្នកស្លាប់។

**ស៖** ត្រឹមត្រូវហើយលោកសាក្សី។ តើអត្រាមរណៈមានទំហំប៉ុនណាដែរ នៅក្នុងស្រុកត្រាំកក់ ឆ្នាំ១៩៧៥ ឬនិយាយថា តើមានមនុស្ស<ប៉ុន្មាននាក់>ស្លាប់រៀងរាល់ឆ្នាំ<>នៅ<>ស្រុកត្រាំកក់ <> ក្នុងឆ្នាំ១៩៧៥ ឬក៏ឆ្នាំមុនៗ<>?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹង។

**ស៖** លោកសាក្សី លោកដឹងអត្រាមរណៈ ឬថាមានប្រជាជនប៉ុន្មាននាក់ស្លាប់ក្នុង<ចំណោមមនុស្ស១០.០០០នាក់> ក្នុងឆ្នាំ១៩៧៦, ៧៧, ៧៨, ៧៩? តើ១ឆ្នាំៗមានអត្រាមរណៈប៉ុន្មានដែរ?

[១៣:៣៧:១៩]

**ឆ៖** នោះៗក៏ខ្ញុំបាទអត់ដឹង។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះ និយាយម្យ៉ាងទៀតថា ប្រសិនបើមានភាពខុសគ្នារវាងអត្រាមរណៈនៅចន្លោះឆ្នាំ៧៥ ទៅដល់៧៩ និងឆ្នាំមុនៗនោះ? <>លោកអាចជម្រាបបានទេថា <នៅក្នុងស្រុកត្រាំកក់ តើ>មានមនុស្សស្លាប់<> តិច<ជាង> ឬក៏ច្រើន<ជាង>នៅមុនឆ្នាំ១៩៧៥?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹង អត់ដែលគិតផងរឿងស្លាប់រឿងរស់ហ្នឹង កាលនោះ។

**ស៖** លោកសាក្សី លោកដឹងច្បាស់លាស់ទេថា <តើ>មានប្រជាជនស្លាប់ដោយសារ<>ជំងឺ<>រាកមួលនៅក្នុងស្រុកត្រាំកក់ មុនឆ្នាំ<១៩៧៥ ដែរឬទេ>?

**ឆ៖** បាទ នៅមុនឆ្នាំ៧៥ ក៏ខ្ញុំមិនដឹងៗដែរ ទាល់តែក្រោយឆ្នាំ៧៥មក ហ្នឹងក៏មិនបានគិតជាចំនួនដែរ អត់ដឹងច្បាស់លាស់នូវចំនួនអ្នកស្លាប់ដោយសារជំងឺរាករូស។

**ស៖** លោកដឹងចំនួនប្រជាជនស្លាប់ដោយសារតែជំងឺរាកមួលដែរទេ ប៉ុន្មាននាក់ដែរទេ ក្រោយឆ្នាំ១៩៧៩?

[១៣:៣៩:២៩]

**ឆ៖** បាទ មិនដឹងទេ មិនដឹងចំនួនទេ។

**ស៖** <តើ>លោកដឹងថាមាន<មនុស្ស>ស្លាប់<ដោយជំងឺគ្រុនចាញ់ប៉ុន្មាននាក់>ជាមធ្យមមុនឆ្នាំ១៩៧៥<ដែរឬទេ>?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេសំណួរទី១ ច្រំដែល។ ទី២ សាក្សីនេះមិនមែនជាអ្នកជំនាញទេ។ សាក្សីឆ្លើយច្បាស់លាស់ហើយ រាប់សិបសំណួរហើយ គឺគាត់មិនដឹងទេ។ ដូច្នេះ សំណួរពាក់ព័ន្ធនឹង

ប្រភេទជំងឺ អត្រាជំងឺ អាណាអ្នកស្លាប់នេះ មិនបាច់ឆ្លើយតបទេ សាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ជាការអាចឲ្យយល់បាន ហេតុអីបានខ្ញុំសួរសំណួរទាំងនេះ ព្រោះ<>មុនពេលឈប់សម្រាកបាយថ្ងៃត្រង់នេះ គឺមានការយោង ឯកសារ<>មួយចំនួនគឺដកចេញពីភស្តុតាងស្តីអំពី<>ចំនួន<មនុស្ស>ស្លាប់នៅស្រុកត្រាំកក់។ អ៊ីចឹងហើយបានខ្ញុំចង់ដឹងតួលេខដល់យើងអ្នកស្លាប់នៅត្រាំកក់ដោយសារគាត់ធ្វើការនៅផ្នែកខាងសុខាភិបាល។ អ៊ីចឹងខ្ញុំចង់ដឹងអំពីតួលេខទូទៅទាំងនេះឯង។ ខ្ញុំគួរតែត្រូវបានអនុញ្ញាតឲ្យសួរសំណួរជាមូលដ្ឋាននេះដោយមិនសួរលម្អិតទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតឲ្យសួរទេ។ សាក្សីឆ្លើយច្បាស់ហើយគឺគាត់មិនដឹងទាំងអស់ វារាប់សិបសំណួររួចហើយ។ មិនមែនសំណួរសួរដើម្បីសួរនោះទេ ដើម្បីឲ្យបានផលចម្លើយហ្នឹងឆ្លើយតប ដើម្បីឲ្យអង្គជំនុំជម្រះយកមកគិតពិចារណាក្នុងការស្វែងរកការពិត។

[១៣:៤១:៣៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ មិនជាអ្វីទេ។ ខ្ញុំសួរទៅប្រធានបទមួយផ្សេងទៀតដោយអាននូវចម្លើយរបស់លោក<ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា>លោកសាក្សី គឺឯកសារ D313/1.2.410, ERN ជាភាសាអង់គ្លេស 00778947, ខ្មែរ 00418770, បារាំង 00752110។ លោកសាក្សីកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺគេបានសួរលោកនូវសំណួរមួយចំនួនដូចតទៅ នៅទំព័រខាងដើមបំផុតជាភាសាអង់គ្លេសនោះ៖ “តើលោកមាននិយាយអំពីភាពខុសគ្នារវាងវិជ្ជាជីវៈពេទ្យនៅក្នុងសង្គមចាស់ហើយនិងខាងវេជ្ជសាស្ត្រទំនើប? លោកឆ្លើយថា វិជ្ជាពេទ្យនេះគឺថាដូចតែគ្នាទេ មិនមានអីខុសគ្នាទេ ពីសង្គមចាស់ និងពេលនោះ”។ <ខ្ញុំចង់សួរលោកថា តើខ្ញុំយល់ចម្លើយរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាត្រឹមត្រូវទេ>ថា វាមិនមានលក្ខណៈខុសគ្នាអីទេ រវាងជំនាញ<វេជ្ជសាស្ត្រ> មុនឆ្នាំ៧៥ និងក្រោយ៧៥ គឺអត់ខុសគ្នាទេ។ តើលោកឆ្លើយថាអ៊ីចឹងឬ?

[១៣:៤៣:០៤]

**លោក វៀល សន៖**

**ឆ៖** បាទ ខ្ញុំឆ្លើយថា អ៊ីចឹង។

**ស៖** តើលោកអាចជម្រាបភាពខុសគ្នារវាងការអនុវត្តជាក់ស្តែង ដូចជាការចាក់ថ្នាំ ឬក៏ការព្យាបាលផ្សេងៗទៀត<បានដែរឬទេ?> តើវាដូចគ្នាមែនទេ ដែលថាការព្យាបាលមិនជាខុសគ្នាទេ ការព្យាបាលដោយបុគ្គលិកពេទ្យនៅមុនឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៥?

**ឆ៖** បាទ ព្រោះពេទ្យមានឯកទេសខាងពេទ្យហ្នឹងគឺដូចតែគ្នា បើគិតទៅខាងច្បាប់ពេទ្យហ្នឹងមានតែមួយ ទាំងមុនក៏ដូចតែក្រោយដែរ។ បើថាឈឺក្បាលលេបអាស្ពីរីនអ៊ីចឹងទៅបាត់។ ពីអង្កាល់ពីមុនក៏លេបអាស្ពីរីន ក្រោយក៏លេបអាស្ពីរីនដែរ។

**ស៖** តើប្រភពនៃចំណេះដឹងរបស់លោកហ្នឹង គឺលោកដឹងមកពីណា ពេលលោកឆ្លើយថាមិនមានការខុសគ្នារវាងការអនុវត្តជាក់ស្តែងផ្នែកវេជ្ជសាស្ត្រទាំងមុនឆ្នាំ៧៥ ក៏ដូចក្រោយឆ្នាំ១៩៧៥ គឺមិនខុសគ្នា?

**ឆ៖** បាទ ខ្ញុំបាទបានជាថាអ៊ីចឹង ព្រោះឃើញសៀវភៅពេទ្យ ឃើញសៀវភៅអ្នករៀនពេទ្យហ្នឹងនៅដូចតែគ្នាៗរៀនវិជ្ជា គ្រាន់តែមានថ្នាក់ទាប និងថ្នាក់ខ្ពស់។

[១៣:៤៥:១៣]

**ស៖** សូមអរគុណ។ លោកអាចជម្រាបអំពីកម្រិតនៃការអប់រំរបស់បុគ្គលិកពេទ្យនៅថ្នាក់តំបន់បានទេ? តើលោកដឹងថាការបណ្តុះបណ្តាលទៅដល់<គិលានុបដ្ឋាក/យិកា និងវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យ>តំបន់<>ដែរ<ឬទេ>?

**ឆ៖** បាទ នៅថ្នាក់តំបន់ ខ្ញុំបាទមិនដឹងទេ។

**ស៖** សូមអរគុណ។ លោកមានដឹងថា តើ<វេជ្ជបណ្ឌិត> ឬក៏គិលានុបដ្ឋាក/យិកាប្រើប្រាស់ថ្នាំបុរាណដែរទេ នៅមុនឆ្នាំ<១៩៧៥ ដែរ ឬទេ>?

**ឆ៖** មុនឆ្នាំ៧៥ ប្រើប្រាស់ថ្នាំបុរាណ ប៉ុន្តែប្រើតិចតួច ព្រោះមុនឆ្នាំ៧៥ វាមានថ្នាំសម័យហ្នឹងច្រើន។

**ស៖** តើលោកដឹង<ដោយរបៀប>ណាដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី!

**លោក រៀល សនៈ**

**ឆ៖** ជាពិសេស ខ្ញុំធ្លាប់ខ្លួនឯង និងបងប្អូននៅជុំវិញខ្លួន ពេលឈឺថ្កាត់អីហ្នឹងប្រើថ្នាំបុរាណតិច

ប្រើថ្នាំសម័យច្រើន ហ្នឹងគឺជាពិសេសបងប្អូននៅជិតៗគ្នាហ្នឹង ទិញថ្នាំនៅហ្វាម៉ាស៊ីនៅអ៊ីចឹងទៅ។ កាលនុំងមានហ្វាម៉ាស៊ី។

[១៣:៤៧:២១]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោកដឹងថាតើមានភាពខុសគ្នាទេ រវាងការព្យាបាលនៅមុនឆ្នាំ១៩៧៥ គឺអ្នកដែលមានលុយ និងអ្នកដែលគ្មានលុយ <ដែលមិនអាច>ទិញថ្នាំសង្កូវទំនើបបាន<ដែរឬទេ>?

**ឆ៖** បាទ បើតាមខ្ញុំដឹង អ្នកក្រកាលមុនឆ្នាំ៧៥ ក៏ទៅពេទ្យ អ្នកក្រពិតនោះ គឺពេទ្យអត់យកលុយដែរ ចាក់ថ្នាំដេកពេទ្យអីអត់យកលុយទេ បើយកៗបន្តិចបន្តួចថ្លៃថ្នាំ។ ហើយដល់អ្នកមានលុយគួរសមអាហ្នឹងយក អ្នកមានយកលុយ។

**ស៖** តើលោកដឹងរឿងនេះដោយរបៀបណា? លោកមានបទពិសោធន៍ផ្ទាល់ ឬក៏មានអ្នកណាប្រាប់លោក?

**ឆ៖** រឿងនេះ ខ្ញុំនៅតាមមូលដ្ឋាន នៅតាមភូមិ ប្រជាជន ប្រជាពលរដ្ឋឈឺទៅពេទ្យ គឺអ្នកក្រផុតលេខ ពេទ្យសុំឲ្យសំបុត្រ ឲ្យបញ្ជាក់សំបុត្រក្រហ្នឹងនៅតាមភូមិមក ពេទ្យអត់យកលុយទេ។ តែបើអ្នកមានគួរសម ពេទ្យអត់មានឲ្យធ្វើសំបុត្របញ្ជាក់ថា ក្រីក្រទេ គឺយកលុយថ្លៃថ្នាំ ថ្លៃអីបន្តិចហ្នឹង តិចតួចទេ មិនច្រើនទេ។

[១៣:៤៩:១៨]

**ស៖** ខ្ញុំបន្តទៅប្រធានបទមួយផ្សេងទៀត ពាក់ព័ន្ធទៅនឹងការប្រតិបត្តិវិជ្ជាជីវៈពេទ្យនេះ ជាក់ស្ដែងនៅក្នុងចម្លើយរបស់លោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ D313/1.2.409, ERN ជាភាសាអង់គ្លេសត្រង់ទំព័រ១២, 00729033, ខ្មែរ 00418817។ លោកឆ្លើយប្រាប់អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា "និយាយរួម<បញ្ហាកង្វះអាហារូបត្ថម្ភ និងរាកមួលបង្កឲ្យមានមនុស្សស្លាប់>ប្រាំនាក់ក្នុង១ថ្ងៃ ក្នុងរយៈពេល<ចុងក្រោយ>នោះ។ <លោកសាក្សីក្នុងចម្លើយរបស់លោកមួយទៀត លោកក៏បាន>និយាយ<>ពី<ជំងឺ>រាកមួល<ដែរ>។ តើលោក<លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថាតើ>មូលហេតុអីបានជាប្រជាជនមានជំងឺរាកមួលហ្នឹង? <តើគេឆ្លងជំងឺនេះពីណា?>

**ឆ៖** បាទ ខ្ញុំបានដឹងតើ។ ដឹងថាប្រជាពលរដ្ឋអត់មានស្បៀងហូបគ្រប់គ្រាន់ អត់មាន ខ្វះជីវជាតិធ្វើការហួសកម្លាំង ធ្វើការពលកម្មហួសកម្លាំងហ្នឹង យូរៗទៅបណ្ដាលឲ្យទៅជាហើម ហើយរាករូស

ស្លាប់។ យើងមិនអាចដាក់ថ្នាំត្រូវទេ ជំងឺហ្នឹង។

**សៈ** លោកសាក្សី ហេតុអីបាននិយាយថា បានជាប្រជាជនជំងឺរាក<មួល ដោយសារកង្វះអាហារូបត្ថម្ភ? តើលោកប្រាកដហើយថាកង្វះអាហារូបត្ថម្ភនេះបង្កឲ្យមានជំងឺរាកមួល>? <តើវាអាចមកពីមេរោគ ឬមីក្រុបដទៃទៀតជាជាងកង្វះអាហារូបត្ថម្ភដែរឬទេ>?

[១៣:៥១:៣៥]

**ឆះ** បាទ មូលហេតុធំជាងគេគឺខ្វះអាហារបរិភោគមិនគ្រប់គ្រាន់ ធ្វើការងារពលកម្មខ្លាំងហើយ ហូបៗហ្នឹងហូបបបរហូត ពីរបីខែហូបបបរបានតិចៗហ្នឹង។ បបរមួយកំប៉ុង អង្ករមួយកំប៉ុងហូបប្អូនដប់ម្ភៃនាក់ ហូបមួយពេល ហូបម៉េចបាន។

**សៈ** <នរណា>ប្រាប់លោក ឬ<>លោក<អានពីឯកសារណាថាកង្វះអាហារូបត្ថម្ភបង្កឲ្យមានជំងឺរាកមួល>?

**ឆះ** បាទ ស្លាប់ដោយសារជំងឺរាកនេះ អត់មានអ្នកណាប្រាប់ខ្ញុំ ព្រោះខ្ញុំ កាលហ្នឹងខ្ញុំនៅពេទ្យ។ បើបញ្ជូនអ្នកជំងឺពីភូមិមក គឺសុទ្ធតែហើម រាកអីចឹង ហើយស្លាប់។ គិតទៅក្នុង១ថ្ងៃដល់ជិតចុងបញ្ចប់ជិតចុងរបបហ្នឹង ជិតចប់ហើយ នៅកន្លះខែ ១ខែទៀត មិនមែនងាប់ប្រាំទេ មិនមែនស្លាប់ប្រាំទេ ស្លាប់ប្អូនដប់ណោះ។ ហើយយើងចេះតែហៅបងប្អូនកូនចៅគេឲ្យមកយកទៅ អ្នកជំងឺដែលនៅៗហ្នឹង ទៅបាត់អស់ទៅ ហើយបានវារលំគ្រាំហ្នឹងទៅ។

**សៈ** បើខ្ញុំយល់មិនច្រឡំទេ អ្នកជំងឺប្រាប់លោក<>ថាជំងឺរាក<មួល>ហ្នឹង គឺបណ្ដាលមកពីការខ្វះ<អាហារូបត្ថម្ភ>។ តើលោកឆ្លើយថាអីចឹង?

លោកសាក្សី ខ្ញុំព្យួរលោកឆ្លើយ បាទ។ លោកឆ្លើយអីចឹងមែន?

[១៣:៥៣:៥៣]

**ឆះ** បាទ។

**សៈ** តើបើសិនណាជាខ្ញុំនិយាយប្រាប់លោក លោកភ្ញាក់ផ្អើលទេ ថាអាជំងឺរាក<មួល>ហ្នឹងមិនបណ្ដាលមកពីខ្វះជីវជាតិទេ<?> លោក<ប្រធាន>ខ្ញុំសូមដកសំណួរនេះចេញវិញ។ លោកសាក្សីតើលោកដឹងអំពីផែនការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលចង់ឲ្យមានប្រព័ន្ធធារាសាស្ត្រឲ្យបានគ្រប់គ្រាន់ត្រឹមត្រូវ ដើម្បីធានាថាទឹកហ្នឹងគឺថាវាស្អាត។ លោកដឹងអំពីផែនការនេះទេ?

**ឆះ** បាទ ដឹងៗ ហើយខ្ញុំបាទចូលរួមជួយធ្វើប្រឡាយ ជួយជីកអណ្ដូងអីប្រជាពលរដ្ឋទៀតផង។

**ស៖** លោកដឹងអំពីផែនការឲ្យមានទឹកស្អាតកាន់តែច្រើនឡើងដែរទេ នៅក្នុងស្រុកត្រាំកក់<ដែរឬទេ>?

**ឆ៖** បាទ លោកចង់សួរឥឡូវនេះ ឬក៏ពីអង្កាល់របបនោះ?

**ស៖** ខ្ញុំសួរទៅលោកចន្លោះពីឆ្នាំ៧៥ ទៅដល់៧៩។

**ឆ៖** ក្នុងចន្លោះនោះប្រជាពលរដ្ឋសេរី គឺទឹកស្អាតអីគ្រប់គ្រាន់ មានទឹកគ្រប់គ្រាន់ មានអណ្ដូង មានត្រពាំង ជីកស្រះអីហ្នឹង ហើយធ្វើប្រឡាយទប់ជាកង់ៗ ទុកប្រើប្រាស់ឲ្យគោផឹក ឲ្យក្របីផឹក។

[១៣:៥៦:២៥]

**ស៖** លោកដឹងថា គោលបំណងមានគោលបំណងអ្វីដែរ ដើម្បីឲ្យមានទឹកស្អាតកាន់តែច្រើនឡើងនៅក្នុងស្រុកនុ៎ង? លោកដឹងថា ហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យមានបំណងគឺចង់ឲ្យនុ៎ងមានទឹកស្អាតកាន់តែសម្បូរឡើងនោះ?

**ឆ៖** ខ្ញុំបាទដឹងដែរ។ ចង់ៗឲ្យមានទឹកសម្បូរឡើងហ្នឹង មកពីចង់ឲ្យមានបានធ្វើស្រែ មានសេដ្ឋកិច្ចបរិបូរ ធ្វើចម្ការតាមស្រែ តាមអីបាន។ ខ្ញុំដឹងអាហ្នឹង ដឹងប៉ុណ្ណឹង។

**ស៖** លោកដឹងអំពីទំនាក់ទំនងរវាងទឹកស្អាត <ជួយកាត់បន្ថយ>ការកើតជំងឺរាគ<មួល>នេះទេ? ដឹងមូលហេតុវាទេ ឬក៏លោកមិនដឹងទេ?

**ឆ៖** បាទ ដឹងៗតើ។ កាលណា ដូចថាប្រជាពលរដ្ឋទាំងអស់គ្នាគឺចុះធ្វើពលកម្មក្នុងប្រឡាយទាំងអស់គ្នានៅតាមការដ្ឋានទាំងអស់គ្នា។ ដូច្នេះ ការបត់ជើង បត់ -- ការបត់ជើងអីហ្នឹងពេញដីទាំងអស់ភ្លៀងធ្លាក់មក ហើយប្រជាពលរដ្ឋខ្លាចមិនហ៊ានទៅណាមក ធ្វើការបត់ជើងៗជិតៗផ្ទះ ជិតត្រពាំងទឹកហ្នឹង ហើយត្រពាំងទឹកហ្នឹងហូបហ្នឹង អីហ្នឹង កង្វក់។ ហើយបើទៅណាឆ្ងាយណ៎ា អត់មានៗបង្គន់អនាម័យ អត់មានអី មានតែធ្វើទៅ។ ហើយមួយកន្លែងៗច្រើនណាស់ ប្រជាពលរដ្ឋរាប់រយនាក់ មួយភូមិៗធ្វើពលកម្ម។ អ៊ីចឹងវាអាចហើយ វាអាចឆ្លងមេរោគរាករូសហ្នឹងពីលាមកមួយទៅលាមកមួយ។ ហ្នឹងបណ្ដាលឲ្យស្លាប់ យើងមើលមិនត្រូវទេ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ បង្វែរក្បាលមីក្រូហ្វូនមកលិចតិចមក! ក្បាលមីក្រូហ្វូនមកសាក្សី។ អូខេបានហើយ។ អញ្ជើញតទៀតលោក វ៉ិចទ័រ កូប៉េ!

[១៣:៥៨:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកចាំ តើមន្ទីរពេទ្យ<>កប់អ្នកជំងឺដែលស្លាប់ហ្នឹង<>នៅទីណាដែរ? ឬក៏<លោក>ដុតចោលតែម្តង?

**លោក វៀល សន៖**

**ឆ៖** បាទ មានខ្លះយកទៅកប់ ខ្លះដុត។ មានបងប្អូនសពហ្នឹងមកជួយដុតពេទ្យទៅ យកឆ្អឹងទៅផ្ទះ ហើយបើអ្នកខ្លះស្លាប់ ហើយនៅ បងប្អូននៅឆ្ងាយ បងប្អូនមិនអាចមកយកបាន យើងកប់ទុកនៅកន្លែង មួយកន្លែងទៅ។

**ស៖** តើលោករៀបរាប់ឲ្យលម្អិតបន្តិចបានទេ តើបរិវេណដែលគេកប់ខ្មោចហ្នឹងនៅចម្ងាយប៉ុន្មានពីមន្ទីរពេទ្យរបស់លោក?

[១៤:០០:០០]

**ឆ៖** បាទ បរិវេណកន្លែងកប់ខ្មោចនៅឆ្ងាយពីពេទ្យប្រហែល១គីឡូម៉ែត្រៗ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ មន្ទីរពេទ្យនោះគឺមានចម្ងាយ៦គីឡូម៉ែត្រពីក្រាំងតាចាន់។ តើអ៊ីចឹងឬក៏អត់ទេ?

**ឆ៖** អាចច្រើនជាង៦គីឡូ អាហ្នឹងគ្រាន់ខ្ញុំស្មាន ព្រោះវាឆ្ងាយដែរ។

**ស៖** លោកសាក្សី លោកដឹងថា តើមន្ទីរពេទ្យ២២ គេកប់អ្នកជំងឺដែលស្លាប់នៅឯណាដែរ<>?

**ឆ៖** បាទ អត់ដឹងទេ មន្ទីរពេទ្យ២២ហ្នឹង ខ្ញុំបាទអត់ហ៊ានទឹងចូលទៅមន្ទីរហ្នឹងផង។

**ស៖** លោកសាក្សី លោកចាំ<ពី>ការព្យាបាលជំងឺគ្រុនចាញ់នៅមន្ទីរពេទ្យរបស់លោក<ដែរឬ>ទេ<>?

**ឆ៖** បាទ ចាំខ្លះៗទេ ប៉ុនភ្លេចខ្លះហើយ វាយូរពេកហើយ លែងព្យាបាល នៅចាំតិចតួច។

[១៤:០១:៥៥]

**ស៖** ជាទូទៅ តើលោកអាចព្យាបាល<អ្នកជំងឺ>គ្រុនចាញ់ហ្នឹងជាសះស្បើយបានទេ<? តើអ្នកជំងឺដែលចូលមកហ្នឹងជាដាច់ទាំងអស់គ្នាដែរឬទេ>? <តើលោកនៅចាំបានទេ?>

**ឆ៖** តាមការពិត ជំងឺគ្រុនចាញ់ដែលខ្ញុំព្យាបាលនៅកន្លែង នៅមន្ទីរពេទ្យមិនមែនបានជាទាំង

អស់ទេ មានអ្នកជំងឺខ្លះខ្លាំងពេក ដែលខ្លាំងធ្ងន់ធ្ងរ ខ្ញុំមិនអាចព្យាបាលបាន ខ្ញុំបញ្ជូនអ្នកជំងឺនោះទៅពេទ្យតំបន់។

**ស៖** តើលោកអាចផ្តល់ជាភាគរយទេ តើ<មនុស្ស>ដែលកើតជំងឺគ្រុនចាញ់ភាគច្រើនបញ្ជូនទៅមន្ទីរពេទ្យហ្នឹង គឺថាជា ត្រូវបានទទួលការព្យាបាលជាសះស្បើយភាគច្រើនឬ?

**ឆ៖** បើជំងឺគ្រុនចាញ់ បើបញ្ជូនទៅពេទ្យតំបន់ហើយ គឺអ្នកជំងឺគ្រុនចាញ់នុ៎ងមិនដែលមានស្លាប់ផង អត់ដែល។ មកវិញបន្តិច ឃើញប្រជាពលរដ្ឋដែលឈឺហ្នឹង មកវិញ។

**ស៖** ខ្ញុំសូមសួរសំណួរមួយចំនួន និយាយពីការបាញ់ថ្នាំ ដេ.ដេ.តេ នៅក្រាំងតាចាន់នោះ។ តើលោកដែលបាញ់ថ្នាំហ្នឹងនៅមន្ទីរពេទ្យរបស់លោកទេ <ឬក៏មិនដែលបាញ់ថ្នាំសោះ>?

**ឆ៖** បាទ ខ្ញុំមិនដែលបាញ់ថ្នាំនេះ ក្នុងមន្ទីរពេទ្យទេ ព្រោះកន្លែងពេទ្យខ្ញុំវាល អត់មានព្រៃ មិនៗហ៊ានបាញ់ បើបាញ់ទាល់តែបាញ់ក្នុងផ្ទះ ក្នុងកន្លែងអ្នកជំងឺ។ អ៊ីចឹង ខ្ញុំអត់ហ៊ានបាញ់ទេ បើមានព្រៃបានបាញ់ ប៉ុន្តែមន្ទីរពេទ្យនុ៎ងអត់មានព្រៃទេ វាល។

[១៤:០៤:១៨]

**ស៖** លោកចាំពាក្យពេចន៍ដែល<គេស្នើ>សុំ<ឲ្យលោកទៅបាញ់ថ្នាំ ដេ.ដេ.តេ នៅមន្ទីរអប់រំកែប្រែ>១០៥<ដែរឬ>ទេ? តើ អាន់ ប្រាប់លោកថាម៉េច មូលហេតុអីបានជា អាន់ ស្នើសុំឲ្យលោកទៅបាញ់ថ្នាំ ដេ.ដេ.តេ នៅក្រាំងតាចាន់?

**ឆ៖** បាទ រឿងស្នើសុំឲ្យខ្ញុំសុំខ្ញុំឲ្យទៅបាញ់ថ្នាំនេះ មិនមែន អាន់ ស្នើទេ គឺគេលេខាស្រុកស្នើប្រាប់ខ្ញុំថា ឲ្យទៅបាញ់ថ្នាំនៅកន្លែងក្រាំងតាចាន់ហ្នឹង។ អាន់ ហ្នឹងគេអ្នកស្នើទៅចៅហ្វាយស្រុក ហើយចៅហ្វាយស្រុកឲ្យមក ឲ្យខ្ញុំមកបាញ់ហ្នឹង។

**ស៖** តើស្រុកហ្នឹងមានការព្រួយបារម្ភ<ពី>អ្វីដែរ<? តើអ្វីជាក្តីកង្វល់ដែលនាំឲ្យគេស្នើឲ្យលោក>ទៅបាញ់ថ្នាំ ដេ.ដេ.តេ នៅក្រាំងតាចាន់? តើស្រុក<>បារម្ភពីបញ្ហាអ្វីដែរ?

**ឆ៖** តាមពិតទៅខ្ញុំ មិនដឹងៗស្រុកហ្នឹងគាត់បារម្ភម៉េច ប៉ុនគាត់ កាលហ្នឹងឲ្យតែឃើញសំបុត្រស្រុកមកហ្នឹងរត់កាប៉ាំងជើង កាប៉ាំងដៃ គ្មានឃ្លានបាយទេ រត់ទៅធ្វើ។ មិនដឹងថាគាត់មានគោលបំណងអ្វី ខ្ញុំអត់ដឹង។ ប៉ុន្តែគ្រាន់តែគាត់ប្រាប់ថាឲ្យបាញ់សម្លាប់មូសត្រង់ណាព្រៃៗហ្នឹង ឲ្យវាងាប់អស់ កុំឲ្យមានជំងឺគ្រុនចាញ់។

**ស៖** លោកដឹងថាតើអ្នកទោសនេះទទួលបានផលប្រយោជន៍ពីការបាញ់ថ្នាំ ដេ.ដេ.តេ ហ្នឹងដែរ

ទេ?

**ឆ៖** ខ្ញុំបាទដែរ កាលនុំងធ្វើជាប្រធានពេទ្យហ្នឹងគឺ ជាបុគ្គលិកពេទ្យហ្នឹងគឺខ្ញុំថាអត់បានសោះ ព្រោះមូសនៅក្នុងអគារស្លឹកហ្នឹង ខាំហ្នឹង ហើយទៅបាញ់ងព្រៃនោះ អាព្រៃហ្នឹង បើវាមិនងាប់វារត់ចូលក្នុងអាកន្លែងអ្នកទោសហ្នឹងមក រស់ហើយ។ ហើយគេមានឲ្យបាញ់នៅកន្លែងអ្នកទោសឯណា អត់បាញ់តែព្រៃជិតៗហ្នឹង ខាងៗហ្នឹង។

[១៤:០៧:២៩]

**ស៖** ខ្ញុំខ្លាចតែខ្ញុំយល់លោកមិនបានច្បាស់ទេ គឺថាមូសគឺវា<ចម្លងពីមនុស្សម្នាក់ទៅម្នាក់ទៀត វាខាំមិនរើសមុខថាជាអ្នកយាម> ឬកម្មាភិបាលដែលធ្វើការនៅទី<នោះទេ>។ ខ្ញុំដូចជាមិនយល់<> អ៊ីចឹងសូមឲ្យលោកពន្យល់ឡើងវិញម្តងទៀត<បានដែរឬទេ?>

**ឆ៖** ខ្ញុំដឹងថាជំងឺគ្រុនចាញ់ អាហ្នឹងនិយាយពីមេរៀនរបស់ពេទ្យ។ ជំងឺគ្រុនចាញ់បណ្តាលមកពីមេរោគនៅនឹងសត្វមូស គឺមូសដែកគោល។ កាលណាមូសដែកគោលញីខាំហ្នឹង វានឹងឆ្លងមេរោគពីមូសមេ។ មូសញីមានមេរោគគ្រុនចាញ់នៅហ្នឹង មូសឈ្មោល បើតាមរៀនអត់ដឹង អត់មានទេ។

**ស៖** ត្រឹមត្រូវហើយ ប៉ុន្តែមូសវាខាំ<មិនរើសមុខទេ>មិន<ថាជាអ្នកទោស> ជាអ្នកយាម <ឬជាកម្មាភិបាល>អីទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** លោកទេ ជាអ្នកនិយាយទៅដូចជាខុសគ្នា តើលោក<អាចបញ្ជាក់បន្តិចបានទេថាហេតុអ្វីបានជាលោកថាមានភាព>ខុសគ្នា<>យ៉ាង<ដូច្នេះ>?

**ឆ៖** អត់ៗមានមូសខាំ អត់មានខុសគ្នាទេ ខាំអ្នកទោសក៏គ្រុនចាញ់ ខាំអ្នកយាមហ្នឹងក៏ឆ្លងជំងឺគ្រុនចាញ់ដូចគ្នា គឺអត់ខុសគ្នាទេឲ្យតែវាខាំ។

**ស៖** ដូច្នេះការបាញ់ថ្នាំ ដេ.ដេ.តេ នេះគឺថា វាផ្តល់ប្រយោជន៍ទៅឲ្យមនុស្សនៅនោះទាំងអស់ គឺនៅក្រាំងតាចាន់នុំងគឺទាំងអ្នកទោស និងអ្នកយាម។ ត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១៤:១០:០០]

**ស៖** កាលដែលខ្ញុំសួរសំណួរនេះ ពីព្រោះក្នុងចម្លើយរបស់លោកឆ្លើយជូនមន្ត្រីស៊ើបអង្កេត E319.1.21 នៅក្នុងសំណួរ-<>ចម្លើយ១២៤ លោកឆ្លើយដូចតទៅ៖ “សួរថា៖ លោកអាចប៉ាន់

ប្រមាណចំនួនអ្នកទោសដែលមាននៅក្រាំងតាចាន់ <គឺទៅតាម>ចំនួនអគារ តើត្រឹមត្រូវដែរទេ? បាទត្រឹមត្រូវហើយ ខ្មែរក្រហមបានដាក់ឃុំឃាំងមនុស្សទាំងអស់នៅទីនោះ ដោយបង្អត់អាហាររហូតដល់ស្លាប់"។ សំណួរសួរថា តើគេមានបំណង<>បង្អត់អាហារអ្នកទោសឲ្យស្លាប់អ៊ីចឹងទេ <តើគេ>ឲ្យលោកទៅបាញ់ថ្នាំដេ.ដេ.តេ<នោះធ្វើអ្វី>?

**ឆ៖** បើតាមពិតទៅការទៅបាញ់ថ្នាំ ដេ.ដេ.តេ នេះមិនៗពាក់ព័ន្ធអីជាមួយនឹងអ្នកទោសទេ ត្រង់អាគេបង្អត់អ្នកទោសនោះ អាហ្នឹងវាដោយឡែក ដឹងគេមិនឲ្យអីហូប។ មិនឲ្យបងប្អូនអ្នកទោសហ្នឹងមានអីហូបមកអំពីបើតាមគិតទៅ ខ្ញុំថាមកពីអត់មានតែម្តង។ អត់មានស្បៀង អត់មានអង្ករ ព្រោះខ្ញុំទៅអត់មានឃើញអាកន្លែងដាំបាយហ្នឹងគ្មានឃើញអង្ករឃើញអី។ ខ្ញុំដើរជិតហ្នឹងមួយភ្លែតដែរហ្នឹង។ ទៅបាញ់ថ្នាំអត់តែមួយធុងហ្នឹង មួយធុងម្នាក់ត្រឡប់មកវិញប្រហែលកន្លះម៉ោង។

[១៤:១១:៥២]

**ស៖** លោកសាក្សី លោកជម្រាបជូនមន្ត្រីស៊ើបអង្កេត <ចម្លើយដែលខ្ញុំទើបតែអានមុននេះបន្តិចថា>អ្នកទោសត្រូវគេបង្អត់អាហាររហូតដល់ស្លាប់នៅក្រាំងតាចាន់។ ហើយលោកក៏បានឆ្លើយថា លោកគិតថា មនុស្សជាច្រើនបានស្លាប់នៅឯក្រាំងតាចាន់។ ខ្លួនលោកផ្ទាល់នេះ ធ្លាប់បញ្ជូន ឬក៏<លោកឲ្យគេ>បញ្ជូន<នរណា>ម្នាក់ទៅក្រាំងតាចាន់ទេ?

**ឆ៖** បាទ ខ្ញុំបាទមិនធ្លាប់បញ្ជូនទេ ប៉ុន្តែកាលចុងក្រោយនេះ មានសេនាជននៅស្រុក ឬខ្ញុំអត់ស្គាល់មកយកបុគ្គលិកពេទ្យខ្ញុំម្នាក់ស្រី ពីពេទ្យទៅ ដល់តែខ្ញុំទៅបាញ់ថ្នាំហ្នឹង ឃើញនៅមន្ទីរក្រាំងតាចាន់ហ្នឹង។

**ស៖** លោកសាក្សី ខ្ញុំសូមអានសម្រង់នៃចម្លើយរបស់លោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យលោកស្តាប់ គឺឯកសារ 131/1.2.409, <ជាភាសាអង់គ្លេស>នៅចុងទំព័រ២២គឺ ERN 00729043, ខ្មែរ 00418826 <ខ្ញុំ>អត់មាន ERN ជាភាសាបារាំងទេ នៅពេលនេះ។ <អ្នកស៊ើបអង្កេត>មជ្ឈ-មណ្ឌលឯកសារកម្ពុជាសួរទៅលោក៖ "តើមានការដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តខុស<សីលធម៌ដែរឬ>ទេ? លោកឆ្លើយថាមានការដាក់ទណ្ឌកម្ម។ ខ្ញុំបានដក<បុគ្គលិកពេទ្យម្នាក់>យកទៅដាក់គុកក្រាំងតាចាន់<។ ខ្ញុំ>ភ្លេចឈ្មោះ <ហើយសព្វ>ថ្ងៃ<រស់> នៅភូមិទួលរកា។ សំណួរ៖ ចុះមានដឹងថា គេធ្វើទារុណកម្ម<ចំពោះអ្នកដែលប្រព្រឹត្តខុសសីលធម៌ហ្នឹងរបៀប>ម៉េចទេ<>? ឆ្លើយថា៖ អត់ដឹងទេ គេយកទៅដាំបាយ<>នៅឯគុក"។ ប្រហែលជាមានបញ្ហាកំហុសនៅក្នុងការបកប្រែ ក៏ប៉ុន្តែក្នុងឯកសារ

នេះ ខ្លួនលោកផ្ទាល់ជាអ្នកសម្រេចបញ្ជូនបុគ្គលិកពេទ្យម្នាក់ ដកបុគ្គលិកពេទ្យម្នាក់បញ្ជូនទៅក្រាំងតាចាន់។ តើត្រឹមត្រូវទេ?

[១៤:១៤:៣០]

**ឆ៖** បាទ មិនត្រឹមត្រូវទេ។ ខ្ញុំមិនបានបញ្ជូនទេ។ អត់ទាំងដឹងផង ខ្ញុំមិននឹងនៅកន្លែងផង មកវិញស្រាប់តែនារីគេរាយការណ៍ប្រាប់ថា មានគេមកយកនារី ហាន ហ្នឹងទៅបាត់ហើយ។

**ស៖** ដូច្នេះ នារីពេទ្យម្នាក់នេះ សព្វថ្ងៃហ្នឹងរស់នៅ<ភូមិ>ទួលរកា តើឈ្មោះហ្នឹងគឺឈ្មោះនារី ហាន អ៊ីចឹងមែនទេ?

**ឆ៖** បាទ ឈ្មោះនារី ហាន។

**ស៖** ខ្ញុំគិតថា ពីប៉ុន្មានថ្ងៃមុននេះ គេបានសួរសំណួរ<នេះ>ទៅលោក<។ ប៉ុន្តែខ្ញុំមិនប្រាកដ ១០០ភាគរយ។> ថាតើនារីហ្នឹងត្រូវបានគេដោះលែងមុនវៀតណាមចូលលុកលុយកម្ពុជា ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹង។ ប៉ុន្តែដល់ក្រោយឆ្នាំ៧៩នេះ ខ្ញុំឃើញវាមកផ្ទះខ្ញុំ មកដល់ផ្ទះខ្ញុំតែម្តង។ សួរវាទៅ វាថាវាមកពីគុកក្រាំងតាចាន់ហ្នឹងមក រត់ទៅដែរ ហើយឥឡូវត្រឡប់មកវិញហើយ មកផ្ទះវិញ។ ប៉ុន្តែដល់ក្រោយមកទៀតមិនដឹងវាទៅណាបាត់ អត់ឃើញ។ ផ្ទះវាមិនមែននៅក្នុងខេត្តតាកែវ មិននៅឯណា អត់ដឹង។

**ស៖** ដូច្នេះលោក<ឃើញ>គាត់ក្រោយឆ្នាំ១៩៧៩ ហើយគាត់ប្រាប់ថា គាត់បានរត់គេចខ្លួន។ ហ្នឹងមានន័យថា នារីហ្នឹងត្រូវបានគេឃុំខ្លួនរហូតដល់ចុងឆ្នាំ១៩៧៨ គឺរហូតដល់ដើមឆ្នាំ១៩៧៩ អ៊ីចឹងឬ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** ដឹងទេសព្វថ្ងៃហ្នឹងនារី ហាន ហ្នឹងរស់នៅឯណាដែរ?

[១៤:១៦:៥៤]

**ឆ៖** បាទ មិនដឹង អត់ដែលដឹង អត់ដែលឃើញមក ហើយខ្ញុំចាស់ហើយ វង្វេងវល់តែឈឺ មិនដឹងអត់ដែលបានដឹងវានៅឯណាអីឯណា។ អត់ដឹងទេ ប៉ុន្តែស្រុកកំណើតវាមិនមែននៅតាកែវទេ ប្រហែលនៅឯណាកំពង់ឆ្នាំង ហើយពោធិ៍សាត់មិនដឹង ខ្ញុំភ្លេចៗអស់។

**ស៖** លោកដឹងអំពីគ្រួសាររបស់គាត់<>ឬក៏សាច់ញាតិរបស់គាត់ដែលអាចប្រាប់<>លោកថា

សព្វថ្ងៃហ្នឹងគឺនារីហ្នឹងនៅរស់នោះ<ដែរឬទេ>?

**ឆ៖** បាទអត់ទេ អត់មានអ្នកណាប្រាប់ គ្មាន។

**ស៖** តើគាត់ដែលនិយាយប្រាប់លោកអំពីការ<>ប្រព្រឹត្តណាមួយ<ទៅលើរូបគាត់>នៅក្រាំងតាចាន់ទេ?

**ឆ៖** បាទ អត់ទេ ព្រោះវាៗមកជួបខ្ញុំនឹងក៏មកជួបឆាប់ដែរណា៎ គ្រាន់តែជួបហើយវាជិះកង់ទៅវិញទៅ។ វាមកសុំអង្ករសុំអីហូបពីខ្ញុំហ្នឹង ខ្ញុំឲ្យអង្ករឲ្យស្រូវវា វាទៅវិញបាត់ ទៅបាត់ទៅ។

**ស៖** ខ្ញុំនឹងសួរអំពីមូលហេតុអំពីការចាប់ខ្លួនរបស់នារីរូបនុ៎ង ហើយនិងការបញ្ជូនខ្លួនទៅក្រាំងតាចាន់។ ហេតុមានមូលហេតុអីបានជានាំឲ្យមានការចាប់ខ្លួននារី ហាន? តើគេមានចោទប្រកាន់នារីហ្នឹងថាជាខ្សែបណ្ដាញរបស់ កង <មែន>ដែរឬ<ទេ>?

[១៤:១៩:១៦]

**ឆ៖** បាទ ខ្ញុំគិតថា កាលពីមុនដែលយកវាមក គេយកវាមកធ្វើហ្នឹង ស្មានតែគេឲ្យពេទ្យពី២២មកជួយខ្ញុំ។ ខ្ញុំអត់ដឹងចេះតែនៅជាមួយគ្នា ល្អកល្អិនជាមួយគ្នា ដល់តែពេលចាប់ទៅបាត់នេះ បានឮសួរគេប្រាប់ថា នារីៗដែលនៅ ហើយខ្ញុំអត់នៅហ្នឹង គេមកយកខ្ញុំអត់នៅទេ អ៊ីចឹងគេប្រាប់ថា "នារី ហានហ្នឹងពាក់ព័ន្ធជាមួយ តាកង នៅមន្ទីរពេទ្យ២២ហ្នឹង។ អ៊ីចឹងត្រូវហៅវាយកទៅ"។ អ៊ីចឹងតែប៉ុណ្ណឹង។

**ស៖** តើ<គេឆ្លើយដាក់>រឿងអី<ដែរ>? តើ កង ហើយនិងអ្នកដទៃទៀតដូចជា កង ហើយនិង ហាន ហ្នឹង គេចោទប្រកាន់ថា ជាប់ទាក់ទងគ្នា។ ជាប់ទាក់ទងក្នុងរឿងអី ក្នុងបទល្មើសអី?

**ឆ៖** ខ្ញុំអត់ដឹង។

**ស៖** ដូច្នេះលោកមិនធ្លាប់បានឮអំពីការចោទប្រកាន់ចំពោះសកម្មភាពរបស់គាត់ហ្នឹងទេ អ៊ីចឹងឬ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** លោកសាក្សី លោកស្គាល់មនុស្សឈ្មោះ សាត និងឈ្មោះ <ដួង ដែរឬ>ទេ?

**ឆ៖** បាទ មិនស្គាល់ទេ។

**ស៖** ក្នុងចម្លើយរបស់លោក លោកនិយាយ បុរសម្នាក់មកពីហាណូយដែលលោកបានឃើញនៅឯក្រាំងតាចាន់នៅពេលដែលលោកបាញ់ថ្នាំ ដេ.ដេ.តេ។ លោកហៅគាត់ថា តាហាណូយ។ តាហាណូយ និង ដួង ជាមនុស្សតែមួយឬ?

**ឆ៖** បាទ មិនមែនទេ។ តាហាណូយ ហ្នឹងគាត់ឈ្មោះ ជា។ ដួង ហ្នឹងខ្ញុំអត់ស្គាល់ទេ។

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត<សិន ហើយ>ក្រោយសម្រាកខ្ញុំនឹង<ត្រឡប់មកនិយាយ>ប្រធានបទ<នេះឡើងវិញ>។ ឥឡូវនេះ ខ្ញុំចូលប្រធានបទមួយទៀត។

[១៤:២២:១៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអានសម្រង់ចេញពីឯកសារមួយគឺឯកសារ E27/7.1.8, ERN ជាភាសាអង់គ្លេស 00901569, ខ្មែរ 00893276-77, ហើយបារាំង <00978648-49>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីនេះ គឺជាចម្លើយរបស់កម្មាភិបាលម្នាក់មកពីភូមិភាគនិរតី។ គាត់ឆ្លើយនូវសំណួរមួយចំនួន។ ខ្ញុំនឹងអានសំណួរនិងចម្លើយនេះ ហើយសួរទៅលោកថាតើលោកយល់ថាដូចម្តេចដែរ។

នៅក្នុងចម្លើយលេខ៥ គឺសួរដូចតទៅ៖ “ក្នុងឋានៈលោកជាមេឃុំកំពង់<ស្វាយ> តើលោកបានទទួលបញ្ជាពីថ្នាក់លើឲ្យចាប់មនុស្សដែរឬទេ? ក្នុងនាមជាមេឃុំកំពង់<ស្វាយ> ខ្ញុំ<គ្មានបំណងធ្វើបាបនរណា>ដែលធ្វើខុស<នោះ>ទេ ប៉ុន្តែ<ថ្នាក់>ឃុំមានសិទ្ធិរាយការណ៍ទៅថ្នាក់លើ។ ខ្ញុំមានសិទ្ធិរាយ-ការណ៍ទៅថ្នាក់លើ ឧទាហរណ៍នៅពេលប្រជាជនមិនមានស្រូវអង្ករហូបគ្រប់គ្រាន់ <និងនៅពេលដែល>ប្រជាជនត្រូវធ្វើឲ្យបាន<តែ២>តោន ក្នុង១ហិកតា។ តាម៉ុក បានចេញបញ្ជាថាថ្នាក់ឃុំ<ថ្នាក់>ស្រុក <និងថ្នាក់តំបន់មិនត្រូវ>ចាប់ ឬក៏សម្លាប់<មនុស្សទេ>។ សួរ៖ តាម៉ុក និយាយថា ថ្នាក់ស្រុក និង<ថ្នាក់>តំបន់មិនមានសិទ្ធិសម្លាប់មនុស្សទេ។ ហេតុអ្វីបានជាមានមនុស្សជាច្រើនត្រូវបានសម្លាប់ដោយថ្នាក់ស្រុក និងតំបន់<យ៉ាងដូច្នេះ>? ខ្ញុំអត់ដឹងដែរ<ពីការអនុវត្តរបស់គេ> ប៉ុន្តែខ្ញុំចាំ<> សម្តី តាម៉ុក ច្បាស់ណាស់។ ហើយសំណួរ៩ (សំណួរទី៩) សួរថា៖ “<តើ> តាម៉ុក ប្រកាសយ៉ាងដូច្នេះនៅពេលណា? <នេះមកដល់សំណួរ និងចម្លើយដែលខ្ញុំលើកយកមកសួរដេញដោលលោកហើយ។ ចម្លើយមួយដូចខ្ញុំទៅសួរតទៅជាមួយលោក ឆ្លើយថា តាម៉ុក<>ប្រកាសនេះ <តាំងពី>មុនឆ្នាំ១៩៧៥ <មកម្ល៉េះ គឺធ្វើឡើងក្នុងពេលសន្និដ្ឋានរួមដើម្បីបញ្ចប់កិច្ច>ប្រជុំ<ប្រចាំឆ្នាំ>មួយនៅក្នុងព្រៃ<។> មានមេឃុំ ថ្នាក់ស្រុក <គណៈខេត្ត> និងថ្នាក់វរ<សេនាធំ> បានចូលរួម។ ក្រោយឆ្នាំ១៩៧៥ មានកិច្ចប្រជុំមួយទៀតនៅក្រុងតាកែវ ដែលមានអធិបតីភាព<របស់> តាម៉ុក ហើយនិង សោម ដែលជាគណៈកម្មា

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ធិការតំបន់១៣។ ពួកគេប្រកាសថា ទាហានមានឋានៈចាប់ពីអនុសេនីយ៍<ត្រី>រហូតដល់វរសេនីយ៍<ឯក នឹងមិនត្រូវប៉ះពាល់ឡើយ>។" តើលោក<សំដៅថាទាហានដែលមានឋានន្តរសក្តិជាអនុសេនីយ៍ត្រី រហូតទៅដល់វរសេនីយ៍ឯកនឹងមិនត្រូវគេចាប់ខ្លួនទេ មែនដែរឬទេ?" ឆ៖ "ខ្ញុំមិនដឹងទេ ព្រោះនេះជាការអនុវត្តផ្សេងៗពីគ្នាពីតំបន់មួយទៅតំបន់មួយទៀត។">

<លោកសាក្សី ខ្ញុំចង់សួរលោកថា តើលោក>បានចូលរួមនៅក្នុងកិច្ចប្រជុំមួយនៅក្រុងតាកែវ<នៅ>ក្រោយឆ្នាំ<១៩៧៥> ដែល<ជា>កិច្ចប្រជុំមានការប្រកាសថា ទាហានពីថ្នាក់អនុសេនីយ៍<ត្រី> ទៅដល់វរសេនីយ៍<ឯក នោះនឹងមិនត្រូវគេ>ប៉ះពាល់<នោះដែរឬទេ>?

**ឆ៖** បាទ ខ្ញុំមិនបានទៅរួមប្រជុំនៅឯតាកែវហ្នឹងទេ ប៉ុន្តែខ្ញុំបាទគ្រាន់តែដឹងថា ដែលនៅតាមមូលដ្ឋានឃុំ ហើយនិងស្រុកនេះ ស្រុកប្រជុំ គឺប្រាប់ត្រង់ៗអ៊ីចឹងហើយថា ប្រជាជនថ្មីដែលមកពីភ្នំពេញជម្លៀសមក បើមានអ្នកណា បើទាហានត្រឹមពាក់អាត់ស្លូដង់ឡើងបោសសម្អាត។ បើខាងរដ្ឋបាល ត្រឹមជំទប់លេខ១ឡើង បោសសម្អាតទាំងអស់។ ហ្នឹងបើប្រជុំនៅតាកែវ ខ្ញុំអត់ដឹង។

[១៤:២៧:០០]

**ស៖** ខ្ញុំដឹងថាហ្នឹងជាចម្លើយរបស់លោកហើយ ខ្ញុំនឹង<ត្រឡប់មក>និយាយអំពីកិច្ចប្រជុំមួយនេះ ដែលលោកកំពុងតែនិយាយ។ តើលោកធ្លាប់ដែលឮថា<>នៅក្នុងភូមិភាគនិរតីដែលថា នាយទាហានដែលមានឋានៈខ្ពស់ជាងអនុសេនីយ៍<ត្រី ឡើង>ទៅ គឺថា<គេនឹង>មិន<>ប៉ះពាល់នោះ?

**ឆ៖** បាទ ខ្ញុំដឹងថាប៉ុណ្ណឹងទេ ដឹងថាគេប្រកាសថាទាហានត្រឹមពាក់អាត់ស្លូដង់ៗណា អាត់ស្លូដង់ឡើងទៅ ហ្នឹងបោសសម្អាតហើយ ហើយបើខាងរដ្ឋបាល ត្រឹមជំទប់លេខ១ឡើងទៅ អាហ្នឹងបោសសម្អាតហើយ ឲ្យតែដឹងច្បាស់។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** លោកសាក្សី លោកបានឆ្លើយជូនមន្ត្រីស៊ើបអង្កេត E3/5511 សំណួរចម្លើយទី៩ លោកនិយាយអំពីកិច្ចប្រជុំមួយនេះ។ ពីម្សិលមិញលោកឆ្លើយទៅសហព្រះរាជអាជ្ញាថា លោក គឺថាកិច្ចប្រជុំហ្នឹងធ្វើឡើងនៅពេលណាមួយក្នុងឆ្នាំ៧៧។ នៅក្នុងសំណួរចម្លើយលេខ៩ លោកឆ្លើយថា<> កិច្ចប្រជុំស្តីពីការបោសសម្អាតនោះត្រូវការ ត្រូវបានប្រកាសឡើងនៅ<មុនពេលគេជម្លៀសប្រជាជន>។ <តើលោកអាចបំភ្លឺបន្ថែម>អំពីកាលបរិច្ឆេទនៃកិច្ចប្រជុំដែលលោកបានចូលរួម<នោះដែរឬទេ?> <តើ>ចម្លើយរបស់លោកថាមានកិច្ចប្រជុំមុនពេលជម្លៀសក្នុងឆ្នាំ១៩៧៥<ដែរឬ>ទេ?

**ឆ៖** បាទ មិនចាំកាលបរិច្ឆេទ ប៉ុន្តែចាំខ្លឹមសារហ្នឹង គឺអ៊ីចឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ប៉ុន្តែវាសំខាន់ណាស់សម្រាប់ខ្ញុំ ដើម្បីស្វែងយល់<>ពីកាលបរិច្ឆេទ<។> ពីម្សិលមិញលោកឆ្លើយថា កិច្ចប្រជុំហ្នឹងធ្វើឡើងនៅក្នុង<>រដូវ<ប្រាំង>ក្នុងឆ្នាំ<១៩៧៧>។ តើមានកិច្ចប្រជុំដែលគេប្រកាស<ប្រភេទមនុស្សដែលត្រូវបោសសម្អាត> មុនពេល<គេ>ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញក្នុង<ខែមេសា ឆ្នាំ១៩៧៥>នោះ<ដែរឬទេ>?

**លោក ឌេល លីសាក់៖**

<លោកប្រធាន គ្រាន់តែ-->

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំសូមជំទាស់ គឺមេធាវីការពារក្តីមានការលើកយកចម្លើយនេះខុស។ ចម្លើយរបស់<សាក្សីរូបនេះ ខ្ញុំចាំចម្លើយគាត់បាន>ថាកិច្ចប្រជុំនៅមុនខែមេសា <ឆ្នាំ១៩៧៧>។ គាត់<>មិននិយាយខែ <ឬពេលវេលា>ច្បាស់លាស់នោះទេ។ <ខ្ញុំកាលពីម្សិលមិញសួរគាត់ថា “តើមុន ឬក្រោយខែមេសា ឆ្នាំ១៩៧៧?” គាត់ឆ្លើយថា “មុន”។ ដូច្នេះខ្ញុំមិនគិតថាកាត់បានឆ្លើយពីពេលវេលាជាក់លាក់ដែលមានខែ ឬឆ្នាំ>នោះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

<លោកប្រធាន ខ្ញុំយល់ថាសាក្សីបានបញ្ជាក់ពីសំណួរនេះហើយ តាមពិតទៅមុនខែមេសា ឆ្នាំ១៩៧៧ ឬខែឧសភា ឆ្នាំ១៩៧៧។ មិនថ្វីទេ ខ្ញុំនឹងសួរសំណួរជាក់លាក់ផ្សេងដល់សាក្សីវិញ។>

**ស៖** <កាល>ពីម្សិលមិញលោកសាក្សី លោកឆ្លើយអំពីកិច្ចប្រជុំមួយដែល តាជឹម ក៏បានចូលរួម ហើយមានការផ្តល់ការណែនាំដែលថាអតីតទាហាន លន់ នល់ ចាត់ពីអនុសេនីយ៍<ត្រី>ឡើងទៅគឺថាត្រូវតែបោសសម្អាត។ លោកថាវាមុនខែមីនា-<ខែមេសា> ឆ្នាំ១៩៧៧។ លោកអាចចាំទេ <ពាក្យលោកនិយាយថា “មុន” នោះ>មានរយៈប៉ុន្មានអាទិត្យ ប៉ុន្មានខែ ឬក៏ប៉ុន្មានឆ្នាំ<>?

[១៤:៣១:៤៥]

**លោក វៀល សន៖**

**ឆ៖** បាទ ខ្ញុំបាទមិនចាំទេ ព្រោះអត់បានគិត គ្រាន់តែដឹង ប៉ុន្តែមិនបានគិតទុកៗ។

**ស៖** ខ្ញុំដឹងថាវាមានការពិបាកចាំកាលបរិច្ឆេទឲ្យបានច្បាស់ អាចចាំសប្តាហ៍ណា<> ខែណា

នោះ<> ក៏ប៉ុន្តែលោកអាចជម្រាបបានទេ ថាមុនពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ឬក៏មុនការរំដោះប្រទេសនៅខែមេសា ១៩៧៥ ឬក៏២ឆ្នាំក្រោយពេលរំដោះនុ៎ង?

**ឆ៖** បាទ មុនជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ គឺជាពិសេស គឺកំពុងតែជម្លៀសហ្នឹងតែម្តងប្រកាស។

**ស៖** ដើម្បីឲ្យយល់ច្បាស់លាស់មែនទែននោះ គឺថាលោកបានឆ្លើយកាលពីម្សិលមិញអំពីកិច្ចប្រជុំ<>ដែល តាជឹម ចូលរួម<> ហើយលោក ឥឡូវនេះលោកឆ្លើយថាកិច្ចប្រជុំហ្នឹងគឺធ្វើឡើងមុនពេលជម្លៀសប្រជាជន អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

[១៤:៣៣:១២]

**ស៖** លោកអាចជម្រាបបានទេ មូលហេតុអីដែលនាំឲ្យលោកទៅចូលរួមក្នុងអង្គប្រជុំហ្នឹងដែរ? តើលោកចូលប្រជុំក្នុងឋានៈអ្វីដែរ? លោក តើលោកចូលប្រជុំហ្នឹងគឺក្នុងសិទ្ធិអំណាចលោកជាអ្វីដែរ?

**ឆ៖** ចូលប្រជុំនេះទើបក្រោយនេះទេ គឺខ្ញុំជាក្នុងសិទ្ធិជាពេទ្យ។ មន្ទីរពេទ្យតំណាងឲ្យមន្ទីរពេទ្យស្រុកមួយទៅប្រជុំរួមគ្នាជាមួយមេឃុំ មេភូមិទាំងអស់គ្នា។ ដល់មតិណែនាំ គេមិនណែនាំខ្ញុំទេ គេមិនណែនាំខ្ញុំពេទ្យទេ គេណែនាំឲ្យប្រយ័ត្នប្រយែងហ្នឹងតែមេភូមិ ហើយនិងមេឃុំទេ ព្រោះមេឃុំ មេភូមិអ្នកទទួលប្រជាពលរដ្ឋនោះ។ តែចំណែកខ្ញុំអត់ទេ។ ទទួលតែអ្នកឈឺ អ្នកណាឈឺរត់ទៅរកថ្នាំមានតិចតួចអីឲ្យទៅ។

**ស៖** ខ្ញុំដឹងហើយលោក ថាវាពេលវេលាវាយូរយារមកហើយ <ប៉ុន្តែខ្ញុំសុំឲ្យលោកព្យាយាមរកនឹកពីកាលបរិច្ឆេទនៃកិច្ចប្រជុំនោះ ក៏ដូចជាមូលហេតុ>ដែល<>លោក<ទៅ>ចូលរួមក្នុងប្រជុំ<នោះផង>ដែរ<។ តើលោកមានឋានៈអ្វី>នៅក្នុងរចនាសម្ព័ន្ធ<ដឹកនោះ?> ហេតុម៉េចបានជា<>លោក<>មានវត្តមានក្នុងពេលប្រជុំហ្នឹងដែរ?

[១៤:៣៤:៥៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំយល់ឃើញថា សំណួរនេះដូចគ្នាទេ។ គាត់បានឆ្លើយហើយសាក្សីថា គាត់<ទៅចូលរួមក្នុងកិច្ច

ប្រជុំនោះ>ក្នុងនាមជាតំណាងឲ្យមន្ទីរពេទ្យ លោកប្រធាន ខ្ញុំយល់ថាសំណួរនេះ ជាសំណួរច្រំដែល។

**លោក វ៉ិចទ័រ កូប៉េ៖**

អាចជាសំណួរច្រំដដែល ប៉ុន្តែមិនមានការហាមឃាត់មិនឲ្យសួរសំណួរដដែលក្នុងរបៀបមួយផ្សេង<ដើម្បីទាញយក>ចម្លើយ<នោះទេ។ ពីព្រោះថា>--

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ ព្រោះវាជាសំណួរច្រំដែល។ យើងមានសិទ្ធិមិនឲ្យសាក្សីសាក្សីឆ្លើយតបនឹងទម្រង់សំណួរឯណាដែលមិននាំឲ្យឈានទៅដល់រួមវិភាគទានក្នុងការស្វែងរកការពិត។

[១៤:៣៦:០៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

<មិនថ្វីទេលោកប្រធាន។>

**ស៖** លោកសាក្សី តើមានមនុស្សប៉ុន្មាននាក់ចូលរួមនៅក្នុងអង្គប្រជុំ<នោះ>?

**លោក វៀល សន៖**

**ឆ៖** បាទ មានប្រធានភូមិទាំងអស់ ប្រធានឃុំទាំងអស់ ហើយខ្ញុំបាទហ្នឹងតំណាងឲ្យមន្ទីរពេទ្យៗ ហើយនិងមន្ទីរផ្សេងៗទៀត ដូចជាមន្ទីរជាង មន្ទីរអីនៅជុំវិញស្រុកហ្នឹងចូលរួមប្រជុំទាំងអស់គ្នា។ ប៉ុន្តែដល់គេណែនាំពីការបោសសម្អាតអីហ្នឹង គេថាដោយឡែកនៅតាមភូមិ តាមអីហ្នឹង អាហ្នឹងគឺគេនិយាយមេភូមិដោយឡែក ប្រធានឈ្លបឃុំ ប្រធានឈ្លបភូមិអីហ្នឹងដោយឡែក ត្រង់ពេទ្យ គេអត់និយាយទេ។

**ស៖** សំណួររបស់ខ្ញុំ សួរលោកចាំទេថា មានមនុស្សប៉ុន្មាននាក់<?> អាច<ថា>១០នាក់ ឬក៏២០ ឬក៏៥០ ឬក៏១០០ ចូលរួមប្រជុំ?

**ឆ៖** បាទ ខ្ញុំមិន១បានរាប់ទេ ហើយព្រោះកាលនោះប្រជុំនោះ គ្មានធ្វើបញ្ជីវត្តមានធ្វើអីទេទៅដល់ប្រជុំតែម្តង គ្រាន់តែសួរថា ភូមិនោះមកអត់ ឃុំនោះមកអត់។ បានជួបជុំគ្នាហើយ ប្រជុំគ្មានបញ្ជីវត្តមានទេ។

[១៤:៣៧:៤៦]

**ស៖** តើ<នរណាជាអ្នក>ដឹកនាំអង្គប្រជុំ<នោះ>?

**ឆ៖** បាទ តាជឹម គាត់ជាលេខាស្រុកកាលនុ៎ង។

**ស៖** តើមាន<នរណាខ្លះទៀតអង្គុយក្បែរគាត់>នៅពេល<>ប្រជុំហ្នឹង<>?

**ឆ៖** បាទ កាលនោះ គ្មានទេ អត់មានអ្នកណាអង្គុយអែបអីទេ។ គ្មានអ្នកណាហ៊ានទៅអង្គុយអែបគណៈស្រុកអីអត់ទេកាលនោះ ខ្លាចដូចខ្លាអ៊ីចឹង។

**ស៖** នៅពេលគេរៀបចំអង្គប្រជុំហ្នឹង តើទីរួមខេត្តតាកែវ<>បានរំដោះហើយឬនៅ<>?

**ឆ៖** បាទ កាលនុ៎ង ប្រជុំនុ៎ងដូចអត់ទាន់រំដោះទេ ហើយក៏យ៉ាងម៉េចទេខ្ញុំភ្លេចអស់ ប៉ុន្តែដូចអត់ទាន់រំដោះទេ ព្រោះអត់ឃើញប្រជាជនមក។ ប្រជុំហ្នឹងមានពីរលើក លើកទី១ អាប្រជាពលរដ្ឋមកដល់ហ្នឹងហើយ ចាប់ប្រជុំ។ ហើយអានៅតាកែវនេះ ខ្ញុំអត់ដឹងផង ដឹងតែប្រជាពលរដ្ឋមកពីតាកែវមកអីនុ៎ងមកនៅត្រង់ឃុំតាភេមហ្នឹងច្រើនអ៊ីចឹង ហ្នឹងគេហៅគ្នាប្រជុំដោយឡែកទៅ។ ហ្នឹងមានខ្ញុំអីចូលរួមហើយ ព្រោះប្រជាជនមកដល់ហើយ មកដល់នៅវត្តមួយឈ្មោះវត្តចំប៉ា នៅខាងលិចផ្សារអង្គតាសោមហ្នឹងច្រើនអ៊ីចឹង គេជ្រើសរើសតាំងពីហ្នឹងទៅ។ ជំទប់លេខ១ អាណាជំទប់លេខ១ ឲ្យធ្វើជំទប់លេខ១វិញ អាណាស័ក្តិ៥ ឲ្យធ្វើស័ក្តិ៥វិញ ហ្នឹងទៅបាត់អស់ទៅ។ ហ្នឹងកាលឆ្នាំហ្នឹង គឺអ៊ីចឹង។

**ស៖** តើខ្ញុំមិន<ប្រាកដថា>ខ្ញុំយល់លោកបានទាំងអស់<>នោះទេ <លោកសាក្សី>។ លោកចាំទេ នៅពេលណាដែលទីរួមខេត្តតាកែវដួលរលំ?

**ឆ៖** បាទ ខ្ញុំបាទអត់ចាំ ភ្លេចបាត់អស់ យូរពេកហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដោយបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី រៀល សន។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី មុនពេលឈប់សម្រាកនេះ គឺយើងនិយាយគ្នាអំពីអង្គប្រជុំមួយ ដែលក្នុងអង្គប្រជុំហ្នឹង លោកនិយាយថាមានការនិយាយអំពីការបោសសម្អាត<អតីត>ទាហាន និង<អ្នករដ្ឋការរបប>លន់ នល់។ ឥឡូវ ខ្ញុំសូមនិយាយអំពីកិច្ចប្រជុំនេះឡើងវិញ។ លោកនិយាយថា <តា>ជឹម គឺជាអ្នកបើកអង្គប្រជុំ។ លោកចាំពាក្យពេចន៍របស់គាត់ផ្ទាល់ទេ? តើគាត់ប្រាប់អ្នកដែលចូលរួមប្រជុំហ្នឹងថា តើផែនការ<នោះត្រូវប្រតិបត្តិដោយរបៀបណា>? <>តើផែនការហ្នឹងត្រូវ<កើតឡើងដោយ>របៀបណា<>?

**លោក រៀល សន៖**

**ឆ៖** ខ្ញុំបាទមិនដឹងថា ផែនការ -- មិនដឹងថាគេគិតម៉េចទេ ប៉ុន្តែគេប្រកាសជាផែនការអ៊ីចឹងតែម្តងថា ឲ្យមើលប្រជាជនជម្លៀសមកហ្នឹង មានទាហាន មានប៉ូលិស មានជំទប់លេខ១ មានស្មៀណានេះហ្នឹង បោសត្រូវតែបោសសម្អាត ហើយធាតុពិត គេបញ្ជាក់គ្នាគេថា យើងត្រូវបោសសម្អាតតែពួកហ្នឹង ហើយនិងថែមទាំងដៃជើងទៀត ហើយនិងដៃជើងពួកហ្នឹង។

[១៥:០៥:០៦]

**ស៖** តើលោកចាំទេ ថា<តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បី>កំណត់បាន<ប្រជាជនជម្លៀស នោះជាអតីតទាហាន ឬអ្នករដ្ឋការរបប លន់ នល់?> តើផែនហ្នឹងគេអនុវត្តដោយរបៀបណា?

**ឆ៖** បាទ អនុវត្តចាប់ -- មិនមែន -- ចាប់ខ្លួនតែម្តង គឺឃាត់ខ្លួនអ្នកដែលមានស័ក្តិ មាននេះហ្នឹងទាហាន ហៅទៅឲ្យធ្វើទាហានវិញ។ អ្នកណាស័ក្តិ៤ ឲ្យទៅធ្វើស័ក្តិ៤វិញ ថាអ៊ីចឹង។ អ្នកណាជំទប់លេខ១ ទៅឲ្យធ្វើជំទប់លេខ១ ហ្នឹងវិញ ហើយហៅទៅៗបាត់អស់ទៅ។ រត់ ខ្លះហ្នឹងថា អត់មានស័ក្តិផងទាហាន ប្រាប់គេថាស័ក្តិ២ គេយកទៅឲ្យធ្វើស័ក្តិ២បាត់ទៅ។ ហ្នឹងអង្កាល់នុំងអ៊ីចឹង។

**ស៖** ប៉ុន្តែខ្ញុំអត់យល់ទេ<លោកសាក្សី។> លោកនិយាយថា អង្គប្រជុំហ្នឹងគឺធ្វើឡើងនៅមុន

ពេល<គេ>ជម្លៀសប្រជាជន នៅពេលនោះ គឺថាកំពុងតែ<នៅប្រយុទ្ធគ្នា>នៅឡើយ។ តើមានគេនិយាយអំពីតួនាទីរបស់ទាហាន <និង>តើគួរតែត្រូវធ្វើ<ចំពោះអ្នករដ្ឋការ និងនាយ>ទាហាន<>ទាំងនោះ?

**ឆ៖** បាទ បើតាមនេះនោះ និយាយ គេនិយាយប្រាប់តែប៉ុណ្ណឹង។ និយាយប្រាប់អង្គប្រជុំអាហ្នឹង គេមិនមែននិយាយប្រាប់ខ្ញុំទេ។ គេនិយាយប្រាប់អង្គប្រជុំទាំងអស់គ្នា ប៉ុន្តែធាតុពិតសំដៅទៅលើមេឃុំ មេភូមិ ឲ្យពិនិត្យពិច័យ មើលអាណាស័ក្តិប៉ុន្មាន អាណាពាក់អីប៉ុន្មានហ្នឹង ឲ្យដឹង ឲ្យបោសសម្អាត។ និយាយរួម ឲ្យបោសសម្អាត។

[១៥:០៧:១៥]

**ស៖** <តើគេត្រូវធ្វើដូចម្តេចដើម្បីឲ្យដឹងថាមនុស្សក្នុងចំណោមអ្នកដែលគេជម្លៀសនោះជាអតីតអ្នករដ្ឋការរបប លន់ នល់ ឬជាអតីតនាយទាហានរបប លន់ នល់?> តើនៅក្នុងការអនុវត្តជាក់ស្តែងនេះ គេអាចកំណត់មុខសញ្ញាហ្នឹងបានដោយរបៀបណា? <តើលោកអាចបំភ្លឺបន្តិចបានទេលោកសាក្សី?>

**ឆ៖** បាទ ធាតុពិតអង្កាល់ដែលទើបនឹងជម្លៀសមកមិនទាន់ដល់ភូមិផ្ទះហ្នឹង គឺគេមាននយោបាយ មួយថា អាណាពាក់ស័ក្តិ២មក១មុំ អាណាពាក់ស័ក្តិ១មកមុំអីអីចឹងទៅ អាណាជំទប់លេខ១ មកមុំមក ហើយដល់ហើយអាពាក់ស័ក្តិ២ គេប្រាប់ថាទៅពាក់ស័ក្តិ២វិញដដែល។ អាណាពាក់ស័ក្តិ១ទៅពាក់ស័ក្តិ១ ហើយយកទៅបាត់ទៅ ប្រពន្ធកូននៅនេះ។

**ស៖** លោកសាក្សី លោករៀបរាប់<ដូចជា>ពិបាកស្មុគស្មាញបន្តិច<ហើយ>។ សូមលោកពន្យល់ឲ្យលម្អិតបន្តិចមក ថាតើ<គេធ្វើដូចម្តេច? ព្រោះថា>មានអ្នក<ជម្លៀសមក>ពីភ្នំពេញហ្នឹង<ដល់ទៅ>រាប់រយពាន់នាក់<ឯណោះ>។ តើ <តា>ជឹម បានណែនាំថាយ៉ាងម៉េចដែរ ដើម្បីឲ្យអនុវត្តសេចក្តីសម្រេចនេះ?

[១៥:០៨:៥០]

**ឆ៖** បាទ តាជឹម គាត់ណែនាំដូចខ្ញុំលើកឡើងអីចឹង ប៉ុន្តែគាត់ណែនាំតែក្នុងស្រុកត្រាំកក់ហ្នឹងទេ។ មិនណែនាំនេះទេ ហើយជាពិសេស មនុស្សដែលជម្លៀសមកហ្នឹងមក១មួយក្រុម១ ហើយកន្លែងខ្លះ១នៅវត្តនេះ ខ្លះនៅវត្តនោះអីចឹងទៅ ប៉ុន្តែនៅក្នុងឃុំក្នុងស្រុកហ្នឹង។ អីចឹងហៅមេឃុំ មេភូមិហ្នឹងទាំងអស់ហ្នឹងគ្នាមក ប្រាប់អីចឹង ប្រាប់ដូចខ្ញុំថាអីចឹងឲ្យពិនិត្យពិច័យរឿងទាហាន ហើយនិងអ្នករដ្ឋការ។

**ស៖** បាទ ខ្ញុំព្យាយាមកែតម្រូវសំណួររបស់ខ្ញុំ។ <លោកសាក្សី ខ្ញុំសួរឲ្យបានខ្លីៗដើម្បីងាយយល់។ តើលោកចាំទេ បន្ទាប់ពីចេញពីប្រជុំនោះ រូបលោកផ្ទាល់នេះទទួលបានការណែនាំឲ្យធ្វើអ្វីខ្លះ>?

**ឆ៖** បាទ ចាំតើ! ខ្ញុំចាកចេញពីអង្គប្រជុំទៅកន្លែងវិញ អត់មានគេឲ្យធ្វើអី ទៅធ្វើពេទ្យវិញធម្មតា នៅកន្លែងពេទ្យហ្នឹងមើលអ្នកជំងឺ។

**ស៖** ខ្ញុំអត់យល់ទេ។ ពីខាងដើមលោកឆ្លើយថា<រហូតដល់ឆ្នាំ១៩៧៦>ឯណោះបាន<លោក>ចាប់ផ្តើមធ្វើ<ការនៅមន្ទីរពេទ្យ។> ហើយនៅពេលជាមួយគ្នាលោកនិយាយអំពីអ្នកដែលគេជម្លៀសនៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ លោកកំពុងតែច្របូកច្របល់ជាមួយកាលបរិច្ឆេទនៃកិច្ចប្រជុំនេះ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ លោកសួរខ្ញុំតែពីរឿងប្រជុំហ្នឹង អ៊ីចឹងប្រជុំហ្នឹងដូចខ្ញុំជម្រាបជូនលោកហ្នឹងតែប៉ុណ្ណឹង។

[១៥:១១:០៩]

**ស៖** ហើយជាការពិតហើយ ក៏ប៉ុន្តែខ្ញុំសួរថាតើលោកបានធ្វើអ្វី នៅពេលដែលកិច្ចប្រជុំចប់ទៅ? លោកថា លោកទៅមន្ទីរពេទ្យ ត្រឡប់ទៅមន្ទីរពេទ្យ។ ប៉ុន្តែចម្លើយរបស់លោកមួយ<> លោក<ប្រាប់ថាលោក>ចូលទៅធ្វើការនៅមន្ទីរពេទ្យ<នៅ>ឆ្នាំ<១៩៧៦> ឯណោះ<។> គឺ១ឆ្នាំកន្លះក្រោយពេលជម្លៀស។ ហើយមុននេះបន្តិចលោកនិយាយថា កិច្ចប្រជុំហ្នឹងធ្វើឡើងនៅមុនពេលជម្លៀស។ ដូច្នេះ<វាមិនអាចនោះទេ។> សំណួររបស់ខ្ញុំ គឺ<បន្ទាប់ពី>កិច្ចប្រជុំហ្នឹង<>ចប់ទៅ តើលោកធ្វើអ្វី?

**ឆ៖** ខ្ញុំមិនច្រំឡទេ ប្រហែលក៏ខ្ញុំច្រឡំមិនដឹង។ ប៉ុន្តែលោកសួរមកខ្ញុំថា កាលពីមុនឆ្នាំ៧៥ -- ពីមុនឆ្នាំចិតសិបប៉ុន្មាន -- ពីមុនដែលប្រជាជនជម្លៀសមក និងក្រោយប្រជាជនជម្លៀសមក។ ហ្នឹងខ្ញុំនិយាយតែត្រឹមមុនប្រជាជនៗជម្លៀសមក ក៏គាត់ប្រជុំប្រាប់ថាអ៊ីចឹងដែរ។ ដល់ក្រោយពីប្រជាជនមកហើយ ដែលមកដល់ចង្អុលយកទៅហើយ ថាស័ក្តិ២ អ្ហែង! ទៅពាក់ស័ក្តិ២វិញ ទៅបានទៅហ្នឹងអាហ្នឹងគឺក្រោយៗ៧៥។ ហើយបើអាពីមុននោះ ប្រជុំមិនទាន់មកដល់ផងប្រជុំប្រាប់ហើយ។ យើងមិនដឹងថាជម្លៀសហ្នឹងម៉េចផង យើងនៅមូលដ្ឋាន។

**ស៖** ឥឡូវនេះលោក<ហាក់ដូចជាកំពុង>និយាយ<ពី>កិច្ចប្រជុំនោះពីរលើក<ផ្សេងពីគ្នា>។ តើ <តា>ជឹម ជាចៅហ្វាយស្រុកហ្នឹងក៏ធ្វើជាអធិបតីភាពនៅក្នុងកិច្ចប្រជុំ<លើកទី២នោះដែរឬ>ទេ?

**ឆ៖** គឺគាត់អ្នកធ្វើជាអធិបតីភាពអង្គប្រជុំហ្នឹងទាំងពីរលើកហ្នឹង។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:១៣:២៧]

**ស៖** ឥឡូវខ្ញុំសូមនិយាយអំពីកិច្ចប្រជុំលើកទី១ គឺកិច្ចប្រជុំមុនពេលជម្លៀសប្រជាជន<។> កិច្ចប្រជុំ <ដែលតាជឹម បាននិយាយហ្នឹង>ចប់ទៅ <លោកក៏បាន>ចាកចេញទៅ<ដែរ តើលោកទទួលបានការណែនាំឲ្យធ្វើអ្វីខ្លះ?> តើលោកត្រូវធ្វើអ្វី<ខ្លះ>ក្រោយកិច្ចប្រជុំលើកទី១ចប់ទៅ<នោះ>?

**ឆ៖** អង្កាល់ហ្នឹងខ្ញុំនៅធ្វើៗស្រែផង ធ្វើជាងផង កាលមុនប្រជាជនជម្លៀសមកហ្នឹង។ ធ្វើស្រែផង ធ្វើជាងផ្ទះ ជាងធ្វើស្ពានតាមថ្នល់អីហ្នឹង នាយអាយ។

**ស៖** ខ្ញុំសួរសំណួរខាងដើមឡើងវិញ។ ក្នុងនាមលោកជាជាង<ជួសជុលម៉ាស៊ីន ឬក៏ត្រឹមជាអ្នក>ធ្វើស្រែ <ហេតុអ្វីបានជាគេ>អនុញ្ញាតឲ្យចូលរួមប្រជុំអ៊ីចឹង<?> តើលោកកាល<នោះលោក>មានតួនាទីអ្វីដែរ<ដើម្បីនិយាយអំពីការបោសសម្អាតអតីតនាយទាហាន និងអ្នករដ្ឋការលន់នល់ទៅវិញ? ហេតុអ្វីបានជាលោកមានវត្តមានក្នុងកិច្ចប្រជុំនោះ>?

**ឆ៖** បាទ កាលហ្នឹងខ្ញុំគ្មានតួនាទីជាអ្វីទេ ប៉ុន្តែវាបានការអប់រំខ្លះពីយាយបឿន ពីអីហ្នឹង ហើយចេះតែទៅៗ។ មានអប់រំខ្លះទៅស្តាប់គេនិយាយ អាហ្នឹងគេអត់ថាអីទេ គេមិនថាអីទេ យើងបាន--

[១៥:១៥:១៣]

**ស៖** <>ចម្លើយរបស់លោក<ថា>នៅក្នុងកិច្ចប្រជុំនេះ មុនពេលជម្លៀស<ប្រជាជន> គេបានសម្រេចត្រូវសម្លាប់<មនុស្សជាច្រើននាក់ចោល> គឺលោក<មានវត្តមានក្នុងកិច្ចប្រជុំនោះ> ដោយគ្មានតួនាទីអ្វី<សោះ។> អ៊ីចឹង<មែនដែរឬទេ>?

**ឆ៖** គ្មានទេ។ ប៉ុន្តែដូចខ្ញុំលើកឡើងអ៊ីចឹងថា កាលហ្នឹងមានជនចម្រើន យុវជនចម្រើន យុវនារីចម្រើន អាណាបានចម្រើនខ្លះហ្នឹងបានទៅជិតអង្គប្រជុំហ្នឹង។ អ្នកណាអត់ចម្រើន អត់ទេ។

**ស៖** ឥឡូវនេះ ខ្ញុំសូមនិយាយអំពីកិច្ចប្រជុំលើកទី២<។> គឺកិច្ចប្រជុំ<បន្ទាប់ពី>លោកធ្វើការនៅមន្ទីរហើយ<។> ចម្លើយរបស់លោកថា <>តាជឹម <>ធ្វើ<ជាប្រធាន>ប្រជុំ<>នេះដែរ។ <តើ> លោកចាំទេ នៅក្នុងអង្គប្រជុំលើកទី២ តាជឹម និយាយ<អ្វី>ខ្លះដែរ?

**ឆ៖** បាទ នៅលើកទី២នេះ ក៏និយាយដូចអង្កាលលើកទី១ដែរ ព្រោះប្រជាជនមកដល់ហើយនៅពេញភូមិ។ អ៊ីចឹងឲ្យមេភូមិ មេឃុំហ្នឹងពិនិត្យ ហើយដូចផែនការលើកមុនអ៊ីចឹង ទាហានចាប់ពីពាក់អាត់សួដង់ឡើងទៅ ប៉ូលិសក៏អ៊ីចឹងដែរ ប៉ុន្តែផ្នែករដ្ឋបាលចាប់ពីជំទប់លេខ១ឡើងទៅ។ អាហ្នឹងក៏យើងត្រូវបោសសម្អាតដែរ។

[១៥:១៧:១១]

**ស៖** លោកចាកចេញពីកិច្ចប្រជុំលើកទី២ តើគេណែនាំឲ្យលោកធ្វើអីជាក់លាក់<ដែរឬទេ>? តើគេមានណែនាំឲ្យលោកធ្វើអ្វីនៅឯមន្ទីរពេទ្យហ្នឹង?

**ឆ៖** បាទនៅមន្ទីរ គេអត់មានណែនាំអីផង ខ្ញុំបាទ។ ហ្នឹងវាពេទ្យ វាមិនមែន គេចង់ណែនាំថា មេភូមិ មេឃុំ និងឈ្លបឃុំផ្នែកឃោធាហ្នឹង គេចង់ គឺខ្ញុំពេទ្យហ្នឹងគ្រាន់តែហៅទៅ ឲ្យដឹង ឲ្យឮអីចឹង។ ប៉ុន្តែត្រង់ណែនាំឲ្យអនុវត្តផែនការហ្នឹង គឺណែនាំមេភូមិ មេឃុំ និងឈ្លបឃុំ។

**ស៖** លោកសាក្សី លោកបាននិយាយថា នៅក្នុងកិច្ចប្រជុំលើកទី២នេះ<>និយាយអំពី<អតីត> ទាហាន <>និង<អ្នករដ្ឋការ របប> លន់ នល់ គឺត្រូវបានកំណត់ជាគោលដៅដែរ។ តើលោកដឹង <ដោយរបៀបណា>ថា ប្រជាជនដែលគេបានកំណត់គោលដៅ<ហើយ ត្រូវគេ>យកទៅសម្លាប់ ចោល? <>

**ឆ៖** ខ្ញុំបាទដឹងដោយឃើញផ្ទាល់ បងថ្លៃខ្ញុំមកដល់ គ្រាន់តែមកដល់លើផ្ទះ គាត់ឡើងលើផ្ទះមុន ប្រពន្ធមិនទាន់ឡើងផង ថ្ងៃមកទាញចុះយកទៅបាត់ បងថ្លៃ អាហ្នឹងផ្ទះខ្ញុំផ្ទាល់ ហើយពូខ្ញុំផ្ទះជិតហ្នឹង យកយប់ ខ្ញុំមិនដឹងថា អ្នកណាអ្នកយកទេ ប៉ុនយកយប់។ អាហ្នឹងពូខាងប្រពន្ធ ដល់ពូខាងខ្ញុំទៀត គាត់ ត្រូវផែនការពាក់ស័ក្តិ៤ ឮគេថាឲ្យទៅពាក់ស័ក្តិ៤រត់ប្រសេចប្រសាច នាំកូនទៅ គេមិនឲ្យយកកូនទៅ ទៅពាក់ស័ក្តិ៤បាត់ អត់ទាន់ឃើញមកវិញរហូតពេលឥឡូវ។ ហើយបងមួយឈ្មោះ រៀល អឹម ធ្វើ ប៉ូលិសដែរ ដូចបងថ្លៃអីចឹងដែរ ធ្វើប៉ូលិសពាក់អាត់ស្ទូដង់ ក៏រត់ទៅធ្វើប៉ូលិសតាមគេពាក់អាត់ស្ទូដង់ បាត់រហូតទល់ឥឡូវហ្នឹងមក។ ហ្នឹងខ្ញុំដែលយល់ដឹងហ្នឹងតាមហ្នឹង តាមឃើញអីចឹង។

[១៥:១៩:៥៥]

**ស៖** ខ្ញុំយល់ហើយ លោកកំពុងតែព្យាយាម<យក>បទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកជាមួយពូ ជាមួយបងថ្លៃ <ទើបនាំឲ្យ>លោក<សន្និដ្ឋាន វា>ថាគឺលទ្ធផលនៃកិច្ចប្រជុំ<ពិភាក្សាគ្នាលើ>ការ សម្លាប់<អតីតអ្នករដ្ឋការ>លន់ នល់ <ដែល តាជឹម ដឹកនាំនោះមែនទេ?> តើដោយសារតែបទ ពិសោធន៍ផ្ទាល់ខ្លួន រឿងរ៉ាវរបស់សាច់ញាតិហ្នឹង វានាំឲ្យលោកសន្និដ្ឋានថាបែបនេះ ឬយ៉ាងម៉េច?

**ឆ៖** បាទ សន្និដ្ឋានម៉េច ខ្ញុំស្តាប់អត់បានទេនេះ។

**ស៖** ខ្ញុំរៀបសំណួរឡើងវិញ។ លោកបានផ្តល់ឧទាហរណ៍អំពីបងថ្លៃ និងអំពីពូរបស់លោក។ លោកថាអ្នកទាំងពីរនេះត្រូវបានបាត់ខ្លួនរហូត។ សំណួររបស់ខ្ញុំនិយាយអំពីអង្គប្រជុំដែលដឹកនាំដោយ

តាជឹម។ តើ តាជឹម បាននិយាយនៅក្នុងអង្គប្រជុំហ្នឹងថា<ត្រូវយកអតីត>ទាហាន និង<អ្នករដ្ឋការរបប> លន់ នល់ <>ទៅសម្លាប់ចោល<មែន>ដែរទេ?

**ឆ៖** តាជឹម គាត់មិនថាសម្លាប់ចោលទេ គាត់ថាបោសសម្អាត។ គាត់មិនយកពាក្យសម្លាប់ចោលមកនិយាយ គាត់និយាយរឿងបោសសម្អាត។ យើងបប្អូលគ្នាបោសសម្អាត។

[១៥:២១:២៦]

**ស៖** តើ<>លោកផ្ទាល់ធ្លាប់បានឃើញការសម្លាប់<អតីត>ទាហាន ឬ<អ្នករដ្ឋការរបប> លន់ នល់ <>ដែរទេ?

**ឆ៖** បាទ គឺអត់ដែរទេ។

**ស៖** តើលោកដឹងទេថា<នៅក្នុងស្រុក១០៥នេះ គេគ្រាន់តែយក>អតីតទាហាន និង<អ្នករដ្ឋការរបប> លន់ នល់ <>ទៅអប់រំកែប្រែ ដោយគេមិនសម្លាប់ចោល<>ដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំរៀបសំណួរខ្ញុំឡើងវិញលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកមានដឹងអំពីការអប់រំ<កែប្រែ អតីត>ទាហាន លន់ នល់ ឬ<អ្នករដ្ឋការរបប> លន់ នល់ <ដែរឬ>ទេ?

**លោក វៀល សន៖**

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ។

[១៥:២២:៤២]

**ស៖** តើលោកដឹង<>ក្រាំងតាចាន់ <ឈ្មោះជាផ្លូវការជាអ្វី>ដែរ<ឬទេ>?

**ឆ៖** ហៅថា ក្រាំងតាចាន់។

**ស៖** <តើឈ្មោះជា>ផ្លូវការរបស់<ទីកន្លែងនោះជាអ្វី? តើឈ្មោះជាផ្លូវការនៃទីកន្លែងនោះ> នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ<មានឈ្មោះអ្វី>?

**ឆ៖** តាមពិតទៅក្រាំងតាចាន់ហ្នឹង ខ្ញុំបាទក៏ខ្លាច មនុស្សម្នាជុំវិញហ្នឹងក៏ខ្លាច។ ក្រាំងតាចាន់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្នឹងគឺជាគុកសម្រាប់ដាក់អ្នកទោស ដែលអ្នកណាគេថាតែមានទោសហ្នឹងយកទៅដាក់ហ្នឹង។

**ស៖** បាទត្រឹមត្រូវហើយ<លោកសាក្សី> ប៉ុន្តែសំណួរខ្ញុំ<សួរថា> តើឈ្មោះផ្លូវការរបស់កន្លែង<>ក្រាំងតាចាន់ហ្នឹងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គេហៅ<>វា<>ថាយ៉ាង<ដូចម្ដេច>?

**ឆ៖** កាលដែលមិនទាន់ធ្វើមន្ទីរឃុំឃាំងហ្នឹង គេហៅត្រពាំងតាចាន់តែម្ដង។ មានត្រពាំងមួយនៅពីលិចហ្នឹង ហៅថាត្រពាំងតាចាន់។ បើតាមខ្ញុំដឹងយូរហើយ មិនដឹងម៉េច ប៉ុនហៅត្រពាំងតាចាន់។

**ស៖** ខ្ញុំសូមជួយប្រាប់លោកបន្តិចចុះ<លោកសាក្សី។ តើឈ្មោះ>"មន្ទីរអប់រំកែប្រែ" ស្រុក ១០៥ តើ<លោកនឹកឃើញដែរឬ>ទេ?

**ឆ៖** ខ្ញុំបាទមិនយល់ទេពាក្យនេះ ពាក្យគេថាកែប្រែហ្នឹង គឺខ្ញុំអត់យល់ទេ។

[១៥:២៥:០០]

**ស៖** លោកធ្លាប់ឮពាក្យថា "អប់រំកែប្រែ"នេះដែរទេ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** បើតាមខ្ញុំបាទគិតទៅ អប់រំកែប្រែហ្នឹង គឺដូចជាមិនដែលឮទេ ហើយក៏ខ្ញុំភ្លេចក៏មិនដឹង អត់ដែលឮផង ហើយមិនដឹងគេអប់រំកែប្រែឯណា អប់រំឯណាអីឯណា បើតែខុសមានកំហុសអីបន្តិចបន្តួចអ៊ីចឹង បាត់ខ្លួនបាត់អ៊ីចឹងទៅ។ អាហ្នឹងមិនដឹងថា កែប្រែ កន្លែងកែប្រែហ្នឹងនៅឯណា ប៉ុន្តែត្រង់ថា ក្រាំងតាចាន់ជាមន្ទីរកែប្រែ អាហ្នឹងខ្ញុំមិនដឹងដែរ ខ្ញុំអត់ដឹងពីព្រោះខ្ញុំអត់ដឹង។

**ស៖** ប្រហែលជាខ្ញុំយល់លោកមិនច្បាស់ទេ<លោកសាក្សី។> គិលានុបដ្ឋាយិកាម្នាក់<>ធ្វើការនៅកន្លែងលោកហ្នឹង ត្រូវបានគេបញ្ជូនទៅក្រាំងតាចាន់។ លោក<ឃើញ>នារីនោះ នៅពេលដែលលោកទៅក្រាំងតាចាន់។ <តើលោកដឹងទេថា>នារីម្នាក់<ហ្នឹង> នៅទី<នោះ>ធ្វើអីដែរ? <តើគាត់ជាអ្នកទោសឬ? គាត់ត្រូវគេ>អប់រំកែប្រែ<រួចហើយ>?

**ឆ៖** ខ្ញុំបាទមិនដឹងទេគេ ប៉ុន្តែគេយកទៅ ដែលពេលដែលខ្ញុំឃើញវាហ្នឹង គឺកំពុងអង្គុយដាំបាយ – ដាំបាយឆ្នាំងតូចមួយទេ មិនដឹងថាគេឲ្យធ្វើអី គេអត់មាននិយាយប្រាប់ផង។ ហើយខ្ញុំបាទទៅបាញ់ថ្នាំហ្នឹង គឺគេឲ្យបាញ់ថ្នាំ គេអត់មានឲ្យទៅមាត់ទេ ទៅមាត់រកអ្នកនេះដេកក្នុងនេះហ្នឹងរឿង អត់បានទេ។ អ៊ីចឹង ខ្ញុំខ្លាចនោះ ខ្លាចពេកហើយ។

[១៥:២៧:០៣]

**ស៖** ខ្ញុំសួរ<លោកពាក់ព័ន្ធនឹង>ប្រធានបទ<ដដែលនេះ។ ក្នុង>ចម្លើយរបស់លោកជូនមន្ត្រីស៊ើបអង្កេត <E3/19.1.21> នៅក្នុងចម្លើយលេខ១០៥ លោកនិយាយអំពីអ្នកទោសដែលគេបញ្ជូនទៅ

គុក២០៤ ហើយពាក់ព័ន្ធនឹងគុកនេះ លោកនិយាយអំពីទោសស្រាល និងទោសធ្ងន់។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ តើវាមានភាពខុសគ្នាយ៉ាង<ដូចម្ដេច>រវាងទោសស្រាល និងទោសធ្ងន់នេះ?

**ឆ៖** ខ្ញុំបាទមិនសូវដឹងច្បាស់ដែររឿងៗហ្នឹង ប៉ុន្តែដឹងថាអ៊ីចេះ ដឹងថាមានប្រជាជនគេបញ្ជូនទៅមន្ទីរឃុំឃាំង២០៤ហ្នឹង ជួនកាលខ្លះឃើញមកវិញ ជួនកាលខ្លះអត់ឃើញមកវិញទេ បាត់រហូតទៅ ខ្លះមកវិញៗភាគច្រើន បាត់តិចទេ។

**ស៖** ពេលពួកគេត្រឡប់មក<ពីអប់រំកែប្រែ>វិញ តើគេ<>ប្រើពាក្យថា "អប់រំកែប្រែ<រួចហើយ>"<ដែរឬ>ទេ<?> ឬក៏<គេ>មិនដែលប្រើ<ពាក្យនោះសោះ>?

[១៥:២៨:៣៩]

**ឆ៖** បាទមិនដែលប្រើទេ អ្នកទាំងអស់ហ្នឹង ប្រើថាគុកអ៊ីចឹងតែម្ដង ហៅថា"គុក"អ៊ីចឹង។

**ស៖** លោកសាក្សី ខ្ញុំនឹងចូលទៅប្រធានបទមួយទៀត។ គឺ<សំណួរ->ចម្លើយលេខ១០ នៅក្នុងឯកសារ E3/5511 មន្ត្រីស៊ើបអង្កេតបានសួរសំណួរទៅលោកដូចតទៅនេះ, ខ្ញុំនឹងអានសំណួរ ហើយនិងចម្លើយនេះ។ យើង<កំពុង>និយាយអំពីអង្គប្រជុំដែល<យើង>ទើបតែ<បានពិភាក្សាគ្នាពីមុននេះ>។ សំណួរ "នៅក្នុងកិច្ចប្រជុំនោះ តើ<គេមាននិយាយ>អំពីប្រជាជនវៀតណាមដែរឬទេ? ឆ្លើយ៖ ពុំមានការលើកឡើងអំពីប្រជាជនវៀតណាមទេ ប៉ុន្តែក្រោយមកប្រជាជនវៀតណាមដែលរស់នៅទីនោះជាយូរមកហើយ បានបាត់ខ្លួនអស់"។ លោកចាំទេថា លោកបានឆ្លើយបែបនេះជូនមន្ត្រីស៊ើបអង្កេត?

**ឆ៖** បាទ ចាំ។

**ស៖** តើលោកបានឮពាក្យនៅក្នុងអង្គប្រជុំទី១ ឬក៏បានឮពាក្យនេះនៅក្នុងអង្គប្រជុំលើកទី២?

**ឆ៖** បាទ ឮពាក្យអី? អត់ដឹងពាក្យអីផង អត់បានស្ដាប់មិនបាន។ ពាក្យអ្វី? ពាក្យថាម៉េច?

**ប្រធានអង្គជំនុំ៖**

លោក រ៉ិចទ័រ កូប៉េ សួរ តាំងសំណួរម្ដងទៀត ព្រោះគាត់ស្ដាប់មិនយល់ទេ។

[១៥:៣០:៣៦]

**សួរដោយលោក រ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំ<>អានសំណួរ<ឲ្យ>លោកស្ដាប់<>អំពីការបាត់ខ្លួន<នៃ>ប្រជាជន<វៀតណាម>ដែលរស់នៅក្នុងភូមិនោះ។ លោកចាំទេ តើ<គេមានពិភាក្សាគ្នា>អំពី<>ប្រជាជនវៀតណាម<>នៅ

កិច្ចប្រជុំ<ដែលលោកបានចូលរួមដែរឬទេ>?

**លោក វៀល សនៈ**

**ឆៈ** បើតាមពិតទៅ ក្រោយពីប្រជាជនជម្លៀសមកហ្នឹង អង្គប្រជុំណាក៏និយាយដែរ និយាយពីប្រជាជនវៀតណាម ប្រជាជនកម្ពុជាក្រោមទាំងអស់ គ្រប់តែអង្គប្រជុំ បើប្រជុំនៅភូមិក៏មេភូមិនិយាយអ៊ីចឹង។

**សៈ** តើលោកចង់និយាយថាម៉េចដែរ ពាក្យថា"បាត់ខ្លួន"ហ្នឹង?

**ឆៈ** បាទ ខ្ញុំមិនដឹងថាម៉េចទេ ប៉ុន្តែវាបាត់អត់ឃើញមក ថាបាត់ខ្លួនអ៊ីចឹងទៅ។ បើថាស័ក្តិ២អ៊ីចឹង ហើយគេយកទៅពាក់ស័ក្តិ២ មិនដឹងយកទៅពាក់ឯណា វាបាត់មនុស្សហ្នឹង ទៅហើយអ៊ីចឹងមិនដឹងថាម៉េចដែរ។

**សៈ** ខ្ញុំសុំទោសប្រហែលជាដោយសារសំណួរខ្ញុំពិបាក<យល់>បន្តិច ប៉ុន្តែយើងកំពុងតែនិយាយគ្នាអំពីប្រជាជនវៀតណាម<>ដែលរស់នៅភូមិ<នោះ>។ <ក្នុង>ចម្លើយរបស់លោកៗប្រើ<>"បាត់ខ្លួនអស់"។ តើ <ពាក្យ "បាត់ខ្លួន" ហ្នឹង>លោកនិយាយថា<យ៉ាងដូចម្តេចដែរ>?

**ឆៈ** បាទ បាត់ខ្លួនអស់ គឺទៅពីផ្ទះអស់ ទាំងកូន ទាំងប្រពន្ធអី អីវ៉ែអីវ៉ាន់អីហ្នឹងរែក មិនដឹងទៅណាបាត់ទាំងយប់ហ្នឹង គ្មានអ្នកណាដឹងទេ អត់អ្នកណាដឹងទេ រើទៅបាត់អស់។

[១៥:៣២:៥២]

**សៈ** តើលោកបានឮ -- ខ្ញុំសូមរៀបសំណួរឡើងវិញ<។> តើវាអាចទេដែលថា<ខ្មែរក្រហម>បណ្តេញ<ប្រជាជនវៀតណាមទាំងនោះ>ទៅប្រទេសវៀតណាមវិញដែរឬទេ?

**ឆៈ** បាទ ខ្ញុំមិនដែលឮថាបណ្តេញឲ្យទៅ ប៉ុនអត់ដែលសោះ ស្រាប់តែបាត់អស់អ៊ីចឹង ខ្ញុំអត់ដែលឮគេថាបណ្តេញអីអត់ទេ។

**សៈ** <ដើម្បី>ឲ្យ<កាន់តែ>ច្បាស់ លោកសាក្សី លោកកំពុងនិយាយអំពីឆ្នាំ១៩៧៥ <និង១៩៧៦។> លោកមាន<>ដឹងអំពីការបណ្តេញប្រជាជនវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា <>ឲ្យទៅ<ប្រទេស>វៀតណាមវិញ<ដែរឬ>ទេ?

**ឆៈ** ខ្ញុំបាទមិនដឹងទេ។ ប្រជាជនវៀតណាមនៅក្នុងប្រទេសកម្ពុជា ហើយបណ្តេញទៅវិញហ្នឹងគឺខ្ញុំអត់ដឹងទេ អត់ដឹងព្រោះខ្ញុំធ្វើពេទ្យនៅតែកន្លែងពេទ្យ ម៉េចដឹង។

**សៈ** វាត្រឹមត្រូវទេ ដែលខ្ញុំអាចនិយាយថាលោកអត់ដឹង<>ទាល់តែសោះចំពោះជោគវាសនា

របស់ប្រជាជនវៀតណាមទាំងនោះ<មែនដែរឬទេ>?

**ឆ៖** បាទ ខ្ញុំបាទមិនដឹងទាល់តែសោះ។

**ស៖** <លោកប្រធាន ខ្ញុំមានសំណួរនៅសល់មួយ ឬពីរសំណួរប៉ុណ្ណោះ។> លោកសាក្សីកាលពីម្សិលមិញនៅដើមដំបូងនៃការផ្តល់សក្ខីកម្មរបស់លោកៗបានប្រើពាក្យ "បដិវត្តន៍វប្បធម៌" លោក<ក៏> បានពន្យល់ "បដិវត្តន៍វប្បធម៌" នេះ<។ តើ>លោក<ធ្លាប់ឃើញពាក្យនេះ នៅ>ក្នុងទស្សនាវដ្តី"ទង់បដិវត្ត" ឬក៏ឮ<>ពាក្យ<>"បដិវត្តន៍វប្បធម៌" នេះតាមរយៈការផ្សាយតាមវិទ្យុ<ដែរឬទេ>?

[១៥:៣៥:១១]

**ឆ៖** ពាក្យៗ "បដិវត្តន៍វប្បធម៌" នេះ ខ្ញុំចេះតាំងពីសម័យខ្ញុំនៅស្ទើរ ខ្ញុំមិនទាន់ពេញវ័យសម័យៗម៉ៅ សេទុង ធ្វើបដិវត្តន៍ហើយមកហ្នឹង ដឹងតែម្តង ដឹងៗពាក្យហ្នឹង ដឹងពីហ្នឹងមក ដឹងពីប្រទេសចិនវិញ។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី ប៉ុន្តែតើលោកធ្លាប់បានអានពាក្យហ្នឹងនៅក្នុងឯកសារ<បោះពុម្ពផ្សាយជា>ផ្លូវការណាមួយរបស់ខ្មែរក្រហម ឬហៅថាកម្ពុជាប្រជាធិបតេយ្យ<> ដូចជា<នៅក្នុងទស្សនាវដ្តី>"ទង់បដិវត្ត"<ដែរឬទេ>?

**ឆ៖** បាទ មិនដែលទេ គ្រាន់តែអាទង់បដិវត្តហ្នឹង អត់ដែលឃើញ ទើបឃើញនៅកន្លែងតុលាការហ្នឹងតែម្តង ខ្ញុំមិនដែលឃើញផង។ ខ្ញុំកាលហ្នឹងអត់ដែលឃើញទេ។ ឃើញរូបថតនៅក្នុងតុលាការហ្នឹងតែម្តង។ កាលនោះ ខ្ញុំអត់ដែលឃើញ ប៉ុន្តែខ្ញុំគ្រាន់តែសូមជម្រាបចេះ ខ្ញុំមិនមែនជាបក្ខជនមិនជាអី គេអត់ឲ្យឃើញទេ។ បើបក្ខជនហ្នឹង គេមានឃើញ ខ្ញុំអត់ ដូចថា ប្រជាជនសាមញ្ញធម្មតាអីចឹង ប៉ុណ្ណឹង។

[១៥:៣៦:៥៥]

**ស៖** តើលោកធ្លាប់ឮពាក្យ "បដិវត្តន៍វប្បធម៌" នេះ<>តាមវិទ្យុផ្សាយសំឡេងរបស់កម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** បាទ មិនដែលមានឮវិទ្យុទេ ព្រោះខ្ញុំអត់មានវិទ្យុស្តាប់ អត់ៗដែលមាន អត់ដែលមានវិទ្យុស្តាប់រហូតទាល់តែមាន ទើបតែមានឥឡូវហ្នឹង។

**ស៖** ខ្ញុំនឹងអានចម្លើយរបស់លោក ដែលឆ្លើយជូនមន្ត្រីស៊ើបអង្កេត គឺសំណួរ-ចម្លើយលេខ<២០០> ក្នុងឯកសារ E319.1.21, "សំណួរ៖ សួរតើលោកជឿជាក់លើបដិវត្តន៍ដែរឬទេ? លោក

ឆ្លើយ៖ ដំបូង ខ្ញុំស្រឡាញ់បដិវត្តន៍ ប៉ុន្តែ<ក្រោយមក>ដល់ឮថា បដិវត្តន៍វប្បធម៌ ខ្ញុំលែងស្រឡាញ់តែម្តង។" តើខ្ញុំអាចនិយាយបានថា លោកមិនដែលធ្លាប់បានឮពាក្យនេះនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យទេ? តើខ្ញុំអាចនិយាយអ៊ីចឹងបានទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

[១៥:៣៨:៤០]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ ទាក់ទងទៅនឹងប្រធានបទ<នេះ> តើលោកធ្លាប់ឮពាក្យ "ឆ្វេងនិយម" និង"ស្តាំនិយម" <> ជាពាក្យខ្មែរក្រហម ឬក៏របបកម្ពុជាប្រជាធិបតេយ្យហ្នឹងបានប្រើប្រាស់ទាំងនៅក្នុង"ទង់បដិវត្ត" <ឬ>តាមវិទ្យុ<ដែរឬទេ>?

**ឆ៖** បាទ ខ្ញុំមិនដឹងទេ អត់ដឹងថា ពួកឆ្វេងនិយមហ្នឹងអី ស្តាំនិយមអី អត់ដឹងផង។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអានសម្រង់ខ្លីមួយចេញពី"ទង់បដិវត្ត" <ចេញផ្សាយក្នុង>ខែកក្កដា <ឆ្នាំ១៩៧៦> ដែលឯកសារ នេះគឺដាក់លើអ៊ីនធីហ្វេស E3/4, ERN 00268924 ជាអង់គ្លេស, ហើយខ្មែរ 0062918 <*(ស៊ីក)*>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** "គឺកិច្ចប្រជុំនោះត្រូវបានរៀបចំដើម្បីៗកសាងសាខាបក្សនៅតាមសហករណ៍ វាដាច់ខាតត្រូវតែកម្ចាត់<ទស្សនៈ>ឆ្វេងនិយម និង <>ស្តាំនិយម។ <ទស្សនៈ>ឆ្វេងនិយមមានន័យថា <ពុំ>មានជឿ<លើ>ក្នុងមហាជន មើលងាយ<ចលនា>មហាជន ហើយមើលមហាជន<ថា>ជាខ្លាំង។ ឯ<> ស្តាំនិយមមានន័យថា អ្នកដែលធ្វើការ ធ្វេសប្រហែស ខ្ជីខ្ជាដោយមិន<ប្រកាន់ខ្ជាប់នូវ>គោលការណ៍<គ្រឹះរបស់លក្ខន្តិកៈរបស់បក្ស>"។ <លោកសាក្សី>តើចំណុចនេះ ជួយរំឭកដល់ការចងចាំរបស់លោកបានខ្លះទេ?

[១៥:៤០:៣៤]

**លោក រៀល សន៖**

**ឆ៖** ដូច ខ្ញុំដូចជាខ្ញុំចងចាំមិនបានទេ ភ្លេច។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៀត អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកសាក្សីខ្ញុំមានសំណួរមួយចំនួន ដើម្បីសួរបញ្ជាក់បន្ថែមទាក់ទងទៅនឹងពេលវេលា ដែលលោកឆ្លើយថា លោកចូលមកធ្វើការនៅក្នុងមន្ទីរពេទ្យស្រុក។ លោកអាចបញ្ជាក់បានទេថា ឆ្នាំណាពិតប្រាកដ? ពីព្រោះខ្ញុំឃើញមានអត្ថបទខ្លះនិយាយពី -- បានបញ្ជាក់រួចហើយពីឆ្នាំ១៩៧៦ ដែលមានគណៈស្រុកជាអ្នកចាត់តាំងលោក ក៏ប៉ុន្តែខ្ញុំបានស្តាប់ឮនូវការរៀបរាប់របស់លោកទាក់ទងទៅនឹងការទិញដូរវត្ថុធាតុដើមផ្សេងៗយកមកធ្វើជាថ្នាំ ដែលធ្វើឲ្យខ្ញុំមានចម្ងល់ថា តើការទិញដូរនោះវាកើតឡើងនៅពេលណា? ហើយលោកពិតប្រាកដចូលមកធ្វើការនៅក្នុងមន្ទីរពេទ្យហ្នឹងនៅពេលណា? សូមឲ្យលោកជួយបញ្ជាក់បានទេ?

**លោក រៀល សន៖**

**ឆ៖** បាទ ក្នុងការទិញដូរអីវ៉ែអីវ៉ាន់ ទិញ ព្រោះអីចេះ ព្រោះផ្ទះខ្ញុំហ្នឹងជាអ្នកលក់ដូរ។ អ៊ីចឹងទៅទិញហូរហែតាំងពីមុនឆ្នាំ៧៥ មករហូតមកដល់រហូតក្រោយដែរ ខ្ញុំធ្វើពេទ្យហើយ ក៏នៅតែទិញដែរ។ ទៅទិញមេថ្នាំមេអីមកលាយថ្នាំនៅមន្ទីរធ្វើថ្នាំពេទ្យហ្នឹង។

[១៥:៤២:៥៣]

**ស៖** បាទ សំណួររបស់ខ្ញុំចង់បញ្ជាក់ថា តើការទិញដូរនោះមុនឆ្នាំ៧៥ ហើយមែនទែនលោកធ្វើការនៅក្នុងមន្ទីរពេទ្យមុនឆ្នាំ៧៥ ឬក៏ក្រោយឆ្នាំ៧៥ លោកអាចបញ្ជាក់ចំណុចនេះបានទេ?

**ឆ៖** ខ្ញុំធ្វើពេទ្យក្រោយឆ្នាំ៧៥ ទេ។ ប៉ុន្តែខ្ញុំនិយាយអំមិញដូចជាច្រឡំថា ព្រោះផ្ទះខ្ញុំលក់ថ្នាំ លក់ថ្នាំពេទ្យបន្តិចបន្តួចអីហ្នឹង គឺលក់តាំងពីយូរយារមកហើយ។ អ៊ីចឹងត្រូវទៅទិញដូរហ្នឹង ទិញរហូតយកមកទុកលក់ជូនបងប្អូនឈឺហ្នឹង។ ដល់ខ្ញុំធ្វើពេទ្យហើយក៏នៅតែទៅទិញដែរ ខ្ញុំទៅទិញមេថ្នាំយកមកលាយតាមគណៈស្រុកគាត់ស្នើឲ្យធ្វើថ្នាំ ហើយខ្ញុំថាអត់មានលុយ គាត់អង្គាល់នុំងមានលុយខ្លះ ដល់ក្រោយមកហ្នឹង អត់លុយ លែងចាយលុយហ្នឹង យកជ្រូកយកអីទៅដូរជាមួយវៀតណាម។ អ៊ីចឹងទៅបានខ្លះៗមកហ្នឹង។ ក្រោយមកក៏អត់រហូតអ៊ីចឹងមក។

**ស៖** បាទ ខ្ញុំចង់សួរបញ្ជាក់ផ្ទាល់ -- សួរបញ្ជាក់បន្ថែម លោកជាអ្នកចេញទៅទិញនៅឯប្រទេសវៀតណាមផ្ទាល់ដោយខ្លួនឯង ឬមួយក៏មានអ្នកផ្សេងទៅ?

[១៥:៤៤:៣៧]

**ឆ៖** បាទ ទៅទិញ មិនទៅដល់ក្នុងប្រទេសវៀតណាមទេ គឺទៅដល់បាក់ដៃ។ ខ្ញុំទៅខ្លួនឯង។ ទៅជាមួយនឹងបងប្អូនយើងពីរបីនាក់ ឥឡូវស្លាប់អស់ហើយបងប្អូនទៅជាមួយខ្ញុំហ្នឹង។ គាត់ថាអត់លុយយកគោទៅ ដឹក បបួលគ្នាដឹកគោទៅបានថ្នាំពេទ្យ បានអង្រឹង បានខ្សែអង្រឹងអីឡប់មកវិញ។

**ស៖** បាទ លោកអាចបញ្ជាក់បាក់ដៃហ្នឹងមានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** បាក់ដៃនៅព្រំប្រទល់ខេត្តតាកែវ និងខេត្តកណ្ដាល ខាងត្បូង ព្រំប្រទល់ខាងត្បូង។

**ស៖** ហើយបាក់ដៃហ្នឹងជាប់ព្រំប្រទល់ជាមួយប្រទេសវៀតណាមដែរឬទេ?

**ឆ៖** បាទ ព្រំប្រទល់ប្រទេសវៀតណាម មានអូរមួយ ជាព្រំប្រទល់ខាងជើងកម្ពុជា ខាងត្បូងវៀតណាម។

**ស៖** លោកទៅញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ទាល់តែវាអស់អត់អីប្រើពេក ដូចជាថ្នាំពេទ្យ ដូចជាសាប៊ូលាងអំពូលលាងអីហ្នឹង។ ហ្នឹងខ្លាំងពេក សុំគណៈស្រុកអីចឹងទៅម្ដងទៅ។ ហើយទៅតាមថា ចុះខ្ញុំម៉េចក៏ទៅបានស្រួលបើនៅឆ្ងាយម្លេះ កាលនោះមិនពិបាកទេ ព្រោះខ្ញុំមានតាចុងមួយ –ប្អូនតាម៉ុកធ្វើគណៈស្រុក៥៥– ហ្នឹងនៅស្រុកព្រៃកប្បាស ហ្នឹង ចេញពីហ្នឹងបើទៅ បើយកជ្រូកទៅ អ្ហ៎ះ! យកគោទៅអី ប្រាប់គាត់ទៅ ដឹកគោហ្នឹងយកទៅដល់ឲ្យវៀតណាមឯនោះហ្នឹង ឲ្យគិតគូរថ្លៃអីប៉ុន្មានៗ “អ្នែងឲ្យថ្នាំពេទ្យឲ្យមេថ្នាំមកអញ ទៅវិញអីចឹង ធ្វើអីចឹង” អស់លុយហ្នឹងដោះដូរជាមួយសម្ភារៈ។

[១៥:៤៧:០៧]

**ស៖** បាទ ត្រឡប់មកសំណួរខ្ញុំវិញ ខ្ញុំចង់ដឹងថាលោកទៅញឹកញាប់ប៉ុនណា លោកអាចបញ្ជាក់បានទេ ១ខែម្ដង ឬក៏២ខែម្ដង ឬក៏ញឹកញាប់យ៉ាងម៉េច? លោកអាចជម្រាបបានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក រៀល សន៖**

**ឆ៖** ១ឆ្នាំទៅតែពីរដងទេ គឺនៅរដូវប្រាំង ដើមរដូវប្រាំង និងចុងរដូវប្រាំង។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកទទួលបានថ្នាំច្រើនប៉ុនណាដែរម្តងៗ?

**ឆ៖** បាទ មិនបានថ្នាំច្រើនទេ បានតិចតួច ព្រោះដល់ចុងក្រោយដែលអត់មានលុយ យកគោទៅ បើគោពីរក្បាលបានតែមេថ្នាំបេខ្ញូបួនដប់ដបប៉េនីសាលីនហ្នឹង កាល់ស្យូមនោះកន្លះគីឡូមក ហើយនិង កង់ហ្វូ ខ្ញុំភ្លេចអស់ហើយ មានបេអងទៀតម្សៅ យកមកលាយ បានបន្តិចៗហ្នឹង យកមកគ្រាន់តែប្រើប្រាស់ខ្លួនឯង។

**ស៖** បាទ សូមអរគុណ។ សូមលោកបញ្ជាក់អំពីការងាររបស់លោកបន្ថែមបានទេ ពីព្រោះខ្ញុំស្តាប់ឮការផ្តល់សក្ខីកម្មរបស់លោក ពេលខ្លះលោកនិយាយថា លោកធ្វើជាអនុប្រធាននៅមន្ទីរពេទ្យ ហើយពេលខ្លះលោកអះអាងថាជាប្រធានមន្ទីរ មន្ទីរពេទ្យស្រុកនោះ។ បាទអ៊ីចឹងសូមលោកបញ្ជាក់ ថាតើពេលដែលលោកធ្វើ ចូលធ្វើការនៅមន្ទីរពេទ្យហ្នឹង មានពេលណាមួយដែលលោកត្រូវផ្លាស់ប្តូរ ឬក៏ដំឡើងឋានៈទៅជាប្រធានមន្ទីរពេទ្យដែរទេ?

**ឆ៖** បាទ គឺគ្មានទេ។ នៅតែអនុប្រធានហ្នឹងរហូតតាំងពីទៅរហូតដល់បែកហ្នឹងតែម្តង។

[១៥:៤៩:៤៧]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងរចនាសម្ព័ន្ធនៅក្នុងមន្ទីរពេទ្យរបស់លោក លោកបានបញ្ជាក់អំពីមានប្រាំផ្នែក ដែលមានផ្នែកទូទៅ សម្ភព ផ្នែកផលិតថ្នាំ ចុងភៅ ហើយមានផ្នែកមួយទៀតនោះគឺកសិកម្ម ហើយនិងបណ្តុះបណ្តាល។ ចំណុចនេះខ្ញុំឃើញមានខ្វែងគ្នាត្រង់ឯកសារខ្លះបញ្ជាក់អំពីកសិកម្ម ហើយសក្ខីកម្មរបស់លោកនិយាយអំពីផ្នែកបណ្តុះបណ្តាល។ លោកអាចបញ្ជាក់បានទេថា តើផ្នែកណាមួយពិតប្រាកដ ទាំងប្រាំផ្នែកនោះ កសិកម្ម ឬក៏បណ្តុះបណ្តាល?

**ឆ៖** បាទ កសិកម្ម។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងផ្នែកទូទៅ ខ្ញុំចង់សួរចំណុចមួយថា តើមានអ្នកជំនាញពេទ្យ ឬក៏បុគ្គលិកដែលទទួលការហ្វឹកហ្វឺនក្នុងការពិនិត្យអ្នកជំងឺហ្នឹងប៉ុន្មាននាក់ដែរ ហើយមានជំនាញអ្វី?

[១៥:៥១:២៨]

**ឆ៖** បាទ ធាតុពិតក្នុងមួយផ្នែកៗហ្នឹងមានអ្នកជំនាញពេទ្យហ្នឹង មិនជំនាញទេ វាគ្រាន់តែឈ្មប្រើប្រាស់កើត គ្រាន់ចែកថ្នាំ ចាក់ថ្នាំអីបានហ្នឹងមានតិចតួចទេ មួយក្រុមៗមានពីរបីនាក់ៗហ្នឹង។ ក្រុម

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ខ្លះដូចជាក្រុមបុរស អាហ្នឹងខ្ញុំបាទចូលរួមផ្ទាល់។

**ស៖** បាទ សូមអរគុណ។ ទាក់ទងការបណ្តុះបណ្តាល សម្រាប់លោក លោកបានបញ្ជាក់អំពីការចូលរួមវគ្គហ្វឹកហ្វឺនពីរវគ្គ ដែលមានរយៈពេល៣ខែ និង៦ខែ។ អ៊ីចឹងខ្ញុំចង់ដឹងថា អ្នកផ្សេងដែលជាបុគ្គលិកពេទ្យនៅក្នុងមន្ទីរពេទ្យរបស់លោក ឥឡូវខ្ញុំសូមលើកអំពីផ្នែកទូទៅនេះ តើពួកគេទទួលការហ្វឹកហ្វឺនដូចម្តេចដែរ?

**ឆ៖** បាទ គឺខ្ញុំត្រឡប់មកពីរៀនវិញ ប្រមូលបុគ្គលិកពេទ្យមិនទាំងអស់គ្នាទេ យើងធ្វើ យើងរៀនពីរវគ្គ មួយវគ្គ១អាទិត្យអីទៅ។ ហើយវគ្គក្រោយទៀត ១អាទិត្យទៀតទៅ អស់គ្នាហើយ ព្រោះខ្ញុំអ្នកទៅរៀន គេនៅកន្លែង ដល់មកវិញ ដល់តែខ្ញុំបង្រៀនគេ។ អ៊ីចឹងមានតែប៉ុណ្ណឹង។

**ស៖** ការហ្វឹកហ្វឺនហ្នឹងញឹកញាប់ប៉ុនណាដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំបាទនៅពេទ្យស្រុក១ខែគឺហ្វឹកហ្វឺនម្តង ពេលដាច់ខែ។ ហ្នឹងនៅពេទ្យស្រុកខ្ញុំ ១ខែម្តងៗទោះបីតិចច្រើន គ្នានៅតិចក៏ធ្វើ ច្រើនក៏ធ្វើ លើកលែងតែថ្ងៃណាដែលមានបុណ្យអីធំៗ អត់តែម្តង។

[១៥:៥៣:៤៣]

**ស៖** លោកនិយាយ១ខែមួយម្តង ធ្វើការហ្វឹកហ្វឺននេះ គឺសម្រាប់បុគ្គលិកពេទ្យជាទូទៅនៅក្នុងមន្ទីរពេទ្យស្រុករបស់លោក តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** បាទ សូមអរគុណ។ ចុះផ្នែកសម្ភព តើខាងសម្ភពហ្នឹងមានទទួលការហ្វឹកហ្វឺនដូចម្តេចដែរ?

**ឆ៖** ខាងសម្ភពហ្នឹង ការហ្វឹកហ្វឺនក៏ខ្ញុំអ្នកបង្ហឹកដែរ ព្រោះខ្ញុំចេះឆ្មបខ្លះៗ ហើយក្រៅពីនោះហៅឆ្មប យាយឆ្មបនៅជិតៗហ្នឹងមកជួយណែនាំឧទាហរណ៍។ ខ្ញុំលើកឧទាហរណ៍ដូចជា នារីហ្នឹងពោះធំ ហើយគាត់មកសម្រាល ហើយសម្រាលវាមិនបាន វានៅធ្លាក់ឈាម ធ្លាក់អីអ៊ីចឹងដូចជា ខ្ញុំលើកឧទាហរណ៍ដូចជាហៅសុកពាំងមុខស្បូនអីហ្នឹង រត់រកយាយៗជិតៗហ្នឹងខ្លះ។ ខ្ញុំហ្នឹងផ្សំគ្នាខ្លះមក រួចហើយកាលហ្នឹង។ ឬក៏មិនអាចនារីហ្នឹងវាតូច ត្រគាកមិនអាចបើកកូនហ្នឹងចេញបាន នេះខ្ញុំជម្រាបត្រង់ជម្រាបតុលាការត្រង់ គឺខ្វែងក្បាលយកកូនហ្នឹងចេញ ឲ្យតែម៉ែនៅ។

**ស៖** សម្រាប់លោកៗទទួលចំណេះដឹងផ្នែកខាងឆ្មបនេះពីណាមកដែរ លោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេ?

[១៥:៥៥:៥២]

**ឆ៖** ផ្នែកឆ្មបនេះ ខ្ញុំបាទចេះពីប្រពន្ធខ្ញុំ ប្រពន្ធខ្ញុំបាទធ្វើឆ្មបៗតាមភូមិ។ គាត់ចេះធ្វើតាំងពីយូរហើយមក។ ប៉ុន្តែចេះហ្នឹងមិនចំណានទេ ដល់ខ្ញុំទៅរៀន ហើយគាត់បានទៅរៀនក្រោយៗមក ដូចគ្រាន់បើ ចំណានគ្រាន់បើ។

**សៈ** បាទ សូមអរគុណ។ ខ្ញុំបានស្ដាប់សក្ខីកម្មរបស់លោកតាំងពីម្សិលមិញ ហើយនិងថ្ងៃនេះ លោកបានឆ្លើយបញ្ជាក់អំពីការធ្លាប់ទៅចាក់ថ្នាំឱ្យគេ និងការព្យាបាលមួយចំនួនមុនពេលលោកធ្វើជាពេទ្យ ធ្វើជាអនុប្រធាននៅមន្ទីរពេទ្យស្រុក។ ខ្ញុំចង់ដឹងថាតើលោកបានរៀនពីអ្នកណា រៀនពីកន្លែងណាទាក់ទងនឹងការចាក់ថ្នាំ និងការឱ្យថ្នាំព្យាបាលនេះ ពីមុនមកនោះ?

**ឆ៖** បាទ អង្កាល់ពីសង្គមចាស់ ខ្ញុំនៅកំលោះអាយុប្រហែលជា១៧-១៨ឆ្នាំហ្នឹង ខ្ញុំនៅរៀនភ្នំពេញនៅវត្ត។ មិនដែលនៅសម្រាន្តក្នុងវត្តទេ គឺទៅសម្រាន្តនៅពេទ្យ ព្រោះមានពួកម៉ាកធ្វើពេទ្យនៅហ្នឹងពីរបីនាក់ណោះ។ ទៅចេះ ហើយពួកម៉ាកវាបង្ហាត់បង្ហាញឱ្យចាក់ថ្នាំ ឱ្យៗថ្នាំអីចឹងទៅ ឱ្យខ្ញុំជួយឱ្យថ្នាំអ្នកជំងឺអីចឹង យូរៗខ្ញុំចេះ។ ហើយមានក៏មានឆ្មបដែរនៅកន្លែងហ្នឹង ដូចនៅព្រះកេតុមាលាហ្នឹង ក៏មានឆ្មបដែរ។ អីចឹងគេអាចនិយាយប្រាប់ខ្ញុំបានខ្លះៗ យកមកអនុវត្តផ្ទាល់ទៅគួរសមដែរ។ ដូចជាមិនសូវឃើញអីដែរអង្កាល់នុ៎ង។

[១៥:៥៧:៥៨]

**សៈ** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ថារយៈពេលប៉ុន្មានឆ្នាំដែរ ដែលលោកអនុវត្តក្រៅផ្លូវការក្នុងការចាក់ថ្នាំ ឬក៏ឱ្យថ្នាំដល់អ្នកជំងឺនៅពេទ្យនោះ?

**ឆ៖** បាទ មិនដឹងថាប៉ុន្មានឆ្នាំទេ ប៉ុន្តែប្រហែលជាយូរដែរ ៣ឆ្នាំអី ៤ឆ្នាំណោះ បីបួនឆ្នាំ។

**សៈ** បាទ សូមអរគុណ។

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំសូមសំណួរត្រឹមប៉ុណ្ណោះ ដោយសារខាងមេធាវីមានសំណើត្រូវលើកខ្លីមួយ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយលោក វ៉ិចទ័រ កូប៉េ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ យើងចង់ប្រើប្រាស់៥នាទីចុងក្រោយនេះ ដើម្បីស្នើសុំឱ្យមានការ

បញ្ជាក់ខ្លះ។ ដោយសារ២០នាទីមុននេះ យើងបានទទួលការជូនដំណឹងអំពីការដាក់ឯកសារដោយសហព្រះរាជអាជ្ញាដែលបញ្ជាក់ថា មាន<កំណត់ហេតុនៃការស្តាបចម្លើយសាក្សីចំនួន> ២២៦ទៀត គឺថាកំពុងតែយកមកដាក់បញ្ចូលក្នុងសំណុំរឿងហើយ។ ខ្ញុំ<ហាក់ដូចជាគុញទ្រាន់នូវទង្វើនេះ> តើឯកសារទាំងអស់នេះជាឯកសារថែមពីលើ<>កំណត់ហេតុ<ចំនួន១៩០>ដែលបាននិយាយពីលើកមុន ឬក៏យ៉ាងម៉េច? <ខ្ញុំចង់ដឹងថាតើរឿងនេះវាយ៉ាងដូចម្តេច ដូច្នេះហើយទើបខ្ញុំសុំពេល៥នាទីចុងក្រោយដើម្បីសួរពីបញ្ហានេះ។ ខ្ញុំគិតថា>ប្រហែលជាសហព្រះរាជអាជ្ញាអន្តរជាតិអាចនឹងឆ្លើយក្នុងសំណួរនេះបាន។

[១៥:៥៩:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំនឹងជម្រាបជូនអង្គជំនុំជម្រះដោយសង្ខេប។ តាមដែលខ្ញុំយល់នោះ គឺថាយោងតាមសហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺនឹងដាក់កំណត់ហេតុស្តាប់ចម្លើយ ដើម្បីយកមកដាក់បង្ហាញហ្នឹងមួយចំនួន។ ហេតុដូច្នេះឯងបានជាតាមដែលយើងបានជម្រាបជូនខាងដើមហើយ គឺថាមានឯកសារដែលជាកំណត់យ៉ាងច្រើនដែលត្រូវយកមកបង្ហាញ។ ខ្ញុំមិនអាចផ្តល់ចំនួនពិតប្រាកដថានៅសល់ប៉ុន្មាននោះទៀតទេ ប៉ុន្តែនៅសល់ក្រៅពីនេះ គឺថានៅសល់តិចតួចទៀតទេ។ ខ្ញុំដឹងថាវាមានកំណត់ហេតុ<នៃការស្តាប់ចម្លើយ>មាននៅសល់ច្រើន។ ដំណឹងដែលល្អនោះគឺថា យើងបានទទួលបានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិឲ្យយក<កំណត់ហេតុនៃការស្តាប់>ចម្លើយទាំងអស់នេះមកដាក់ក្នុងសំណុំរឿង <នាពេលឥឡូវនេះ ដោយមិនរង់ចាំដល់វគ្គក្រោយៗនៃសំណុំរឿងនេះឡើយ>។

ការដែលខ្ញុំក្រោកឈរឡើងនេះ គឺខ្ញុំដើម្បីជាប្រតិចារឹក គឺថាមេធាវីការពារក្តីគួរតែមើលទៅលើឯកសារ E3/281, ERN <00168050 និង 00168073>។ នេះជាសេចក្តីថ្លែងការណ៍ជាសាធារណៈដែល នួន ជា និងខៀវ សំផង លើកសរសើរ> "បដិវត្តន៍វប្បធម៌"--

**<លោក វ៉ិចទ័រ កូប៉េ៖>**

<ប្រទេស>ចិន។

[១៦:០១:២៣]

**ប្រធានអង្គជំនុំ៖**

សូមមេធាវី គង់ សំអុន ប្រហែលចំណាយពេលវេលាប្រហែលប៉ុន្មានដែរ ក្នុងការសួរសាក្សីរូបនេះ?

**លោក គង់ សំអុន៖**

លោកប្រធាននៅមានច្រើនទៀត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះ ប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី១៩ ខែមីនា ឆ្នាំ២០១៥ ដែលចាប់ផ្តើមនៅម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី រៀល សន និងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-822 ។

ហើយក៏ទន្ទឹមនឹងហ្នឹងដែរ ក៏មានលទ្ធភាពអាចនឹងស្តាប់សារណារបស់ភាគីលើសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលសុំស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី D22/2500 ដែលដាក់សំណើតាមឯកសារ E344។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

ហើយអង្គជំនុំជម្រះ សូមអរគុណលោក រៀល សន។ ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះ កោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយនាពេលនេះ លោកអាចវិលត្រឡប់ទៅកាន់ទីកន្លែងដែលលោកស្នាក់នៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោក រៀល សន វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឲ្យអញ្ជើញគាត់ត្រឡប់ចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក ឌុច ផារី –មេធាវីប្រឹក្សាសាក្សី– អង្គជំនុំជម្រះកោះអញ្ជើញលោកមេធាវីមកបន្តចូលរួមប្រឹក្សាសាក្សី រៀល សន នៅក្នុងអំឡុងពេលសាក្សីនេះត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ នៅថ្ងៃស្អែកទៀត ដែលទំនងតែយ៉ាងយូរមួយព្រឹកប៉ុណ្ណោះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង១៦:០៣ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*